IMF inFocus

ឯកសារបំពេញបន្ថែមលើ*ការស្ទង់មតិរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ* លេខ ៣៥ កញ្ញា ២០០៦



WWW.IMF.ORG/IMFSURVEY

**អត្ថបទពិសេស :**

# ការធ្វើអោយមានការប្រែប្រួលក្នុងប្រទេស ដែលមានប្រាក់ចំណូលទាបនៅអាស៊ី

មគ្គុទេសក៍សំរាប់យល់ដឹងអំពី
មូលនិធិរូបិយវត្ថុអន្តរជាតិ

# ការណែនាំខ្លីៗដើម្បីយល់ពាក្យសំខាន់ៗមួយចំនួន

## ការសិក្សាពីពាក្យបច្ចេកទេស

សេដ្ឋកិច្ចវិទូ និង មូលនិធិរូបិយវត្ថុអន្តរជាតិបានប្រើភាសាឯកទេសមួយ ។ ទាំងនេះ គឺជាពាក្យបច្ចេកទេសខ្លះៗ ដែលប្រើប្រាស់សំរាប់ការបោះពុម្ពផ្សាយ និង ទំព័រអត្ថបទនានាដែលលោកអ្នកនឹងជួបប្រទះ ។

**លក្ខខណ្ឌ** (Conditionality)៖ ជាលក្ខខណ្ឌគោលនយោបាយដែលប្រទេសទាំងឡាយត្រូវបំពេញ ជាទូទៅនៅក្នុងពេលខ្ចីប្រាក់ពីមូលនិធិរូបិយវត្ថុអន្តរជាតិ (សូមមើលទំព័រ ២៣) ។

**ការរាលដាល** (Contagion)៖ ជាការរីកសាយភាយវិបត្តិសេដ្ឋកិច្ចពីប្រទេសមួយទៅប្រទេសមួយទៀត (សូមមើលទំព័រ ១៧) ។

**កម្មវិធីឥណទាន** (Facilities)៖ ប្រភេទឥណទានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ដែលប្រទេសជាសមាជិកអាចខ្ចីបាន (មើលទំព័រ ២៥) ។

**អភិបាលកិច្ច** (Governance)៖ សំដៅលើលក្ខណៈទាំងអស់ដែលប្រទេសមួយ ឬ ស្ថាប័នមួយមានក្នុងការគ្រប់គ្រង ដោយរួមបញ្ចូលក្របខ័ណ្ឌបទបញ្ញត្តិ និង គណនេយ្យភាព (សូមមើលទំព័រ ១៩) ។

**ការតាមដានឃ្លាំមើលរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ** (IMF Surveillance)៖ តាមន័យចំ គឺការតាមដានឃ្លាំមើល ៖ នៅក្រោមមាត្រានានានៃកិច្ចព្រមព្រៀងរបស់ខ្លួន មូលនិធិរូបិយវត្ថុអន្តរជាតិមានភារកិច្ចទទួលខុសត្រូវតាមដានឃ្លាំមើលប្រព័ន្ធរូបិយវត្ថុអន្តរជាតិ និង តាមដានយ៉ាងម៉ត់ចត់លើគោលនយោបាយអត្រាប្តូរប្រាក់របស់ប្រទេសជាសមាជិកនានា ។ ការតាមដានគឺជាសកម្មភាពដ៏សំខាន់ របស់មូលនិធិរូបិយវត្ថុអន្តរជាតិ រួមមានការតាមដានការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចពិភពលោក និង សេដ្ឋកិច្ចប្រទេសនីមួយៗ ហើយផ្តល់ពត៌មានដល់អ្នកធ្វើគោលនយោបាយ ប្រសិនបើមានអ្វីដែលមិនបានអនុវត្តចំទិសដៅ ឬ គោលនយោបាយនានាដែលតម្រូវឱ្យមានការកែតំរូវ (សូមមើលទំព័រ ១៧) ។

**ម៉ាក្រូសេដ្ឋកិច្ច** (Macroeconomics)៖ ពាក្យម៉ាក្រូមានប្រភពពីភាសាក្រិច ដែលមានន័យថា "ធំ" ។ ដូចនេះ "ម៉ាក្រូសេដ្ឋកិច្ច" គឺសំដៅលើដំណើរការណ៍សេដ្ឋកិច្ចរបស់ប្រទេសទាំងមូលដែលមានអថេរដូចជា ទ្រព្យធនសរុប ប្រាក់សរុប ចំណូល ភាពអត់ការងារធ្វើ អតិផរណា និងអត្រាប្តូរប្រាក់ (តំលៃរូបិយប័ណ្ណនានាធៀបនឹងរូបិយប័ណ្ណផ្សេងៗទៀត) ។ ផ្ទុយទៅវិញ មីក្រូសេដ្ឋកិច្ចសំដៅលើប្រព្រឹត្តកម្មនៃស្ថាប័នសេដ្ឋកិច្ចទាំងឡាយណាដែលមានឯកត្តលក្ខណៈ ដូចជា សំរាប់គ្រួសារ និង សំរាប់ក្រុមហ៊ុនឯកជនជាដើម និង មានការកំណត់ថ្លៃធៀបនានា (សូមមើលទំព័រ ១៦) ។

**តំលៃបច្ចុប្បន្នសុទ្ធ** (Net Present Value - NPV) គឺជាវិធី ដើម្បីវាយតំលៃទៅលើតំលៃនៃការទូទាត់ពេលអនាគត ដោយមើលលើតំលៃនាពេលបច្ចុប្បន្ន នៃលំហូរសាច់ប្រាក់ពេលអនាគតដែលបានធ្វើអប្បហារតាមកំរៃមូលធនសព្វថ្ងៃ (សូមមើលទំព័រទី ២៩) ។

**សិទ្ធិដកប្រាក់ពិសេស** (Special Drawing Rights - SDR) ជាទ្រព្យបំរុងអន្តរជាតិបង្កើតឡើងដោយ មូលនិធិរូបិយវត្ថុអន្តរជាតិនៅក្នុងឆ្នាំ ១៩៦៩ ដើម្បីបំពេញបន្ថែមលើទុនបំរុងរបស់ប្រទេសសមាជិក ។ សិទ្ធិដកប្រាក់ពិសេសត្រូវបានគេធ្វើការបែងចែកទៅឱ្យប្រទេសសមាជិកជាសមាមាត្រទៅតាមកូតារបស់ប្រទេសនីមួយៗ ។ សិទ្ធិដកប្រាក់ពិសេសក៏មានតួនាទីជាឯកតាគណនីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។ តំលៃទឹកប្រាក់នៃសិទ្ធិដកប្រាក់ពិសេសគឺធ្វើឡើងដោយផ្អែកលើបណ្តុំនៃតំលៃរូបិយវត្ថុអន្តរជាតិសំខាន់ៗ (សូមមើលទំព័រទី ១៤) ។

**និរន្តរភាព**(Sustainability)៖ មូលនិធិរូបិយវត្ថុអន្តរជាតិជំរុញគោលនយោបាយដែលគេបានរៀបចំឡើងក្នុងគោលបំណងធានានិរន្តរភាពនៃការរីកចំរើន គឺថាការរីកលូតលាស់ដែលមិនមានភាពរអាក់រអួលដែលបង្កឡើងដោយ ឧទាហរណ៍ "ភាពចំរុងចំរើន និង វិបត្តិសេដ្ឋកិច្ច" ។ បំណុលរបស់ប្រទេសមួយអាចមាននិរន្តរភាព ប្រសិនបើបំណុលនោះ ត្រូវបានគេសងវិញដោយមិនប៉ះពាល់ដល់ស្ថានភាពសេដ្ឋកិច្ច (សូមមើលទំព័រ ១៧) ។

**តម្លាភាព** (Transparency) សំដៅលើថាតើស្ថាប័នមួយមានការបើកចំហចំពោះសាធារណៈជន ។ ស្ថាប័នមួយ កាន់តែមានតម្លាភាព ស្ថាប័ននោះកាន់តែរក្សាការជូនដំណឹងដល់សាធារណៈជនអំពីសកម្មភាព និង វិធីប្រតិបត្តិទាំងឡាយរបស់ខ្លួន (សូមមើលទំព័រទី ១៩) ។

សំរាប់ពត៌មានបន្ថែមសូមមើលវាក្យស័ព្ទហិរញ្ញវត្ថុនៃសន្ទានុក្រមរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ នៅគេហទំព័រ (www.imf.org)

គំរបបង្ហាញពីស្ត្រីម្នាក់ថែរទូកតាមទន្លេមេគង្គ ឡុង ស៊ុយិន (Long Xuyen) ប្រទេសវៀតណាម ។ ប្រទេសនេះបានធ្វើឱ្យការប្រឹងប្រែងយ៉ាងខ្លាំងក្នុងសេរីភាវូបនីយកម្ម នៃប្រព័ន្ធពាណិជ្ជកម្មរបស់ខ្លួន (សូមមើលទំព័រទី ៣) ។ (Steve Raymer/CORBIS)

# IMF inFocus

## ឯកសារបំពេញបន្ថែមលើការស្ទង់មតិរបស់ មូលនិធិរូបិយវត្ថុអន្តរជាតិ

IN THIS ISSUE


២ **ការធ្វើអោយមានការប្រែប្រួល**
មូលនិធិរូបិយវត្ថុអន្តរជាតិ និង ប្រទេសដែលមានប្រាក់ចំណូលទាបនៅអាស៊ី

៧ **ការបង្កើតមាគ៌ាថ្មីមួយ**
យុទ្ធសាស្ត្ររយៈពេលមធ្យមរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ

៨ **ព្រឹត្តិការណ៍ចំនួន ១០ ដែលជះឥទ្ធិពលដល់មូលនិធិរូបិយវត្ថុអន្តរជាតិ**
ការពិនិត្យទូទៅលើប្រវត្តិការងារ

១៣ **ការចាត់ចែងមូលនិធិរូបិយវត្ថុអន្តរជាតិ**
ការរៀបចំ និង ហិរញ្ញវត្ថុ

១៥ **គណៈកម្មការប្រតិបត្តិនៃមូលនិធិរូបិយវត្ថុអន្តរជាតិ**
តំណាងរបស់ប្រទេស និង សន្លឹកឆ្នោត

១៦ **ជំរុញសេដ្ឋកិច្ចអោយមានសុខភាពរឹងមាំ**
ការត្រួតពិនិត្យតាមដានសេដ្ឋកិច្ច និង ការទប់ស្កាត់វិបត្តិ

២០ **ផ្តល់ជំនួយនៅពេលមានបញ្ហាកើតឡើង**
ដំណោះស្រាយវិបត្តិ

២២ **ការត្រឡប់មករកភាពប្រក្រតី**
ការផ្តល់ប្រាក់កំចី និង លក្ខខណ្ឌ

២៥ **មូលនិធិរូបិយវត្ថុអន្តរជាតិផ្តល់ឥណទានយ៉ាងដូចម្តេច**
លក្ខខណ្ឌមួយចំនួននៃកម្មវិធីឥណទានហិរញ្ញវត្ថុនានា

២៦ **ការផ្ទេរចំណេះធ្វើ**
ជំនួយបច្ចេកទេស និង ការបណ្តុះបណ្តាល

២៨ **ការតស៊ូដើម្បីជីវភាពប្រសើរឡើង**
ការកាត់បន្ថយភាពក្រីក្រ និង ជំនួយលប់បំណុល

៣២ **ដើម្បីបង្កើនតម្លាភាព និង គណនេយ្យភាពរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ**
ការិយាល័យវាយតំលៃឯករាជ្យ

៣៣ **ទិដ្ឋភាពរួម**
សូចនាករសំខាន់ៗរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ

៣៣ **មូលនិធិរូបិយវត្ថុអន្តរជាតិត្រូវបានរៀបចំយ៉ាងដូចម្តេច**



2
Chris Stowers/Panos Pictures


16
Bernd Jonkmanns/laif/Aurora & Quanta Productions, Inc.


22
Dinka Spirovka/Bloomberg News/Landov


Laura Wallace
*Editor-in-Chief*

Sheila Meehan
*Managing Editor*

Christine Ebrahim-zadeh
*Production Manager*

Jeremy Clift
*Senior Editor*

Elisa Diehl
Ina Kota
*Assistant Editors*

Maureen Burke
Lijun Li
Kelley McCollum
*Editorial Assistants*

Lai Oy Louie
*Art Editor*

Stephen Jaffe
Michael Spilotro
*Photo Editors*

Kanitta Meesook
*Senior Advisor*



IMF inFocus ( មូលនិធិរូបិយវត្ថុអន្តរជាតិ ដែលអាចមើលឃើញច្បាស់ ) គឺជាឯកសារបំពេញបន្ថែមលើ IMF Survey ( ការស្ទង់មតិរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ) ។ ការស្ទង់មតិរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (ISSN 0047-083X) គឺជាព្រឹត្តិប័ត្របោះពុម្ពផ្សាយជាភាសាអង់គ្លេស បារាំង និង អេស្ប៉ាញ ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ ។ គំនិតយោបល់ និង ឯកសារនៅក្នុង IMF Survey និង IMF inFocus មិនចាំបាច់ឆ្លុះបញ្ចាំងអំពីទស្សនៈជាផ្លូវការរបស់មូលនិធិរូបិយវត្ថុអន្តរជាតិឡើយ ។ អត្ថបទទាំងឡាយនៅក្នុង IMF Survey និង IMF inFocus អាចបោះពុម្ពឡើងវិញបានទៅតាមការអនុញ្ញាតដែលអាចផ្តល់អោយ ប៉ុន្តែរូបភាព និង គំនូរបញ្ជាក់នានា មិនអាចធ្វើការបោះពុម្ពផ្សាយឡើងវិញក្រោមទំរង់ណាមួយឡើយ ។
សូមផ្ញើការទាក់ទងនៃបទវិចារណកថាទៅកាន់ Current Publications Division បន្ទប់លេខ ៧-១០៦ មូលនិធិរូបិយវត្ថុអន្តរជាតិ វ៉ាស៊ីនតោនឌីស៊ី 20431 U.S.A ទូរស័ព្ទលេខ : ( ២០២ ) ៦២៣-៨៥៨៥ ឬ តាមរយៈអ៊ីម៉ែលសំរាប់ការផ្តល់មតិ : imfsurvey@imf.org. ។ IMF Survey ត្រូវបានគេផ្ញើសារ ក្នុងលំដាប់ទី ១ នៅក្នុងប្រទេសកាណាដា ម៉ិចស៊ិច និង ក្នុងសហរដ្ឋអាមេរិក និង ដោយអាកាសចរល្បឿនលឿននៅទីផ្សេងៗទៀត ។ ក្រុមហ៊ុនឯកជន និង បុគ្គលទាំងឡាយត្រូវបានកំណត់យកថ្លៃ ១២០ ដុល្លា ក្នុងមួយឆ្នាំ ។ ការដាក់ពាក្យស្នើសុំជាវត្រូវទាក់ទងផ្នែកសេវាកម្មបោះពុម្ព ប្រអប់សំបុត្រលេខ X2006, IMF, Washington, DC 20431 U.S.A
ទូរស័ព្ទលេខ : ( ២០២ ) ៦២៣-៧៤៣០ ទូរសារលេខ : ( ២០២ ) ៦២៣-៧២០១, អ៊ីម៉ែល : publications@imf.org.

### មូលនិធិរូបិយវត្ថុអន្តរជាតិ និង ប្រទេសដែលមានប្រាក់ចំណូលទាបនៅអាស៊ី

# ការធ្វើឱ្យមានការប្រែប្រួល




Chris Stowers/Panos Pictures

កំពង់ផែរបស់វៀតណាមនៅទីក្រុងហូជីមិញ មមាញឹកជាមួយសកម្មភាព

អាស៊ីប៉ាស៊ីហ្វិកគឺជាតំបន់ដែលមានសកម្មភាពក្លៀវក្លាផ្នែកសេដ្ឋកិច្ច និង ភាពចម្រុះប្លែកៗគ្នាបំផុត នៅលើពិភពលោក។ តំបន់នេះ បានក្លាយជាកំលាំងជំរុញកំណើនសេដ្ឋកិច្ចពិភពលោកដ៏សំខាន់មួយ ដោយមានសេដ្ឋកិច្ចធំៗបួន ក្នុងចំណោមសេដ្ឋកិច្ចធំៗទាំងដប់ពីរនៅលើពិភពលោក គឺ ជប៉ុន ចិន ឥណ្ឌា និង កូរ៉េ ព្រមទាំងប្រទេសកំពុងរីកចំរើនខ្លាំងមួយចំនួនទៀត ។ ទោះជាយ៉ាងនេះក្តី អាស៊ីប៉ាស៊ីហ្វិកក៏ជាតំបន់ដែលមានប្រទេសក្រីក្របំផុតក្នុងពិភពលោកមួយចំនួនផងដែរ ។ ប្រទេសក្រីក្រ មានចំណូលទាបបំផុត ទាំងនេះនៅបន្តត្រូវការ ការជួយជ្រោមជ្រែង ដើម្បីសម្របសម្រួលនឹងតំរូវការថ្មីនៃសកលភាវូបនីយកម្ម ។

នៅទូទាំងតំបន់ មូលនិធិរូបិយវត្ថុអន្តរជាតិ បានធ្វើការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាលរបស់ប្រទេសមានកំរិតប្រាក់ចំណូលទាបនៅអាស៊ី ដែលរួមមាន ១៧ប្រទេស និង មានប្រជាពលរដ្ឋសរុបលើស ៣៥០លាននាក់ ដោយរួមបញ្ចូលទាំង ប្រជាពលរដ្ឋមួយភាគធំដែលរស់នៅក្នុងភាពក្រីក្រ មានន័យថា ពួកគេមានប្រាក់ចំណូលតិចជាង ២ ដុល្លាក្នុងមួយថ្ងៃ ។ ប្រទេសទាំងនេះមានស្ថានភាពខុសប្លែកៗពីគ្នា ក្នុងនោះមានប្រទេសស្ថិតក្នុងអន្តរកាលកំពុងឈានទៅកាន់ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ( ដូចជា វៀតណាម កម្ពុជា និង ម៉ុងហ្គោលី) សេដ្ឋកិច្ចមហាសាគរប៉ាស៊ីហ្វិក (ដូចជា ប៉ាពួរនូហ្គីណេ) ដែលមានចំណុចខ្សោយដោយសារទីផ្សារតូចចង្អៀត និងប្រទេសងាយរងគ្រោះដោយគ្រោះធម្មជាតិ និង វិបត្តក្រៅប្រទេសផ្សេងទៀត ( ដូចជា បង់ក្លាដែសជាដើម) ។

ក្នុងខណៈដែលប្រទេសនីមួយៗ កំពុងប្រឈមមុខនឹងឧបសគ្គផ្ទាល់រៀងៗខ្លួន ប្រទេសទាំងនោះ មានលក្ខណៈសម្បត្តិមួយចំនួន សដៀងគ្នា នៅក្នុងយុទ្ធសាស្ត្រកំណែទំរង់របស់ពួកគេ ដូចជាៈ ការអនុវត្តន៏គោលនយោបាយដែលមានលំនឹង ការពង្រឹងសមត្ថភាពធនធានមនុស្ស និង ស្ថាប័ន ការកែលំអបរិស្ថានវិនិយោគឱ្យមានលក្ខណៈប្រសើរឡើងដើម្បីទាក់ទាញវិនិយោគិនបរទេស ការបង្កើតការងារ និង ការកាត់បន្ថយភាពក្រីក្រ ។ នៅក្នុងវិស័យទាំងអស់នេះ មូលនិធិរូបិយវត្ថុអន្តរជាតិ បានធ្វើការជាមួយប្រទេសមានកំរិតប្រាក់ចំណូលទាប ដើម្បីពង្រឹងសមត្ថភាពតាមរយៈការផ្តល់យោបល់ប្រឹក្សាសំរាប់ការរៀបចំគោលនយោបាយ ការផ្តល់ជំនួយបច្ចេកទេស និង ការគាំទ្រផ្នែកហិរញ្ញវត្ថុ ។ ស្ថានភាពបច្ចុប្បន្ន របស់ប្រទេសចំនួនប្រាំខាងក្រោម នឹងបង្ហាញនូវសកម្មភាពរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។

## ■ សេរីភាវូបនីយកម្មពាណិជ្ជកម្ម : ប្រទេសវៀតណាម

ការបើកចំហទីផ្សារសេដ្ឋកិច្ចរបស់ប្រទេសវៀតណាម ជាវិធីមួយដើម្បីសំរេចនូវកំណើនសេដ្ឋកិច្ចឆាប់រហ័ស និង ប្រកបដោយនិរន្តរភាព ព្រមទាំងធ្វើឱ្យកំរិតជីវភាពរបស់ប្រជាពលរដ្ឋមានភាពប្រសើរឡើង ។ ចាប់តាំងពីឆ្នាំ ១៩៨៦ វៀតណាមបានប្រឹងប្រែងធ្វើសេរីភាវូបនីយកម្មប្រព័ន្ធពាណិជ្ជកម្មរបស់ខ្លួន ។ តាមប្រសាសន៏របស់លោក ឡាហ្សារ៉ូស ម៉ុលឡូ(Lazaros Molho) ប្រធានក្រុមបេសកកម្មរបស់មូលនិធិរូបិយវត្ថុអន្តរជាតិសំរាប់ប្រទេសវៀតណាម បានឱ្យដឹងថា "ការរុះរើចេញនូវរបាំងពាណិជ្ជកម្ម គឺជាស្នូលនៃគោលនយោបាយកំណែទំរង់ដូយម៉ុយ (Doi Moi) ឬ ការកែលំអសេដ្ឋកិច្ចឡើងវិញ ហើយមូលនិធិរូបិយវត្ថុអន្តរជាតិ បានគាំទ្រនូវយុទ្ធសាស្ត្រនេះ" ។

នៅក្នុងចន្លោះឆ្នាំ ១៩៩៣-២០០៤ ការបើកចំហពាណិជ្ជកម្មរបស់វៀតណាម ដែលអាចគណនាបានតាមរយៈ ផលបូករវាងការនាំចេញ និងការនាំចូល ហើយចែកនឹងផលិតផលសរុបក្នុងស្រុក ឃើញថាមានការកើនឡើងជាងទ្វេដង រីឯអនុបាត ឬ ផលធៀបការនាំចេញរបស់ប្រទេសនេះ និងការនាំចេញរបស់ពិភពលោកមានការកើនឡើងជាងបីដង ។ ដោយមានវិស័យនាំចេញ និង ការកើនឡើងផ្នែកវិនិយោគផ្ទាល់ពីបរទេសជាកត្តាជំរុញសេដ្ឋកិច្ច កំណើនសេដ្ឋកិច្ចរបស់វៀតណាម មានការកើនឡើងគួរឱ្យកត់សំគាល់ (កំណើនផលិតផលសរុបក្នុងស្រុកជាមធ្យមបានកើនឡើងជាង ៧,៥ភាគរយក្នុងមួយឆ្នាំៗ នៅចន្លោះ ឆ្នាំ ១៩៩៣-២០០៥) ហើយបានកាត់បន្ថយភាពក្រីក្រយ៉ាងឆាប់រហ័ស (ពី ៥៨ភាគរយ ក្នុងឆ្នាំ ១៩៩៣ មកនៅក្រោម ២០ ភាគរយ ក្នុងឆ្នាំ ២០០៤) ។ ទាំងក្នុងតំបន់ និង លើឆាកអន្តរជាតិ លោក ម៉ុលឡូ (Molho) បានមានប្រសាសន៏ថា "ប្រការនេះ គឺជាលទ្ធផលមួយគួរឱ្យចាប់អារម្មណ៏" ។

ចាប់តាំងពីឆ្នាំ ១៩៩៣ កម្មវិធីកំណែទំរង់ទាំងអស់របស់វៀតណាម ដែលមានការគាំទ្រពីសំណាក់មូលនិធិរូបិយវត្ថុអន្តរជាតិ សុទ្ធតែមានសមាសធាតុសេរីភាវូបនីយកម្មពាណិជ្ជកម្ម ដែលក្នុងនោះរួមមាន ការសំរួលនីតិវិធីក្នុងការផ្តល់អាជ្ញាប័ណ្ណនាំចូល ការបញ្ចប់នូវប្រព័ន្ធកូតាជាជំហានៗ និង ការធ្វើសេរីភាវូបនីយកម្មសំរាប់សិទ្ធិធ្វើពាណិជ្ជកម្ម ។ ជាអាទិ៍ក្នុងចំណោមកិច្ច ខិតខំប្រឹងប្រែងថ្មីៗរបស់ប្រទេសវៀតណាម រួមមានផែនទីមាគ៌ាគោលនយោបាយសំរាប់ពាណិជ្ជកម្មឆ្នាំ ២០០១-២០០៥ ដែលអំពាវនាវឱ្យមានការកាត់បន្ថយពន្ធនាំចូល ការលុបចោលការកំណត់បរិមាណទំនិញនាំចូល និង វិធានការផ្សេងៗទៀត ដែលផ្តោតលើការរៀបចំមូលដ្ឋានសំរាប់ការចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) ។ ការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីជាមួយសហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០១ បានផ្តល់ឱ្យវៀតណាមនូវសន្ទុះមួយកំរិតថែមទៀត ចំពោះកិច្ចខិតខំ ប្រឹងប្រែងធ្វើសេរីភាវូបនីយ៏កម្មពាណិជ្ជកម្ម និង វិនិយោគក៏ដូចជាការផ្តល់នូវក្របខ័ណ្ឌដ៏មានសារៈប្រយោជន៏ សំរាប់ការសុំចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។ ការបេជ្ញាចិត្តនៅក្នុងកំរិតតំបន់ ក្រោមក្របខ័ណ្ឌតំបន់ពាណិជ្ជកម្មសេរីរបស់អាស៊ាន (ASEAN Free Trade Area) ក៏បានដើរតួជាកត្តាដ៏សំខាន់ក្នុងការធ្វើសេរីភាវូបនីយកម្ម និង បានចូលរួមចំណែកដល់ការកើនឡើងយ៉ាងឆាប់រហ័សនៃលំហូរពាណិជ្ជកម្មរបស់វៀតណាមក្នុងទសវត្សរ៏កន្លងមកនេះ ។

ទោះជាយ៉ាងណានេះក្តី ប្រទេសវៀតណាមនៅបន្តមានលទ្ធភាពបន្ថែមទៀត ក្នុងការរំលាយចោលនូវរបាំងមិនមែនពន្ធនាំចូល និង ការកាត់បន្ថយអត្រាពន្ធនាំចូលជាមធ្យមបន្ថែមទៀត ដែលនៅតែមានអត្រាខ្ពស់ជាងគេក្នុងតំបន់អាស៊ី និង ការបន្តធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងការវិនិយោគ ។ ការចរចាសុំចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ដែលកំពុងតែប្រព្រឹត្តទៅ បានក្លាយជាអភិក្រមដ៏សំខាន់សំរាប់ការធ្វើសមាហរណកម្មអន្តរជាតិជាជំហ៊ានៗ ។ ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក មិនគ្រាន់តែផ្តល់ឱកាសសំរាប់ពាណិជ្ជកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយជំរុញដល់ការរីកចំរើន ក្នុងផ្នែកបរិស្ថាន ច្បាប់ និង ពាណិជ្ជកម្ម ហើយបន្តការលើកកំពស់ការចាប់អារម្មណ៏លើវៀតណាម ជាគោលដៅសំរាប់ការវិនិយោគបរទេសផ្ទាល់ថែមទៀត ។

មូលនិធិរូបិយវត្ថុអន្តរជាតិ បានគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងសុំចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ហើយបានផ្តល់យោបល់បន្ថែមលើចំនុចខ្វះខាតនានា និង ជំនួយផ្នែកបច្ចេកទេសដល់វៀតណាម ក្នុងការអភិវឌ្ឍន៏ ប្រព័ន្ធប្តូររូបិយប័ណ្ណដែលមានលក្ខណៈបើកទូលាយ និង ប្រសិទ្ធភាពថែមទៀត។ ទាក់ទងនឹងចំណុចចុងក្រោយនេះ វៀតណាម បានធ្វើការសំរេចចិត្តដ៏សំខាន់មួយកាលពីខែ តុលា ឆ្នាំ ២០០៥ ក្នុងខណៈដែលប្រទេសនេះ បានលុបចោលនូវរបាំងសេសសល់ចំពោះការទូទាត់ចរន្តអន្តរជាតិរបស់ខ្លួន ។ នៅក្នុងពេលអនាគត មូលនិធិរូបិយវត្ថុអន្តរជាតិ នឹងបន្តផ្តល់អនុសាសន៏ដល់ប្រទេសវៀតណាម ក្នុងការកំណត់គោលនយោបាយលើការគ្រប់គ្រងវិស័យម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយកំណែទំរង់រចនាសម្ព័ន្ធ ក្នុងបរិបទនៃប្រតិបត្តិការត្រួតពិនិត្យតាមដាន ហើយនឹងផ្តល់ជាជំនួយបច្ចេកទេសគ្រប់ពេលវេលាក្នុងការជួយរដ្ឋាភិបាល ដើម្បីធ្វើការអភិវឌ្ឍន៏ទីផ្សាររូបិយប័ណ្ណបរទេស ដែលផ្អែកទៅលើគោលការណ៏ទីផ្សារ និង ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។

## ■ ការកាត់បន្ថយវិបត្តិ : ប្រទេសបង់ក្លាដែស

ជាមួយនឹងការបញ្ចប់កូតាក្រោមកិច្ចព្រមព្រៀងពហុវាយនភ័ណ្ឌ របស់អង្គការពាណិជ្ជកម្មពិភពលោក នៅចុងឆ្នាំ ២០០៤ ប្រទេសមានកំរិតប្រាក់ចំណូលទាបជាច្រើនក្នុងតំបន់អាស៊ី ក្នុងនោះមានប្រទេសបង់ក្លាដែសផងដែរ មានការព្រួយបារម្ភចំពោះការប្រកួតប្រជែងកាន់តែស្រួចស្រាវ ជាពិសេសពីសំណាក់ប្រទេសចិនដែលអាចធ្វើឱ្យប៉ះពាល់ដល់ទីផ្សារវាយនភ័ណ្ឌ និង សំលៀកបំពាក់ដែលពួកគេពឹងផ្អែកសំរាប់ការរកចំណូលជារូបិយប័ណ្ណបរទេស និង ការងារ ។

ដោយទទួលស្គាល់អំពីហានិភ័យទាំងនេះ មូលនិធិរូបិយវត្ថុអន្តរជាតិ បានដាក់ចេញនូវយន្តការសមាហរណកម្ម ពាណិជ្ជកម្ម (Trade Integration Mechanism - TIM) ក្នុងខែ មេសា ឆ្នាំ ២០០៤ (សូមមើលទំព័រទី ១៩) ដើម្បីជួយប្រទេសជាសមាជិកក្នុងការដោះស្រាយកង្វះខាតជាបណ្តោះអាសន្ន ដើម្បីសំរេចបាននូវតុល្យភាពជញ្ជីងទូទាត់។ រយៈពេលពីរខែក្រោយមក មូលនិធិរូបិយវត្ថុអន្តរជាតិបានផ្តល់ឱ្យប្រទេសបង់ក្លាដែស ដែលជាប្រទេសនាំចេញនូវផលិតផលសំរេចសំលៀកបំពាក់ដ៏ធំមួយនូវប្រាក់កម្ចី មានតំលៃទឹកប្រាក់រហូតដល់ ៧៨ លានដុល្លាសហរដ្ឋអាមេរិក ជាផ្នែកមួយនៃការគាំទ្រផ្នែកហិរញ្ញវត្ថុ ស្ថិតក្រោមយន្តការ (TIM) ដើម្បីជួយប្រទេសនេះ ក្នុងការដោះស្រាយនូវសម្ពាធលើជញ្ជីងទូទាត់តាមការគ្រោងទុក។

លោក ថូម៉ាស រាំបូ (Thomas Rumbaugh) ប្រធានក្រុមបេសកកម្មរបស់មូលនិធិរូបិយវត្ថុអន្តរជាតិសំរាប់ប្រទេសបង់ក្លាដែស បានមានប្រសាសន៍ឱ្យដឹងថា "ដំណឹងល្អនោះគឺថាប្រទេសនេះ បានឆ្លងរួចផុតពីព្យុះ និង កំពុងតែធ្វើការប្រកួតប្រជែងដោយមានប្រសិទ្ធភាពបំផុតក្នុងវិស័យនេះ" ។ ការនាំចេញសំលៀកបំពាក់សំរេច ត្រូវរក្សាបានលើសពីអ្វីដែលគេរំពឹងទុក ហើយបានទទួលប្រយោជន៍ពីការដាក់សារជាថ្មីនូវវិធានការ កូតា "គាំពារទំនិញក្នុងស្រុក" (Safeguard) ចំពោះការនាំចេញវាយនភ័ណ្ឌ និងសំលៀកបំពាក់ពីប្រទេសចិន។ ទោះជាយ៉ាងនេះក្តី បញ្ហាប្រឈមស្ថិតនៅចំពោះមុខនៅឡើយ ហើយការសង្ឃឹមទុកលើការនាំចេញផលិតផលសំលៀកបំពាក់សំរេច គឺពឹងផ្អែកលើសមត្ថភាពរបស់ប្រទេសបង់ក្លាដែស ក្នុងការដោះស្រាយឧបសគ្គនានាក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរដ្ឋបាលគយសាំញ៉ាំ តំរូវការបទបញ្ញត្តិស្មុគស្មាញ និង ការព្រួយបារម្ភលើអភិបាលកិច្ច និង បញ្ហាសន្តិសុខ។

អត្រាប្តូរប្រាក់មានលក្ខណៈទន់ភ្លន់បានច្រើនជាងមុន គឺជាហេតុផលមួយទៀតដែលធ្វើឱ្យបង់ក្លាដែស អាចងើបឡើងវិញបានយ៉ាងឆាប់រហ័ស ។ លោក អូលីន លីវ (Olin Liu) ដែលជាសមាជិករបស់ក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិ បានបញ្ជាក់ថាជាមួយ នឹងការផ្តល់សញ្ញាតំលៃមួយដែលមានប្រសិទ្ធភាពជាងមុន ភាពទន់ភ្លន់នេះ "មិនគ្រាន់តែជួយបែងចែកធនធានសេដ្ឋកិច្ចសំរាប់ប្រើប្រាស់ឱ្យមានប្រសិទ្ធភាពនោះទេ ប៉ុន្តែថែមទាំងផ្តល់សមត្ថភាពសេដ្ឋកិច្ច ក្នុងការកាត់បន្ថយការរាំងស្ទះនៃវិស័យក្រៅស្រុកដែលកើតឡើងពីបំរែបំរួលភ្លាមៗនៃបរិស្ថានសកលលោក នៅពេលដែលបានរៀបចំគោលនយោបាយ ម៉ាក្រូសេដ្ឋកិច្ចយ៉ាងប្រុងប្រយ័ត្ន"។



ស្ត្រីបង់ក្លាដេសដេរសំលៀកបំពាក់ក្នុងរោងចក្រមួយនៅក្រុងដាកា

Mohammad Shahidullah/Reuters/Landov

ការផ្តល់អនុសាសន៍ ក្នុងការរៀបចំ គោលនយោបាយ និង ជំនួយបច្ចេកទេសរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ បានជួយ បង់ក្លាដែស ក្នុងការឈានទៅអនុវត្តប្រព័ន្ធអត្រាប្តូរប្រាក់ ដែលមានលក្ខណៈទន់ភ្លន់។ ជំនួយបច្ចេកទេសក៏បានជួយអោយធនាគារកណ្តាល អាចពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការទ្រទ្រង់ អត្រាប្តូរប្រាក់មានលក្ខណៈទន់ភ្លន់ និង រៀបចំក្របខ័ណ្ឌ រូបិយវត្ថុ ទៅតាមគោលការណ៍សេដ្ឋកិច្ចទីផ្សារ សំរាប់ការគ្រប់គ្រប់អតិផរណា ។ អាជ្ញាធរបានដាក់ឱ្យតំលៃនៃរូបិយប័ណ្ណ ទៅតាមគោលការណ៍សេដ្ឋកិច្ចទីផ្សារសំរាប់ការគ្រប់គ្រងអតិផរណា ។ អាជ្ញារធរបានដាក់ឱ្យតំលៃនៃរូបិយប័ណ្ណ "កាតា" (Kata) ឱ្យមានការប្រែប្រួលដោយសេរី នៅចុងខែ ឧសភា ឆ្នាំ ២00៣ ដោយលប់ចោលនូវការកំណត់អត្រាប្តូរប្រាក់សំរាប់ ការទិញ និង ការលក់ប្រាក់ដុល្លា ។ លោក រាំបូ (Rumbaugh) បានមានប្រសាសន៍ថា "ចាប់តាំងពីពេលនោះមកប្រព័ន្ធថ្មីនេះមានដំណើរការល្អ " ។ ការប្តេជ្ញាចិត្តចំពោះអត្រាប្តូរប្រាក់ផ្អែកលើទីផ្សារ គាំទ្រសមត្ថភាពសេដ្ឋកិច្ច នៅក្នុងការសំរបខ្លួនទៅនឹងបំរែបំរួលនានានៃបរិស្ថានខាងក្រៅ ។ ប្រការនេះមានសារៈសំខាន់ក្នុងការគាំពារការអនុវត្តន៏ដ៏រឹងមាំបន្តទៅទៀត ក្នុងវិស័យនាំចេញ និង ការផ្ទេរចំណូលដែលជាសារធាតុសំខាន់ៗនៃយុទ្ធសាស្ត្រកំណើន និង កាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាល ។ ដើម្បីសំរេចគោលដៅនេះ មូលនិធិរូបិយវត្ថុអន្តរជាតិនៅតែបន្តផ្តល់ជំនួយបច្ចេកទេស និង អនុសាសន៍ក្នុងការរៀបចំគោលនយោបាយតទៅទៀត ។

**ការពង្រឹងការគ្រប់គ្រងធនាគារ : ប្រទេសប៉ាពួរនូហ្គីណេ** (Papua New Guinea)

ក្នុងខណៈដែលមូលនិធិរូបិយវត្ថុអន្តរជាតិបានបើកការិយាល័យរបស់ខ្លួន នៅឯផតម៉ូរេសប៊ី (Port Moresby) កាលពី ខែ កញ្ញា ឆ្នាំ២000 សេដ្ឋកិច្ចរបស់ប៉ាពួរនូហ្គីណេបានប្រឈមនូវបញ្ហាលំបាកជាច្រើន មួយផ្នែកបណ្តាលមកពីបញ្ហាអភិបាលកិច្ច ហើយសកម្មភាពសេដ្ឋកិច្ច និង ទំនុកចិត្ត ក្នុងការធ្វើអាជីវកម្មកំពុងមានការធ្លាក់ចុះយ៉ាងខ្លាំង ។ ដោយមានការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះកំណែទំរង់សេដ្ឋកិច្ច និង ដំណោះស្រាយបញ្ហានយោបាយសំខាន់ៗក្នុងគោលបំណងបង្កើន ទស្សនៈវិស័យ ដើម្បីកំណើន និង កាត់បន្ថយភាពក្រីក្រ រដ្ឋាភិបាលបានអនុវត្តនូវដំណោះស្រាយបញ្ហាជាច្រើន ក្រោមការជួយជ្រោមជ្រែងពីមូលនិធិរូបិយវត្ថុអន្តរជាតិ ។ នៅក្នុងចំណោមអាទិភាពចំបងរបស់រដ្ឋាភិបាលនេះ គឺការរៀបចំប្រព័ន្ធហិរញ្ញវត្ថុឱ្យមានដំណើរការល្អ ដែលអាចជំរុញដល់ស្ថេរភាពនៃម៉ាក្រូសេដ្ឋកិច្ច និង ផ្នែកហិរញ្ញវត្ថុ ហើយធ្វើការទាក់ទាញលំហូរមូលធនអន្តរជាតិ ក្នុងទ្រង់ទ្រាយធំ និង មានស្ថេរភាពជាងមុន ។ ដើម្បីពង្រឹងការគ្រប់គ្រងធនាគារនៅនឹងកន្លែង និង ដើម្បីធ្វើការរៀបចំបទបញ្ញត្តិ ព្រមទាំងការអនុវត្តន៏ ការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព មូលនិធិរូបិយវត្ថុអន្តរជាតិបានផ្តល់នូវជំនួយបច្ចេកទេសច្រើនសន្ធឹកសន្ធាប់ ដល់ធនាគារកណ្តាលរបស់ ប៉ាពួរ នូហ្គីណេ ។ មូលនិធិរូបិយវត្ថុអន្តរជាតិ បានជួយអាជ្ញាធរប្រទេសនេះ ក្នុងការរៀបចំពង្រាងច្បាប់សំខាន់ៗ ច្បាប់ធនាគារកណ្តាល នៅឆ្នាំ ២000 ច្បាប់ធនាគារ និង ស្ថាប័ន ហិរញ្ញវត្ថុ ឆ្នាំ ២000 ហើយនិងច្បាប់ធានារ៉ាប់រងអាយុជីវិត និង សោធននិវត្តន៏ឆ្នាំ ២000 ដែលច្បាប់ទាំងនេះ ត្រូវបានរៀបចំឡើងក្នុងអំឡុងពេលចាប់ផ្តើមដំណើរការកំណែទំរង់។ ជាលទ្ធផលច្បាប់ទាំងនេះ បានជួយជំរុញបង្កើនសមត្ថភាព ធនាគារកណ្តាល ក្នុងការអនុវត្តន៏អនុសាសន៏ជាច្រើនរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ជាអាទិ៍ច្បាប់នេះ បានកំណត់ចំពោះការផ្តល់ប្រាក់កម្ចី ទៅឱ្យអ្នកខ្ចីប្រាក់ទោលនានា ជួយបង្កើតប្រព័ន្ធសវនកម្មផ្ទៃក្នុង ដែលមានលក្ខណៈម៉ត់ចត់ និង តំរូវការរបាយការណ៍ មានភាពជាក់លាក់ ច្បាប់ក៏រិតមូលធនអប្បរមាខ្ពស់ជាងមុន និង ក៏រិតគ្រប់គ្រាន់នៃមូលធន ដែលអនុលោមតាមបទដ្ឋាន បាស់ហ្សល (Basle) និង ការប្រើប្រាស់ក្របខ័ណ្ឌការងារអន្តរជាតិ សំរាប់ធ្វើការវាយតំលៃក៏រិតគ្រប់គ្រាន់នៃមូលធនរបស់ធនាគារ គុណភាពទ្រព្យសកម្ម ការគ្រប់គ្រង ការរកប្រាក់ចំណូល និង ក៏រិតសាច់ប្រាក់ក្នុងចរាចរ (Liquidity) ។

អនុវត្តតាមនិយាមអន្តរជាតិ ធនាគារកណ្តាលបានដាក់ឱ្យប្រើប្រព័ន្ធគ្រប់គ្រងម៉ត់ចត់ ចំពោះធនាគារក្រុមហ៊ុន ហិរញ្ញវត្ថុ និង ស្ថាប័នហិរញ្ញវត្ថុ ទាំងឡាយផ្សេងទៀត ។ លោក អ៊ីប្រីម៉ា ហ្វាអាល់ (Ebrima Faal) អ្នកតំណាងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំប៉ាពួរនូហ្គីណេ បានពន្យល់ថា "ការធ្វើបែបនេះអាចនាំឱ្យយើងធ្វើការគ្រប់គ្រងបានម៉ត់ចត់ចំពោះប្រាក់តំកល់របស់អ្នកផ្ញើ ការចូលរួមចំណែកផ្តល់មូលនិធិសោធននិវត្តន៏របស់សមាជិកនីមួយៗ និង ប្រាក់កំរៃ ពីគោលការណ៍ធានារ៉ាប់

រងអាយុជីវិត ដែលគ្រប់គ្រងដោយស្ថាប័នហិរញ្ញវត្ថុទាំងនេះ"។ គាត់ក៏បានបន្ថែមទៀតថា ការយកចិត្តទុកដាក់ឱ្យបានជិតដល់ លើអភិបាលកិច្ចល្អ និង ការវាយតំលៃដល់ជំនាញវិជ្ជាជីវៈរបស់អ្នកទាំងឡាយណាដែលធ្វើជានាយក និងជាអ្នកគ្រប់គ្រងស្ថាប័នហិរញ្ញវត្ថុទាំងនេះ ក៏ជាចំណុចសំខាន់មួយដែរ។

រហូតមកដល់ពេលនេះ កំណែទំរង់ទាំងឡាយបានទទួលជោគជ័យ។ បុគ្គលិកធនាគារកណ្តាល ដែលបានទទួលការបណ្តុះបណ្តាលពីអ្នកជំនាញការនៃជំនួយបច្ចេកទេស កំពុងតែបំពេញការងារត្រួតពិនិត្យនៅនឹងកន្លែងដោយខ្លួនឯង ។ សូចនាករមួយចំនួនបង្ហាញឱ្យឃើញថា ប្រព័ន្ធធនាគារនាពេលបច្ចុប្បន្នមានភាពរឹងមាំជាងមុន ។ ឧទាហរណ៍ជាក់ស្តែង ប្រាក់កម្ចីមិនដំណើរការ គិតជាភាគរយនៃប្រាក់កម្ចីសរុបបានធ្លាក់ចុះពី ៧,៣ ភាគរយ ក្នុងឆ្នាំ ២០០២ មកនៅត្រឹម ៣,៦ ភាគរយក្នុងឆ្នាំ ២០០៥ ។ ចំណូលពីទ្រព្យសកម្មបានប្រែក្លាយ ពីអវិជ្ជមាន ក្នុងឆ្នាំ ២០០២ កើនដល់ ៤,0 ភាគរយក្នុងឆ្នាំ ២០០៥។

លោក ហ្វាល (Faal) បានមានប្រសាសន៍ថា "ឥឡូវនេះបញ្ហាប្រឈមចំបងគឺការធានាឱ្យធនាគារកណ្តាលមាន សមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រង និងរក្សាបានមូលដ្ឋានសំរាប់ការគ្រប់គ្រង និងការកំណត់បទបញ្ញត្តិឱ្យបានតឹងរឹង បន្តទៀត" ។ ជំនួយបច្ចេកទេសបន្ត គឺ ផ្តោតជាសំខាន់លើវិស័យទាំងអស់នេះ។

## ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ : ប្រទេសកម្ពុជា

បញ្ហាប្រឈមចំបងបំផុតក្នុងចំណោមបញ្ហាប្រឈមនានា របស់ប្រទេសកម្ពុជា ចាប់តាំងពីប្រទេសនេះបានងើបចេញ ពីសង្គ្រាមស៊ីវិលប្រកបដោយវិនាសកម្ម និងភាពឯកោលើឆាកអន្តរជាតិ នៅក្នុងឆ្នាំ ១៩៩១ គឺការគៀងគរប្រមូលចំណូលសាធារណៈ ដើម្បីផ្តល់មូលនិធិដល់ការស្តារនិតិសម្បទា និង សេវាសាធារណៈជាមូលដ្ឋាន ហើយដើម្បីកែលំអការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីប្រើប្រាស់ប្រភពធនធានទាំងនេះប្រកបដោយប្រសិទ្ធភាព។ការផ្តល់ជំនួយបច្ចេកទេស រួមជាមួយការគាំទ្រផ្នែកហិរញ្ញវត្ថុ និង ការផ្តល់ប្រឹក្សាយោបល់ផ្នែកគោលនយោបាយរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ជាឧបករណ៍មួយក្នុងការជួយរដ្ឋាភិបាលប្រឈមនឹងបញ្ហាទាំងនេះ ។

ក្នុងខណៈដែលកម្ពុជាចាប់ផ្តើមការស្តារនិតិសម្បទា ប្រាក់ចំណូលសាធារណៈមានចំនួនតិចជាង ៥ ភាគរយនៃផលិតផលសរុបក្នុងស្រុកនៅឡើយ ការចំណាយសាធារណៈមានចំនួនទ្វេដងនៃចំណូលរបស់រដ្ឋ ហើយសមតុល្យចរន្តនៃថវិកា រដ្ឋាភិបាលគឺស្ថិតក្នុងឱនភាព ។ រដ្ឋាភិបាលបានចាប់ផ្តើមធ្វើកំណែទំរង់សារពើពន្ធ នៅក្នុងឆ្នាំ ១៩៩២ ។ ទោះជាយ៉ាងនេះក្តី គឺ មានតែឆ្នាំ ១៩៩៩ ប៉ុណ្ណោះ ដែលរដ្ឋាភិបាលអាចប្រមូលប្រាក់ចំណូលបានស្មើនឹង ១០ ភាគរយនៃផលិតផលសរុបក្នុងស្រុក គឺ ដោយសារការកំណត់ឱ្យប្រើច្បាប់ស្តីពីអាករលើតម្លៃបន្ថែម (VAT) ចំនួន ១០ ភាគរយ និង ការកែលំអរចនាសម្ព័ន្ធប្រមូលពន្ធ និង ការពង្រីកមូលដ្ឋានប្រមូលពន្ធថែមទៀត ។

កិច្ចខិតខំប្រឹងប្រែងនេះ ត្រូវបានពង្រឹងក្នុងឆ្នាំ ២០០១ ក្នុងពេលដែលរដ្ឋាភិបាលចាប់ផ្តើមធ្វើកំណែទំរង់ដើម្បីបង្កើន ប្រសិទ្ធភាពការគ្រប់គ្រងរដ្ឋបាលពន្ធដារ គយ និងរដ្ឋាករ ដែលស្ថិតក្រោមកម្មវិធីកិច្ចសហប្រតិបត្តិការបច្ចេកទេស (TCAP) របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។ កម្មវិធីនេះត្រូវបានរៀបចំឡើងរួមគ្នា ដោយអាជ្ញាធរកម្ពុជា មូលនិធិរូបិយវត្ថុអន្តរជាតិ និង ម្ចាស់ជំនួយផ្សេងទៀត ក្នុងគោលដៅលើកកំពស់សមត្ថភាពប្រតិបត្តិការរបស់ស្ថាប័នសំខាន់ៗក្នុងការប្រមូលប្រាក់ចំណូល និង លើកស្ទួយប្រសិទ្ធភាពចំណាយ និង ការគ្រប់គ្រងសាច់ប្រាក់ ។ ការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងចំណូលពន្ធគយ បានជួយធ្វើឱ្យប្រាក់ចំណូលមានការកើនឡើង លើសពី ១១ ភាគរយ នៃផលិតផលសរុបក្នុងស្រុក ក្នុងឆ្នាំ ២០០១ និង ឆ្នាំ ២០០២ ។ ទោះបីយ៉ាងនេះក្តី ផលធៀបនៃចំណូលទៅនឹងផលិតផលក្នុងស្រុក (Revenue to GDP ratio) គឺស្ថិតនៅកំរិត ទាបណាស់បើធៀបទៅនឹងនិយាមអន្តរជាតិនានា ហើយនៅពុំទាន់គ្រប់គ្រាន់សំរាប់ផ្តល់ហិរញ្ញប្បទានដល់ការកសាងហេដ្ឋារចនាសម្ព័ន្ធ អភិវឌ្ឍន៍ជនបទ និងបំពេញតំរូវការចំណាយខាងសង្គមកិច្ចផ្សេងៗ ។ ការប្រឈមមុខជាចំបង គឺបង្កើនចំណូលរដ្ឋាភិបាលថែមទៀត ។ មូលនិធិរូបិយវត្ថុអន្តរជាតិ បន្តផ្តល់អនុសាសន៍លើគោលនយោបាយនានា និង លើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ដើម្បីបង្កើនចំណូល និង បន្តផ្តល់ជំនួយបច្ចេកទេសផងដែរសំរាប់ពង្រឹងរដ្ឋបាលពន្ធដារ និង គយ ។

ម្យ៉ាងវិញទៀត គោលនយោបាយចំណាយសាធារណៈរបស់រដ្ឋាភិបាល បានកែលំអច្រើនផងដែរក្នុងរយៈពេលពីរ បីឆ្នាំកន្លងទៅនេះ ។ ការចំណាយត្រូវបានកែប្រែរចនាសម្ព័ន្ធសំរាប់វិស័យអាទិភាពនានា ដូចជាវិស័យកសិកម្ម អភិវឌ្ឍន៍ជនបទ សុខាភិបាល និង អប់រំ ទោះបីការចំណាយក្នុងវិស័យអប់រំ និង សុខាភិបាលស្ថិតនៅទាបជាងកំរិតមធ្យមនៃប្រទេសនានា ដែលស្ថិតក្នុងដំណាក់កាលអភិវឌ្ឍន៍ប្រហាក់ប្រហែលគ្នា ក៏ដោយ។ ទោះបីជាមានវឌ្ឍនភាពរហូតដល់ពេលនេះក្តី ប្រទេសកម្ពុជា នៅតែមានការប្រឈមយ៉ាងសន្ធឹកសន្ធាប់ក្នុងការប្រែក្លាយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យទៅជាប្រព័ន្ធមួយ ដែលមានសមត្ថភាពសំរាប់ផ្តល់សេវាសាធារណៈឱ្យសមល្មម ។ ប្រទេសកម្ពុជា បន្តទទួលជំនួយជាច្រើនពីមូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោក ដើម្បីគាំទ្រដល់កម្មវិធីអាទិភាពរបស់រដ្ឋាភិបាល ដើម្បីដោះស្រាយនូវភាពអន់ខ្សោយទាំងឡាយ ។

ការរីកចំរើនថ្មីៗ ក្នុងស្នាដៃគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងការគ្រប់គ្រងចំណាយសាធារណៈ (ដែលចាប់ផ្តើមពីកំរិតទាបបំផុត) បានជួយត្រួសត្រាយផ្លូវសំរាប់ការលុបចោល ១០០ភាគរយ នូវកាតព្វកិច្ចបំណុលរបស់ខ្លួន ចំពោះមូលនិធិរូបិយវត្ថុអន្តរជាតិ ក្រោមគំនិតផ្តួចផ្តើមលប់បំណុលពហុភាគី (MDRI) នៅក្នុងខែ មករា ឆ្នាំ ២០០៦ (សូម មើលទំព័រ ២៩) ។ លោក ចន នែលស៍ (John Nelmes) អ្នកតំណាងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំនៅកម្ពុជា បានពន្យល់ថា "កំណែទំរង់របស់ប្រទេសនេះនឹងជួយធានាថា ថវិកាបានពីគំនិតផ្តួចផ្តើមលប់បំណុលជាពហុភាគី (MDRI) នឹង ត្រូវបានគេយកទៅប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ។ រដ្ឋាភិបាលមានបំណងប្រើប្រាស់ប្រាក់សន្សំពីការសងបំណុលដែលមានប្រហែល ៨២ លានដុល្លាសហរដ្ឋអាមេរិក ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ដើម្បីធ្វើហិរញ្ញប្បទានដល់ការស្តារហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពនៅជនបទ ដែលអាចជួយបង្កើនផលិតកម្មកសិកម្ម និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដោយផ្ទាល់ ។

## ការរៀបចំផែនការសំរាប់អនាគត : ប្រទេសម៉ុងហ្គោលី

អ្នកធ្វើគោលនយោបាយនៅប្រទេសម៉ុងហ្គោលី បានប្រឈមមុខនឹងបញ្ហាច្រើនជំពូកតាំងពីដើមទសវត្សរ៍ឆ្នាំ៩០ នៅពេលដែលប្រទេសនេះឆ្លងកាត់អន្តរកាលឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារ ។ បន្ថែមទៅលើការបង្កើតច្បាប់ និង កសាងស្ថាប័ននានា ដែលនាំទៅរកការអភិវឌ្ឍន៍វិស័យឯកជនកន្លងមក អាជ្ញាធរត្រូវតែដោះស្រាយភាពទន់ខ្សោយចំបងៗនៅក្នុងប្រព័ន្ធធនាគារ និង ទប់ទល់នឹងវិបត្តិក្រៅស្រុកធំៗ រួមទាំងភាពរាំងស្ងួតដែលអូសបន្លាយ រដូវរងាដែលពិបាកទ្រាំទ្រជាបន្តបន្ទាប់ ហើយការប្រែប្រួលនៃថ្លៃទំនិញនាំចេញចំបងៗរបស់ប្រទេសម៉ុងហ្គោលី (ស្ពាន់ មាស និង ក្រណាត់រោមសត្វ) ។

ឆ្លងកាត់កំឡុងពេលនេះ មូលនិធិរូបិយវត្ថុអន្តរជាតិបានគាំទ្រដល់កិច្ចខំប្រឹងប្រែងកំណែទំរង់របស់អាជ្ញាធរ ដោយផ្តល់ កម្ចីតាមរយៈកម្មវិធីឥណទានសម្បទាននានា និងជំនួយបច្ចេកទេសជាច្រើន នៅក្នុងផ្នែកមួយចំនួនដូចជា ការកែប្រែរចនាសម្ព័ន្ធ វិស័យហិរញ្ញវត្ថុ គ្រប់គ្រងធនាគារ គោលនយោបាយ និង រដ្ឋបាលពន្ធដារ និង ស្ថិតិ ។

កំណែទម្រង់របស់រដ្ឋាភិបាល បានទទួលជោគជ័យធំធេងក្នុងការកាត់បន្ថយអតិផរណាពីអត្រាដែលមានកំរិតខ្ពស់ ពង្រឹងចំណូលថវិកា និង ស្តារទំនុកចិត្តនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ។ ទោះបីយ៉ាងនេះក្តី កំណើនសេដ្ឋកិច្ចជាទូទៅស្ថិតនៅកំរិតទាបក្នុងមួយទសវត្សរ៍រហូតដល់ឆ្នាំ ២០០១ ឱនភាពថវិកានៅមានច្រើនគួរឱ្យកត់សំគាល់ ហើយបំណុលសាធារណៈនៅតែបន្តកើនឡើង ។

កំឡុងពេលបន្ទាប់ពីឆ្នាំ ២០០១ បានបង្ហាញពីការរីកចំរើនគួរឱ្យកត់សំគាល់នៅក្នុងដំណើរការរបស់សេដ្ឋកិច្ច ដោយសារផលប្រយោជន៍ពីកំណែទំរង់ក្នុងទសវត្សរ៍ទី ៩០ ដែលចាប់ផ្តើមផ្តល់ផល លក្ខខណ្ឌអាកាសធាតុមានភាពប្រសើរឡើង ហើយថ្លៃទំនិញនាំចេញសំខាន់ៗរបស់ម៉ុងហ្គោលី បានកើនឡើងខ្ពស់ជាងមុនយ៉ាងលឿន ។ កំណើនផលិតផលក្នុងស្រុកសរុបតាម ថ្លៃពិត (Real GDP) បានកើនឡើងជាមធ្យម ៦,៥% ក្នុងមួយឆ្នាំៗ ចាប់តាំងពីឆ្នាំ ២០០២ ដែលកើនឡើងទ្វេដងធៀបនឹង អត្រាកំណើនជាមធ្យមក្នុងរយៈពេលប្រាំបីឆ្នាំមុនពេលនេះ ។ ជាមួយនឹងការងើបឡើងនៃសកម្មភាពសេដ្ឋកិច្ច និង ការកើនឡើងនៃថ្លៃទំនិញនាំចេញថវិកា និង ជញ្ជីងទូទាត់បានពង្រឹងខ្លាំងឡើងគួរឱ្យកត់សំគាល់ ។ ចំណូលថវិកា បានកើនឡើងគួរឱ្យចាប់អារម្មណ៍ ១៣ ភាគរយ នៃផលិតផលក្នុងស្រុកសរុប បើប្រៀបធៀបទៅនឹងពាក់កណ្តាលទសវត្សរ៍ឆ្នាំ ៩០ ។ ចំណែកឯឱនភាពថវិកាដែលមានឱនភាពជាមធ្យម ៩,៥% នៃផលិតផលក្នុងស្រុកសរុបនៅ ពាក់កណ្តាល ទី២ នៃទសវត្សរ៍ ឆ្នាំ ៩០ បានកត់ត្រានូវអតិរេក (Surplus) ដែលទើបតែមានលើកទីដំបូង (ប្រមាណ ៣% នៃផលិតផលក្នុងស្រុកសរុប) នៅក្នុងឆ្នាំ ២០០៥ ។ គណនីចរន្តវិស័យក្រៅស្រុកក៏មានអតិរេកចាប់តាំងពីឆ្នាំ ២០០៤ មក ហើយទុនបំរុងអន្តរជាតិ ក៏ចាប់ផ្តើមកើនឡើងច្រើនសន្ធឹកសន្ធាប់ ។



កម្មករដើរឆ្លងកាត់រោងចក្រ ដែលផលិតទង់ដែងសង្កត់នៅឯអណ្តូងរ៉ែរបស់រដ្ឋ នៅអ៊ុឌីណិត ប្រទេសម៉ុងហ្គូលី

Michael Reynolds/EPA/Landov

លោក រ៉ូជឺ ក្រូនិនប៊ឺក (Roger Kronenberg) ទីប្រឹក្សាមូលនិធិរូបិយវត្ថុអន្តរជាតិសំរាប់តំបន់អាស៊ីប៉ាស៊ីហ្វិក និង ជាប្រធានបេសកកម្មសំរាប់ ម៉ុងហ្គោលី បានប្រមាណថា ទោះបីមានការជោគជ័យដ៏ធំធេងនេះក្តី បញ្ហាប្រឈមចំបងៗ នៅត្រូវការដំណោះស្រាយ ប្រសិនបើប្រទេស ម៉ុងហ្គោលី មានបំណងកាត់បន្ថយភាពងាយរងគ្រោះ ដោយសារវិបត្តិពីខាងក្រៅ និង ភាពក្រីក្ររហូតទៅ ។ ដើម្បីរៀបចំផែនការ សំរាប់រយៈពេលវែងអ្នកធ្វើគោលនយោបាយ ត្រូវតែជួយសេដ្ឋកិច្ចឱ្យឃ្លាតឆ្ងាយពីវិបត្តិចំណូលដែលបណ្តាលមកពីការប្រែប្រួលថ្លៃនៃប្រភពធនធាន ។ លោក ក្រូនិនប៊ឺក (Kronen-berg) បាននិយាយថា "ទោះបីជាមានលក្ខខណ្ឌអនុគ្រោះនាពេលបច្ចុប្បន្ននេះក្តី វាមិនចាំបាច់យកការសន្មត់ដែលធំធេងណាស់ណាទេ ដើម្បីឱ្យឃើញថានិរន្តរភាពបំណុលនៅតែអាចជាបញ្ហា ។ ដូចនេះហើយគោលនយោបាយត្រូវតែចាក់គ្រឹះយ៉ាងមាំក្នុងក្របខ័ណ្ឌថវិការយៈពេលមធ្យម ដែលគួរឱ្យទុកចិត្តបានសំរាប់សំរេចបានជោគជ័យលើយុទ្ធសាស្ត្រនេះ" ។

បុគ្គលិករបស់មូលនិធិរូបិយវត្ថុអន្តរជាតិផ្តល់អនុសាសន៍ថា ប្រទេសម៉ុងហ្គោលីត្រូវសន្សំភាគច្រើននៃចំណូលដែលទទួលបានដ៏សន្ធឹកសន្ធាប់យ៉ាងឆាប់រហ័ស មកពីការកើនឡើងនៃថ្លៃទំនិញជាពិសេស និង ស្ថិតនៅក្នុងភាពប្រយ័ត្នពីហានិភ័យ នៃសម្ពាធអតិផរណាដែលបង្កឡើងដោយសារកំនើនឥណទានយ៉ាងឆាប់រហ័ស ហើយត្រូវទប់ស្កាត់នូវកម្ចីពីបរទេសមានលក្ខខណ្ឌពាណិជ្ជកម្មដែលមានការប្រាក់ថ្លៃ ។ មូលនិធិរូបិយវត្ថុអន្តរជាតិលើកទឹកចិត្តផងដែរដល់ប្រទេសម៉ុងហ្គោលី ក្នុងការបង្កើនតម្លាភាពរបស់ធនាគារកណ្តាល និង របស់ស្ថាប័នសាធារណៈដទៃទៀត និង បន្តកំណែទំរង់សេវាសាធារណៈ ។ លោក ក្រូនិនប៊ឹក (Kronenberg) បានឱ្យដឹងថា : កិច្ចពិភាក្សានានាជាមួយរដ្ឋាភិបាលប្រទេសម៉ុងហ្គោលី អំពីលទ្ធភាព នៃកម្មវិធីថ្មីមួយដែលអាចគាំទ្រដោយកម្មវិធីឥណទាន ដើម្បីកាត់បន្ថយភាពក្រីក្រ និង កំណើនរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ បានចាប់ផ្តើមឡើងនៅដើមឆ្នាំនេះ ហើយកិច្ចពិភាក្សាទាំងនេះរំពឹងថាបន្តនៅរដូវស្លឹកឈើជ្រុះ នៅពេលដែលអាជ្ញាធរ ចាប់ផ្តើមរៀបចំថវិកាឆ្នាំ ២០០៧ ។

## យុទ្ធសាស្ត្រផ្សេងៗគ្នា ដើម្បីគោលដៅដូចគ្នា

បញ្ហាប្រឈមផ្សេងៗ ដែលប្រទេសទាំងនេះកំពុងជួបប្រទះ និង យុទ្ធសាស្ត្រផ្សេងៗដែលប្រទេសទាំងនេះកំពុងអនុវត្តបង្ហាញឱ្យឃើញថា មានមាគ៌ាច្រើនសំរាប់ធ្វើឱ្យមានការរីកចំរើនប្រកបដោយនិរន្តរភាព និង សំរាប់ការកាត់បន្ថយភាពក្រីក្រ ។ ដោយយល់ដូច្នេះហើយ មូលនិធិរូបិយវត្ថុអន្តរជាតិ ក៏បានអនុវត្តនូវអភិក្រមទន់ភ្លន់ ប្រែប្រួលតាមកាលៈទេសៈក្នុងការផ្តល់ការគាំទ្រ ដល់កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ ។ ការផ្តល់ប្រឹក្សាសំរាប់រៀបចំគោលនយោបាយបានដំណើរការ តាមរយៈការត្រួតពិនិត្យសុខុមាលភាពរបស់ប្រទេសជាប្រចាំ ដែលគេឱ្យឈ្មោះថា "ការត្រួតពិនិត្យតាមដានឃ្លាំមើល" ។ ការផ្តល់ជំនួយហិរញ្ញវត្ថុ បានធ្វើឡើងតាមរយៈ ឧបករណ៍ឥណទាន ជាច្រើនប្រភេទ ។ ការផ្តល់ជំនួយបច្ចេកទេសបានជួយគាំទ្រដល់ការអភិវឌ្ឍន៍ស្ថាប័នម៉ាក្រូសេដ្ឋកិច្ចក្នុងវិស័យសំខាន់ៗ ដែលមានការប្រែប្រួលទៅតាមកាលៈទេសៈប្រទេសនីមួយៗ និង រួមទាំងការបង្កើតទីផ្សាររូបិយប័ណ្ណបរទេស ក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុ បទបញ្ញត្តិ និង ការគ្រប់គ្រងធនាគារ ប្រឆាំងនឹងការលាងលុយកខ្វក់ គោលនយោបាយ និង រដ្ឋបាលពន្ធដារការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងបំណុលក្រៅប្រទេស និង ស្ថិតិសេដ្ឋកិច្ច ។ ប្រទេសទាំងអស់នេះបានចាត់វិធានការសំរាប់ការកាត់បន្ថយភាពក្រីក្រ និង កំពុងតែមានវឌ្ឍនភាពឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្ស (សូមមើលទំព័រទី ២៩) ដូចជាការកាត់ បន្ថយអត្រាស្លាប់សំរាប់កុមារ និង ការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ និង ជំងឺផ្សេងៗទៀត ។ ប៉ុន្តែនៅមានកិច្ចការច្រើនទៀតដែលត្រូវធ្វើ ហើយមូលនិធិរូបិយវត្ថុអន្តរជាតិ បានត្រៀមខ្លួនជាស្រេចដើម្បីផ្តល់ជំនួយដល់កិច្ចខិតខំប្រឹងប្រែងទាំងនេះ ។ ■

Christine Ebrahim - Zadeh
នាយកដ្ឋានទំនាក់ទំនងផ្នែកខាងក្រៅ
នៃមូលនិធិរូបិយវត្ថុអន្តរជាតិ

## យុទ្ធសាស្ត្ររយៈពេលមធ្យមរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ

# ការបង្កើតមាគ៌ាថ្មីមួយ

មូលនិធិរូបិយវត្ថុអន្តរជាតិ បានរៀបចំនូវយុទ្ធសាស្ត្ររយៈពេលមធ្យមមួយ ដើម្បីជួយដោះស្រាយនូវបញ្ហាប្រឈមថ្មីៗ ចំពោះ សមាជិកទាំង ១៨៤ របស់ស្ថាប័ននេះ ជាពិសេសក្នុងខណៈដែលពួកគេកំពុងប្រយុទ្ធតទល់នឹងការកែតំរូវចាំបាច់ ដើម្បីច្បាមយកនូវអត្ថប្រយោជន៍នៃសកលភាវូបនីយកម្មក្នុងសតវត្សរ៍ទី ២១ នេះ ។

យុទ្ធសាស្ត្រនេះ គ្របដណ្តប់លើវិស័យសំខាន់ៗ នៃកិច្ចការរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ រួមមាន : ការត្រួតពិនិត្យតាមដានសេដ្ឋកិច្ចពិភពលោក សេដ្ឋកិច្ចតំបន់ និង សេដ្ឋកិច្ចជាតិ ការទប់ស្កាត់វិបត្តិសេដ្ឋកិច្ច និង ការផ្តល់ប្រាក់កម្ចី ជំនួយបច្ចេកទេស សំរាប់បណ្តាប្រទេសជាសមាជិក និង អភិបាលកិច្ចស្ថាប័នរួមទាំងសម្លេង និង ភាពជាតំណាងរបស់សមាជិក ។

នៅពេលចូលរួមជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ កាលពីខែ មិថុនា ឆ្នាំ ២០០៤ នាយកគ្រប់គ្រង លោក រ៉ូឌ្រីហ្គូ ឌឺរ៉ាតូ (Rodrigo de Rato) បានចាប់ផ្តើមការត្រួតពិនិត្យឡើងវិញជាយុទ្ធសាស្ត្រមួយ ដើម្បីពិចារណាធ្វើយ៉ាងណាធានាឱ្យមូលនិធិរូបិយវត្ថុអន្តរជាតិ បែងចែកធនធានរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និង ជានិច្ចជាកាលដើរបានមុនបញ្ហាប្រឈមថ្មីៗដែលកើតឡើង ។ របាយការណ៍ ដំបូងមួយត្រូវបានបោះផ្សាយកាលពីខែ កញ្ញា ឆ្នាំ ២០០៥ ដែលនាំឱ្យមានការជជែកពិភាក្សាយ៉ាងផុលផុសទាំងផ្ទៃក្នុង និង ជាសាធារណៈ អំពីតួនាទីសមស្របរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។ បានចេញផ្សាយបន្ទាប់មកទៀត កាលពីខែ មេសា ឆ្នាំ ២០០៦ គឺរបាយការណ៍មួយស្តីពីការអនុវត្តន៍អភិក្រមថ្មីនេះ ដែលត្រូវបានស្វាគមន៍ដោយគណៈកម្មាធិការបង្កើតគោលនយោបាយរូបិយវត្ថុអន្តរជាតិ និង ហិរញ្ញវត្ថុ នៃក្រុមប្រឹក្សាភិបាល។ សំណើកែប្រែសំខាន់ៗ នៅក្នុងការងាររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ រួមមានដូចខាងក្រោម:

***ការត្រួតពិនិត្យតាមដានសេដ្ឋកិច្ច:*** នៅកំរិតពិភពលោក ការត្រួតពិនិត្យតាមដានខ្លាំងជាងមុនរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ មានន័យថា ត្រូវធ្វើកិច្ចការច្រើនទៀតដើម្បីកំណត់ និង ជំរុញវិធានការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ចំពោះហានិភ័យផ្សេងៗ ដែលប៉ះពាល់ដល់ស្ថិរភាពសេដ្ឋកិច្ច រួមទាំងការពង្រីកវិសាលភាពលើការវាយតំលៃអត្រាប្តូរប្រាក់ ។ នៅកំរិតថ្នាក់ជាតិ ការត្រួតពិនិត្យតាមដានសេដ្ឋកិច្ចគប្បីត្រូវលើកកំពស់ផងដែរ តាមរយៈការវិភាគស៊ីជំរៅលើប្រព័ន្ធហិរញ្ញវត្ថុ ទស្សនៈវិស័យពិភពលោកមួយខ្លាំងជាងមុន ការគិតគូរលើបរិបទតំបន់ជាងមុន និង ទំនាក់ទំនងយ៉ាងសកម្មដើម្បីឈានទៅស្ថាបនាភាពយល់ស្របគ្នា រួមទាំងនៅកំរិតថ្នាក់តំបន់ ។

នៅក្នុងការវិវត្តន៍សំខាន់មួយ ក្នុងតួនាទីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិស្ថាប័ននេះក៏បានកសាងនូវយន្តការពិគ្រោះយោបល់ពហុភាគីថ្មីមួយ ។ ការពិគ្រោះយោបល់ទាំងនេះនឹងផ្តល់នូវមធ្យោបាយគន្លឹះសំរាប់ការវិភាគ និង ស្ថាបនានូវភាពយល់ស្របគ្នា ហើយផ្តល់លទ្ធភាពដល់មូលនិធិរូបិយវត្ថុអន្តរជាតិ និង ប្រទេសជាសមាជិកក្នុងការស្នើឡើងនូវចំណាត់ការផ្សេងៗ ដើម្បីដោះស្រាយភាពងាយរងគ្រោះដែលប៉ះពាល់ដល់សេដ្ឋកិច្ចរបស់ប្រទេសជាសមាជិកនីមួយៗ និង ប្រព័ន្ធហិរញ្ញវត្ថុពិភពលោក។ ការពិគ្រោះយោបល់របៀបនេះ លើកទីមួយ ទាក់ទងនឹងតុល្យភាពពិភពលោក កំពុងតែឋិតនៅក្នុងដំណើរការជាមួយនឹងប្រទេសចិន តំបន់អឺរ៉ុប ប្រទេសជប៉ុន សាវឌី អារ៉ាប់ប៊ី និងសហរដ្ឋអាមេរិក ។ ពិគ្រោះយោបល់ថ្មីៗបានបំពេញបន្ថែមលើការពិគ្រោះយោបល់



Stephan Jaffe/IMF

នាយកគ្រប់គ្រងរបស់ មូលនិធិរូបិយវត្ថុអន្តរជាតិ លោក រូឌ្រីហ្គូ ឌឺរ៉ាតូ (Rodrigo de Rato)

នានាដែលមានស្រាប់របស់មូលនិធិរូបិយវត្ថុអន្តរជាតិសំរាប់ប្រទេសនីមួយៗ ដែលអនុញ្ញាតឱ្យមូលនិធិរូបិយវត្ថុអន្តរជាតិ អាចចាប់យកបញ្ហាមកដោះស្រាយក្នុងពេលដំណាលគ្នា ជាមួយសមាជិកសំខាន់ក្នុងប្រព័ន្ធ និង ជាមួយស្ថាប័នបង្កើតឡើងដោយក្រុមប្រទេសជាសមាជិកដូចជា សហគមន៍អឺរ៉ុបជាដើម ។

***សេដ្ឋកិច្ចប្រទេសដែលមានទីផ្សារទើបតែងើបឡើង:*** មូលនិធិរូបិយវត្ថុអន្តរជាតិ មានផែនការពង្រីកការឱ្យខ្ចីរបស់ខ្លួន ដោយរាប់បញ្ចូលយន្តការមួយ សំរាប់បណ្តាប្រទេសដែលមានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចខ្លាំង បំណុលមានចីរភាព និង ប្រព័ន្ធរបាយការណ៍មានតម្លាភាព ប៉ុន្តែងាយរងវិបត្តិ ដោយផ្តល់ការគាំទ្រផ្នែកសាច់ប្រាក់មានលក្ខណៈងាយទទួលបានខ្ពស់ (High-access Contingent Liquidity Support) ។ ស្ថាប័ននេះ ជានិច្ចជាកាលតែងតែត្រៀមខ្លួនជាស្រេច ដើម្បីគាំទ្រយន្តការថ្នាក់តំបន់ និង យន្តការផ្សេងៗ ទៀតសំរាប់ការដាក់បញ្ចូលទុនបំរុងរួមគ្នា រាប់បញ្ចូលទាំងការផ្តល់សារគោលនយោបាយច្បាស់លាស់ ។

***បណ្តាប្រទេសមានចំណូលទាប:*** មូលនិធិរូបិយវត្ថុអន្តរជាតិ នឹងជួយបណ្តាប្រទេសទាំងនោះ ក្នុងការគ្រប់គ្រងបញ្ហាប្រឈមផ្នែកម៉ាក្រូសេដ្ឋកិច្ច ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ជាពិសេសជួយលើការបង្កើនជំនួយ និង ការគ្រប់គ្រងបំណុលនៅក្នុងសកម្មភាពផ្តល់ជំនួយលប់បំណុលនាវគ្គថ្មីៗនេះ ។ ដើម្បីសម្រេចគោលដៅនេះ មូលនិធិរូបិយវត្ថុអន្តរជាតិនឹងផ្តោត លើវិស័យសំខាន់ៗនៃសមត្ថកិច្ចជំនាញរបស់ខ្លួន ដោយបន្តពាក់ព័ន្ធក្នុងបញ្ហាអភិវឌ្ឍន៍ផ្សេងៗ ដែលប្រទេសទាំងនោះកំពុងប្រឈម ។ មូលនិធិរូបិយវត្ថុអន្តរជាតិនឹងពិនិត្យមើលដោយប្រុងប្រយ័ត្នថាតើត្រូវសហការជាមួយដៃគូរអភិវឌ្ឍន៍ផ្សេងទៀតយ៉ាងដូចម្តេច ជាពិសេសជាមួយធនាគារពិភពលោក នៅក្នុងការជួយដល់ប្រទេសនានា ដែលមានកំរិតចំណូលទាបជាសមាជិក ។

***របស់ប្រទេសតំណាង និង សម្លេង:*** អាទិភាពមួយទៀត គឺការកែតំរូវកូតាប្រទេសនានាជាសមាជិក និង តំណាងរបស់ប្រទេសទាំងនោះ នៅក្នុងអភិបាលកិច្ចរបស់ស្ថាប័ននេះ ដើម្បីឆ្លុះបញ្ចាំងការប្រែប្រួលពីទំងន់ និង តួនាទីនៅក្នុងសេដ្ឋកិច្ចពិភពលោក ។ ប្រការនេះ នឹងជំរុញស្មារតីនៃភាពជាម្ចាស់ និង ការចូលរួមរបស់សមាជិកនៅក្នុងមូលនិធិរូបិយវត្ថុអន្តរជាតិ ព្រមទាំងការពារភាពស្របច្បាប់របស់ខ្លួន ជាស្ថាប័នសហប្រតិបត្តិការមួយនៅក្នុងក្រសែភ្នែករបស់សមាជិកទាំងអស់ ។ ■

ការពិនិត្យទូទៅលើប្រវត្តិការងារ

# ព្រឹត្តិការណ៍ចំនួន ១០ ដែលជះឥទ្ធិពលដល់មូលនិធិរូបិយវត្ថុអន្តរជាតិ

**ដោយលោក James Boughton**


Bettman/Corbis


Dorothea Lange/Corbis


Archive Photos


Bettman/Corbis



Alain DeJean/Corbis

មូលនិធិរូបិយវត្ថុអន្តរជាតិ ត្រូវបានគេបង្កើតឡើងនៅពេលបញ្ចប់សង្គ្រាមលោកលើទី ២ ដែលជាផ្នែកមួយនៃការខំប្រឹងប្រែង ដើម្បីធ្វើការសាងសង់ប្រព័ន្ធសេដ្ឋកិច្ចអន្តរជាតិមួយថ្មីហើយមានស្ថេរភាពជាង និង ជៀសវាងកំហុសដែលធ្វើអោយមានការខាតបង់ដ៏ធ្ងន់ធ្ងរ ដូចកាលពីប៉ុន្មានទសវត្សរ៍កន្លងទៅ ។ ក្នុងរយះពេល ៦០ ឆ្នាំ មកនេះ មូលនិធិរូបិយវត្ថុអន្តរជាតិ បន្តធ្វើការផ្លាស់ប្តូរ និង កែសំរួលជាច្រើន។ ប៉ុន្តែចាប់តាំងពីការចាប់ផ្តើមរបស់ខ្លួនមក មូលនិធិរូបិយវត្ថុអន្តរជាតិ ត្រូវបានប្រែប្រួលរូបរាងដោយសារប្រវត្តិសាស្ត្រ និង ត្រូវបានយកទំរង់តាមទស្សនះសេដ្ឋកិច្ច និង នយោបាយនានានៅពេលនោះ ។

នៅពេលដែលប្រតិភូមកពីប្រទេសចំនួន ៤៤ បានជួបគ្នានៅ ប្រឺតុនវូត (Bretton Woods) រដ្ឋ ញូ ហេមស្សៀរ (New Hampshire) ក្នុងខែកក្កដា ឆ្នាំ ១៩៤៤ ដើម្បីបង្កើតស្ថាប័ននានាដើម្បីគ្រប់គ្រងទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិ ក្រោយពីសង្គ្រាមលោកលើកទី២នោះ ការជៀសវាងកុំអោយមានការបរាជ័យម្តងហើយម្តងទៀតចំពោះកិច្ចប្រជុំសន្តិភាពនាទីក្រុងប៉ារីស ដែលបានបញ្ចប់សង្គ្រាមលោកលើកទី ១ បានដិតជាប់ក្នុងចិត្តរបស់ពួកគេយ៉ាងខ្លាំង ។ ការបង្កើតធនាគារអន្តរជាតិសំរាប់ធ្វើការកសាងឡើងវិញ និង ការអភិវឌ្ឍន៏ នឹងជួយស្តារសកម្មភាពសេដ្ឋកិច្ច នៅខណះពេលដែលការបង្កើត មូលនិធិរូបិយវត្ថុអន្តរជាតិមួយ អាចជួយស្រោចស្រង់ការប្តូររូបិយប័ណ្ណ និង ការធ្វើពាណិជ្ជកម្មដោយពហុភាគី។ ចំពោះ ទាំងលោក ចន មេណា ខេនស៏ (John Maynard Keynes) សេដ្ឋកិច្ចវិទូដែលដឹកនាំប្រតិភូរបស់ចក្រភពអង់គ្លេស និង លោក ហារី ដិកស្ទ័រវៃ (Harry Dexter White) ប្រធានអ្នកពង្រាងនៃរចនាសម្ព័ន្ធមូលនិធិរូបិយវត្ថុអន្តរជាតិ សំរាប់ក្រុមប្រតិភូសហរដ្ឋអាមេរិក គោលការណ៏ជំរុញអោយមានការបង្កើតមូលនិធិរូបិយវត្ថុអន្តរជាតិ គឺការធ្វើអោយមានការរីកចំរើនផ្នែកសេដ្ឋកិច្ចពេលក្រោយសង្គ្រាម ដោយបង្កើតស្ថាប័នមួយដែលការពារមិនអោយមានការវិលត្រឡប់មកវិញនូវប្រព័ន្ធសេដ្ឋកិច្ចបិទ និង ប្រព័ន្ធសេដ្ឋកិច្ចគាំពារផលិតផលក្នុងស្រុក ដោយមិនគ្រាន់តែការពារមិនអោយមានការធ្លាក់ចុះដុនដាបខាងសេដ្ឋកិច្ចធំៗប៉ុណ្ណោះឡើយ ។

អត្ថបទនេះពិនិត្យមើលព្រឹត្តិការណ៏ចំបងមួយចំនួននៅក្នុងសតវត្សទី ២០ ដែលមានឥទ្ធិពលដ៏ធំធេងបំផុតលើមូលនិធិរូបិយវត្ថុអន្តរជាតិ និងធ្វើការសន្និដ្ឋានទូទៅអំពីកំលាំងរបស់ប្រវត្តិសាស្ត្រលើប្រព័ន្ធរូបិយវត្ថុអន្តរជាតិដែលរីកដុះដាល ក្នុងពេលបច្ចុប្បន្ននេះ។

## ១- កិច្ចប្រជុំសន្តិភាពទីក្រុងប៉ារីស

កិច្ចប្រជុំនាទីក្រុងប៉ារីសនាឆ្នាំ ១៩១៨ បានធ្វើការពិចារណាអំពីទស្សនវិស័យសំរាប់ស្តារភាពរីកចំរើន និង សន្តិភាពពិភពលោកឡើងវិញទៅតាមទំរង់នៃចំណុចទាំង ១៤ របស់លោកប្រធានាធិបតីសហរដ្ឋអាមេរិក វូដ្រូ វាលសុន (Woodrow Wilson)។ ប៉ុន្តែ




Mark Henley/Panos Pictures



Larry Burrows/Time Life Pictures/Getty Images




Toru Yamakana/AFP Photo



Choo Youn-Kong/AFP



Jacques Langevin/Corbis

នៅក្នុងរយៈពេល ៦ ខែក្រោយមកទៀត នៅពេលដែលប្រតិភូទាំងអស់បានយល់ព្រមចំពោះលក្ខខណ្ឌនានា ដែលបានទទួលស្គាល់ថា ជាសន្ធិសញ្ញាវ៉ែសៃ (Treaty of Versailles) នោះ ផ្នែកសំខាន់នានានៃទស្សនវិស័យនេះត្រូវបានគេលុបចោលវិញ។ ក្នុងកំឡុងមួយទសវត្សរ៍ ភាពចំរើនសំបូររុងរឿងត្រូវបាត់បង់។ ក្នុងមួយទសវត្សរ៍ទៀត សន្តិភាព ក៏ត្រូវបាត់បង់ផងដែរ។ ការបរាជ័យដ៏ល្បីល្បាញបំផុតនោះ គឺអសមត្ថភាពរបស់លោក វ៉ាលសុន (Wilson) ក្នុងការបញ្ចុះបញ្ចូលព្រឹទ្ធសភារបស់សហរដ្ឋអាមេរិក អោយអនុម័តសមាជិកភាពរបស់សហរដ្ឋអាមេរិកចូលទៅក្នុងសម្ព័ន្ធប្រជាជាតិ ។ ទោះបីយ៉ាងនេះក្តីភាពបរាជ័យបំផុតនោះ អាចនិយាយបានថា ជាការបរាជ័យក្នុងការដាក់ចេញការងារជាមូលដ្ឋានដើម្បីសហប្រតិបត្តិការសេដ្ឋកិច្ច ក្នុងចំណោមប្រទេសដែលមានទំហំពាណិជ្ជកម្មធំៗមួយចំនួននៅក្នុងពិភពលោក។

## ២- វិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរ (The Great Depression)

វិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរដែលបានចាប់ផ្តើមនៅឆ្នាំ ១៩២៩ បានពង្រីកផលអវិជ្ជមាននៃសន្ធិសញ្ញាវ៉ែសៃកាន់តែខ្លាំងឡើង ដោយសារការដួលរលំនៃពាណិជ្ជកម្មអន្តរជាតិ ដែលបានជួបនឹងកំហុសឆ្គងនៃគោលនយោបាយក្នុងប្រទេស បានធ្វើអោយចុះខ្សោយផលិតកម្ម និង ថ្លៃជុំវិញពិភពលោក។ វិបត្តិនេះ បានសាកល្បងទំនុកចិត្តរបស់អ្នកវិភាគ និង អ្នកបោះឆ្នោតចំពោះ ប្រសិទ្ធភាពទីផ្សារសេរី និង បានពង្រឹងជំនឿលើតួនាទីជាសកម្មជនមួយរបស់វិស័យសាធារណៈក្នុងភាពរស់រាននៃសេដ្ឋកិច្ច ។ ដូចនេះ វាមានភាពកាន់តែងាយស្រួល និង មានលក្ខណៈកាន់តែសាមញ្ញក្នុងការចាប់ផ្តើមធ្វើការពិភាក្សានានាអំពីក្របខ័ណ្ឌ ការងារពេលក្រោយសង្គ្រាមលោកលើកទី ២ អំពីការសន្មត់ដែលថាភ្នាក់ងារអន្តររដ្ឋាភិបាលជាមួយអំណាចដ៏ក្រាសក្រែលនោះ នឹងផ្តល់ផលប្រយោជន៍ និងអាចថាជាការចាំបាច់ផងដែរសំរាប់ប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិ។

## ៣- សង្គ្រាមលោកលើកទី ២

សង្គ្រាមលោកលើកទី ២ បានផ្តល់ទាំងសន្ទុះ និង បរិបទសំរាប់ធ្វើកំណែទំរង់ប្រព័ន្ធអន្តរជាតិ។ នៅពេលដែលសហរដ្ឋអាមេរិក បានចូលរួមធ្វើសង្គ្រាមតបតទៅនឹងការទំលាក់គ្រាប់បែកដាក់កំពង់ផែភើរល (Pearl Harbor) ក្នុងខែ ធ្នូ ឆ្នាំ ១៩៤១ លោក ហិនរី ម័រហ្គិនថូ យូញ័រ (Henry Morgenthau, Jr.) ដែលជារដ្ឋមន្ត្រីនៃរតនាគារបានដាក់លោក វ៉ៃ (White) អោយធ្វើការទទួលខុសត្រូវលើគោលនយោបាយហិរញ្ញវត្ថុ និង សេដ្ឋកិច្ចអន្តរជាតិ ហើយបានសុំអោយរូបលោកធ្វើគំរោងសំរាប់រៀបចំប្រព័ន្ធសារជាថ្មីឡើងវិញនៅពេលដែលសង្គ្រាមបានបញ្ចប់។ ដូចដែលវាបានកើតឡើង លោក វ៉ៃ (White) បានធ្វើសេចក្តីព្រាងនូវគំរោងការសំរាប់ធ្វើអោយមានមូលនិធិស្ថេរភាពអន្តរជាតិ រួចរាល់ហើយ ហើយគាត់អាចធ្វើសេចក្តីព្រាងដំបូងក្នុងរយៈពេលតែពីរបីខែប៉ុណ្ណោះ។ នៅផ្នែកម្ខាងទៀតនៃមហាសមុទ្រអាត្លង់ទិក លោក ខេនស៍ (Keynes) បានធ្វើការបង្កើតគំរោងការមួយសំរាប់សហគមន៍ទូទាត់អន្តរជាតិ ដែលត្រូវគ្រប់គ្រងរួមគ្នាដោយចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ដែលជា "រដ្ឋស្ថាបនិក" ។ ទោះជាវាមិនមានលក្ខណៈពហុភាគីយ៉ាងច្បាស់ដូចគំរោងរបស់លោក វ៉ៃ (White) ហើយដោយផ្អែកលើប្រព័ន្ធឥណទាន (អាចខ្ចីលើសប្រាក់បញ្ញើ) របស់ចក្រភពអង់គ្លេស ជាជាងការលើកគំរោងសំណើ ស្មុគ្រស្មាញអំពីការដោះដូររូបិយវត្ថុរបស់ លោក វ៉ៃ (White) ក៏ដោយ គំរោងរបស់លោក ខេនស៍ (Keynes) ក៏មានចំណុចស្រដៀងគ្នាលើចំណុចសំខាន់ៗទៅនឹងគំរោងរបស់លោក វ៉ៃ (White) ដែរ ។ ពីរឆ្នាំក្រោយពីការធ្វើកិច្ចពិភាក្សា និង ការចចារគ្នារួចមក គំរោងទាំងពីរនេះ ត្រូវបានគេដាក់រួមបញ្ចូលគ្នាសំរាប់ធ្វើជាលក្ខន្តិកៈរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។

ផលប៉ះពាល់ដ៏ធំបំផុតនៃសង្គ្រាមគឺថា វាបានទុកសហរដ្ឋអាមេរិកអោយត្រួតត្រាលើសេដ្ឋកិច្ចពិភពលោកយ៉ាងពិតប្រាកដ។ រចនាសម្ព័ន្ធហិរញ្ញវត្ថុរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ នឹងយកប្រាក់ដុល្លាសហរដ្ឋអាមេរិកជាមូលដ្ឋាន ជាជាងការបង្កើតរូបិយវត្ថុអន្តរជាតិមួយដោយខ្លួនឯង ។ អំណាចក្នុងការអោយខ្ចីប្រាក់របស់ខ្លួនមានកំរិតកំណត់ ហើយមូលនិធិរូបិយវត្ថុអន្តរជាតិ នឹងខ្វះខាតអំណាចជាធនាគារកណ្តាលច្រើនបំផុត។ ការិយាល័យស្នាក់ការរបស់ខ្លួននេះ មិនមែនស្ថិតក្នុងទីក្រុងឡុងដ៏ ឬ នៅក្រុងញូវយ៉កឡើយ គឺនៅទីក្រុងវ៉ាស៊ីនតោន ដែលរតនាគារសហរដ្ឋអាមេរិកអាចប្រើកំលាំងទាញយ៉ាងខ្លាំង។ ក្នុងរយៈពេល ៣ ទសវត្សរ៍ក្រោយមកទៀត មូលនិធិរូបិយវត្ថុអន្តរជាតិ បានក្លាយទៅជាស្ថាប័នប្រើប្រាស់ ដុល្លា ដោយមានសហរដ្ឋអាមេរិកជាអ្នក

ផ្តល់ប្រភពធនធានកំចីច្រើនជាងគេ និង គ្រប់គ្រងភាគច្រើនលើសលប់ លើការសំរេចចិត្តផ្តល់ប្រាក់កំចី។

**៤-សង្គ្រាមត្រជាក់**



លោក ហារី ដិតស្ទ័រវៃ (Harry Dexter White) បានខិតខំធ្វើការយ៉ាងខ្លាំងនៅក្នុង ឆ្នាំ ១៩៤៤ ដើម្បីធ្វើការបញ្ចុះបញ្ចូលសហភាពសូវៀត អោយចូលរួមជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ ដោយជឿជាក់ថា កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងសហភាពសូវៀត និង សហរដ្ឋអាមេរិកអាចជាកត្តាដ៏សំខាន់ក្នុងការរក្សាសន្តិភាព និង ភាពរុងរឿងបន្ទាប់ពីសង្គ្រាម។ ប្រតិភូសហភាពសូវៀតទៅកាន់ ប្រ៊ីតុន វ៊ូត (Bretton Woods) បានចុះហត្ថលេខាលើមាត្រានានា នៃកិច្ចព្រមព្រៀងបណ្តោះអាសន្ន (Ad referendum) ប៉ុន្តែ នៅទីបញ្ចប់លោក ហ្សូសេប ស្តាលីន (Joseph Stalin) បានបដិសេធនឹមិនព្រមផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងនោះទេ ប្រហែលជាដោយសារគាត់មានការភ័យខ្លាច (មិនមែន មិនមានការបង្ហាញហេតុផល) ដែលថាគោលនយោបាយរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ នឹងត្រូវបានគ្រប់គ្រងដោយប្រទេសលោកខាងលិច ។ នៅពេលដែលភាពតានតឹងនោះ បានឈានចូលទៅក្នុងសង្គ្រាមត្រជាក់ ទស្សនៈរបស់លោក វៃ (White) ចំពោះសមាជិកភាពជាសកលត្រូវបានជាប់គាំង។ ប្រទេសប៉ូឡូញ បានដកសមាជិកភាពរបស់ខ្លួនចេញក្នុងឆ្នាំ ១៩៥០។ បួនឆ្នាំក្រោយមកទៀត ប្រទេសឆេកូស្លូវ៉ាគី ត្រូវគេបង្ខំអោយដកសមាជិកភាពចេញ ។ ភ្លាមៗបន្ទាប់ពីការកាន់អំណាចនៅក្នុងឆ្នាំ ១៩៥៩ លោក ហ្វីដែល កាស្ត្រូ (Fidel Castro) បានដកប្រទេសគុយបាចេញទៀត។ ក្នុងរយៈពេលលើសពី ៣ ទសវត្សរ៍បន្ទាប់ពី លោក ម៉ៅ សេទុង ដណ្តើមអំណាចគ្រប់គ្រងប្រទេសចិនបាន រដ្ឋាភិបាលរបស់សហរដ្ឋអាមេរិកបានរាំងខ្ទប់កិច្ចខិតខំប្រឹងប្រែងរបស់សាធារណៈរដ្ឋប្រជាមានិតនេះ មិនអោយមកអង្គុយជាតំណាងរបស់ប្រទេសចិនខ្លួនឯងនៅក្នុងគណៈកម្មការប្រតិបត្តិរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។ ប្រទេសផ្សេងៗទៀតនៅរង្វង់ឥទ្ធិពលរបស់ក្រុមសហភាពសូវៀត ឬ ប្រទេសចិនមិនបានចូលរួមឡើយ។ រហូតដល់ទសវត្សរ៍ ឆ្នាំ ១៩៨០ ទើបនិន្នាការនោះមានភាពផ្ទុយគ្នាទៅវិញដោយការផ្តល់កៅអីអោយទៅប្រទេសចិន និង ផ្តល់សមាជិកភាពសាជាថ្មីដល់ប្រទេសប៉ូឡូញ ។ ឥទ្ធិពលដ៏ខ្លាំងក្លាបំផុតសំរាប់សង្គ្រាមត្រជាក់ចំពោះមូលនិធិរូបិយវត្ថុអន្តរជាតិ គឺការរឹតត្បិតនៃសមាជិកភាព។ ការប្រើពាក្យស័ព្ទនៅសម័យនោះ មូលនិធិរូបិយវត្ថុអន្តរជាតិមានរាប់បញ្ចូលលោកទី ១ និងភាគច្រើននៃលោកទី ៣ (តតិយលោក) ប៉ុន្តែលោកទី ២ បានអវត្តមានពីសមាជិកភាព។ មូលនិធិរូបិយវត្ថុអន្តរជាតិបានក្លាយជាក្រុមមូលធននិយមមួយយ៉ាងធំ សំរាប់ជួយធ្វើអោយមានស្ថេរភាពសេដ្ឋកិច្ចអាស្រ័យទីផ្សារ។

**៥- ឯករាជ្យរបស់ប្រទេសអាហ្វ្រិក**



ក្នុងចំណោមប្រទេសសមាជិកដើម របស់មូលនិធិរូបិយវត្ថុអន្តរជាតិទាំង ៤០ មានតែប្រទេសចំនួន ៣ ដែលមកពីទ្វីបអាហ្វ្រិកគឺ : អេត្យូពី អេហ្ស៊ីប និង អាហ្វ្រិកខាងត្បូង។ ក្នុងចំណោមប្រទេសទាំងអស់នោះ មានប្រទេសមួយដែលទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធទៅនឹងប្រទេសមជ្ឈឹមបូពា និង ប្រទេសមួយទៀតគ្រប់គ្រងដោយជនជាតិភាគតិច និង មានចំណងទាក់ទងជាមួយអឺរ៉ុបដោយវប្បធម៌ ។ ភាគច្រើនលើសលប់នៃទ្វីបអាហ្វ្រិកស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាណានិគមនៅឡើយ ។ ស្ថានភាពបែបនេះបានចាប់ផ្តើមប្រែប្រួលក្នុងឆ្នាំ ១៩៥៧ នៅពេលដែលប្រទេសដែលទើបទទួលបានឯករាជ្យថ្មីៗ ដូចជា ហ្គាណា និង ស៊ូដង់ បានក្លាយជាសមាជិករបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។ ក្រោយមកមានការដាក់ពាក្យសុំចូលជាសមាជិកជាច្រើន ហើយនៅឆ្នាំ ១៩៦៩ មានសមាជិក ៤៤ ប្រទេស ក្នុងចំណោមសមាជិកទាំង១១៥ មកពីទ្វីបអាហ្វ្រិក។ នៅឆ្នាំ ១៩៩០ ប្រទេសទាំង ៥៣ ដែលនៅក្នុងទ្វីបអាហ្វ្រិកបានចូលជាសមាជិករបស់មូលនិធិរូបិយវត្ថុអន្តរជាតិ។ ប្រទេសទាំងអស់នេះមានចំនួនប្រហែលជាមួយភាគបីនៃប្រទេសសមាជិកទាំងអស់ ទោះជាប្រទេសទាំងអស់នេះ មានទំហំផ្ទៃក្រលាដីតូចជាមធ្យម និង ជាប្រទេសដែលបានមានកំរិតប្រាក់ចំណូលទាបដែលមានន័យថា ប្រទេសទាំងអស់គ្រប់គ្រងតិចជាង ៩ ភាគរយនៃអំណាចការនៃការបោះឆ្នោត ហើយកាន់កាប់កៅអីចំនួនត្រឹមតែ ៣ ប៉ុណ្ណោះ ក្នុងចំណោមកៅអីគណៈកម្មការប្រតិបត្តិទាំង ២២ កៅអី។

ការងើបឡើងរបស់ទ្វីបអាហ្វ្រិក ជាទ្វីបមួយដែលមានប្រទេសឯករាជ្យនានា មានឥទ្ធិពលដ៏ចំបងមួយទៅលើទំហំ និង ភាពសំបូរបែបនៃមូលនិធិរូបិយវត្ថុអន្តរជាតិ ហើយវាត្រូវអោយមានភាពខ្លាំងក្លាយ៉ាងក្រាសក្រែលចំពោះការជំពាក់វ៉ាក់វិន របស់មូលនិធិរូបិយវត្ថុអន្តរជាតិជាមួយនឹងការត្រួតពិនិត្យលើអ្នកសុំខ្ចីប្រាក់នានា ។ ភាគច្រើននៃប្រទេសទាំងនេះ ជាពិសេសប្រទេសក្នុងអនុតំបន់វាលខ្សាច់អាហ្វ្រិកសាហារា ជាប្រទេសដែលមានប្រាក់ចំណូលក្នុងប្រជាជនម្នាក់ៗទាប ហើយជាប្រទេស ដែលស្ថិតក្នុងចំណោមប្រទេសដែលមានការអភិវឌ្ឍន៍ សេដ្ឋកិច្ចកំរិតទាបបំផុតនៅក្នុងពិភពលោក ជារូបភាពមួយដែលនៅមាននៅឡើយ។ បញ្ហាផ្នែកសេដ្ឋកិច្ចរបស់ប្រទេសទាំងនេះ មានទំនោរទៅរកបញ្ហារចនាសម្ព័ន្ធ ច្រើនជាងបញ្ហាម៉ាក្រូសេដ្ឋកិច្ច ដែលបានចាក់ឫស ក្នុងតំរូវការនៃការអភិវឌ្ឍលើវិស័យអប់រំ ការថែទាំសុខភាព ការស្តារហេដ្ឋារចនាសម្ព័ន្ធ និង អភិបាលកិច្ច ច្រើនជាងលើផ្នែកហិរញ្ញវត្ថុ ហើយមានភាពកប់ជ្រៅ និង ជាប់ស្អិតជាងប្រទេសនៅក្នុងតំបន់ផ្សេងទៀត។ ការដោះស្រាយ បញ្ហាទាំងអស់នេះតំរូវអោយមានការផ្តល់ប្រាក់កំចីក្នុងលក្ខខណ្ឌសម្បទាន និង ជំនាញការបច្ចេកទេសជាច្រើន ។ ហេតុដូចនេះហើយតួនាទីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ បានពង្រីកហួសពីព្រំដែនដើម ហើយ កិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយធនាគារពិភពលោក និង ភ្នាក់ងារអភិវឌ្ឍន៍ផ្សេងៗទៀតក្លាយទៅជាភាពខានមិនបាន។

**៦- ការលេចឡើងនូវពហុមណ្ឌលសេដ្ឋកិច្ចនានា**



ក្នុងខណៈដែលសេដ្ឋកិច្ចពិភពលោក និង ពាណិជ្ជកម្មពិភពលោកចាប់ផ្តើមស្តារឡើងវិញបន្ទាប់ពីសង្គ្រាមលោក លើកទី ២ នុត្តរភាពសេដ្ឋកិច្ច (Economic Hegemony) របស់សហរដ្ឋអាមេរិកមានការថយចុះបន្តិចម្តងៗ ។ អ្នកទី ១ ដែលងើបពីផេះ (សង្គ្រាម) គឺ ប្រទេសនៅក្នុងអឺរ៉ុបខាងលិច ។ តាមរយៈនៃការបញ្ចូលរួមគ្នាមួយនៃការខិតខំប្រឹងប្រែងជាលក្ខណៈជាតិ និង ការគាំទ្រអន្តរជាតិ--ពីសហរដ្ឋអាមេរិក ក្រោមផែនការចាប់បង្ហំ (Marshall plan) អំពីធនាគារពិភពលោក ចុងបំផុតមូលធិនិរូបិយវត្ថុអន្តរជាតិ--និង អំពីការរីកចំរើនក្នុងស្រុកនៃកិច្ចសហការពហុភាគីនិយមក្នុងលំនាំទីផ្សាររួមហើយ និង សហភាពទូទាត់អឺរ៉ុប ប្រទេសភាគច្រើននៅក្នុងអឺរ៉ុប បានរីកដុះដាលយ៉ាងឆាប់រហ័ស និង មានការបើកចំហសំរាប់ពាណិជ្ជកម្ម ពហុភាគី និង ការប្តូររូបិយប័ណ្ណ នៅចុងទសវត្សរ៍ឆ្នាំ ១៩៥០។ សាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ បានចូលជាសមាជិកមូលធិនិរូបិយវត្ថុអន្តរជាតិនៅឆ្នាំ ១៩៥២ ហើយបានក្លាយជាប្រទេសអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចឈានមុខគេមួយយ៉ាងឆាប់រហ័ស ។ បន្ទាប់មកមានប្រទេសក្នុងតំបន់អាស៊ី ។ ប្រទេសជប៉ុនក៏បានចូលរួមជាមូលធិនិរូបិយវត្ថុអន្តរជាតិ នៅឆ្នាំ

១៩៥២ ហើយនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ប្រទេសនេះ បានកំពុងធ្វើដំណើរទៅចូលរួមជាមួយសហរដ្ឋអាមេរិក និង អាល្លឺម៉ង់នៅលើលំដាប់ខ្ពស់ជាងគេ ក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ច ។ បន្ទាប់មកនៅទសវត្សរ៍ ឆ្នាំ ១៩៧០ គេឃើញមានការងើបឡើងនៃអំណាចសេដ្ឋកិច្ចរបស់ប្រទេសអារ៉ាប់ប៊ីសាអូឌីត និង ប្រទេសដែលនាំប្រេងចេញជាច្រើនទៀតក្នុងតំបន់មជ្ឈឹមបូពា ។ ក្នុងរយៈពេល ៣០ ឆ្នាំក្រោយមកទំហំនៃការនាំចេញរបស់សហរដ្ឋអាមេរិកក្នុងការនាំចេញពិភពលោកបានធ្លាក់ចុះពី ២២ ភាគរយមក ១២ ភាគរយ ចំណែកឯទំហំនៃធនធានបំរុងផ្លូវការអន្តរជាតិរបស់សហរដ្ឋអាមេរិកវិញក៏មានការធ្លាក់ចុះយ៉ាងឆាប់រហ័សពី ៥៤ ភាគរយ ក្នុងឆ្នាំ ១៩៤៨ មក ១២ ភាគរយ ក្នុងឆ្នាំ ១៩៧៨។

នៅពេលដែលតុល្យការអំណាចសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានភាពកាន់តែបែកខ្ញែកទៅមានរូបិយប័ណ្ណកាន់តែច្រើន ដែលអាចធ្វើការដោះដូរដោយពេញលេញសំរាប់គណនេយ្យចរន្ត និង រួមទាំងប្រតិបត្តិការមូលធននានា ។ ដៃគូពាណិជ្ជកម្មនានាមានភាពរីកដុះដាលក្នុងកំរិតខុសៗគ្នា និងមានគោលនយោបាយហិរញ្ញវត្ថុចំរុះគ្នា។ សម្ពាធលើអត្រាប្តូរប្រាក់ថេរ និង លើភាពមានកំណត់នៃការផ្គត់ផ្គង់មាស និង ដុល្លាសហរដ្ឋអាមេរិកកាន់តែកើតឡើងជាញឹកញាប់ និង មានភាពកាន់តែធ្ងន់ធ្ងរឡើងៗ ។ នៅក្នុងឆ្នាំ ១៩៦៩ មូលធិនិរូបិយវត្ថុអន្តរជាតិបានឆ្លើយតបទៅលើបញ្ហានេះ ដោយធ្វើវិសោធនកម្មអាត្រាមួយចំនួនរបស់ខ្លួន និង បង្កើតសិទ្ធិដកប្រាក់ពិសេស (SDRs) ដើម្បីបំពេញបង្គ្រប់ទ្រព្យធនបំរុងដែលមានស្រាប់ ប៉ុន្តែសកម្មភាពបែបនេះ នៅមានកំរិតណាស់ ក្នុងការដោះស្រាយបញ្ហាដែលកើតមកពី សម្ពាធផ្សេងៗគ្នា។ ហេតុដូចនេះហើយ សូម្បីតែនៅមុនពេលមានវិបត្តិប្រេងលើកទី ១ នៅក្នុងឆ្នាំ ១៩៧៣ ប្រព័ន្ធ ដើមនៃប្រ៊ឺតុន វ៉ូត (Bretton Woods) ដែលកំណត់អត្រាប្តូរប្រាក់ថេរ តែអាចកែតំរូវបានក្លាយទៅជាមិនអាចធ្វើទៅកើត ។

## ៧ – សង្គ្រាមនៅប្រទេសវៀតណាម



ការកើនឡើងកាន់តែខ្លាំង នៃការប្រលូកចូលនៃសហរដ្ឋអាមេរិក ក្នុងសង្គ្រាមវៀតណាម ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ និង នៅដើមទសវត្សរ៍ ឆ្នាំ១៩៧០ ពុំផ្តល់ផលប៉ះពាល់ក្រាស់ក្រែលដល់មូលនិធិរូបិយប័ណ្ណអន្តជាតិឡើយ ក្រៅពីផលប៉ះពាល់ផ្ទាល់ដល់សមាជិកភាពរបស់ប្រទេសវៀតណាម។ នៅពេលដែលរដ្ឋាភិបាលរបស់វៀតណាមខាងត្បូង ជិតបរាជ័យនៅខែ មេសា ឆ្នាំ ១៩៧៥ មន្ត្រីនានារបស់ប្រទេសនេះ បានព្យាយាមខ្ចីប្រាក់យ៉ាងច្រើនបំផុតពីមូលនិធិរូបិយវត្ថុអន្តរជាតិ ។ មូលនិធិរូបិយវត្ថុអន្តរជាតិ បានបដិសេធន៍ ហើយក្នុងរយៈពេលតែពីរបីខែក្រោយមក មូលនិធិរូបិយវត្ថុអន្តរជាតិបានទទួលស្គាល់សាធារណៈរដ្ឋសង្គមនិយមវៀតណាមថា ជារដ្ឋាភិបាលបន្តតំណែង។ ទោះជាយ៉ាងណាក៏ដោយ ផលប៉ះពាល់ដ៏ធំ គឺ ទៅលើសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក និង តួនាទីក្នុងការទូទាត់វិស័យក្រៅប្រទេសរបស់ប្រទេសនេះ ។ រួមផ្សំជាមួយការចំណាយច្រើនក្នុងស្រុកសំរាប់កម្មវិធីសង្គមដ៏ធំរបស់លោកប្រធានាធិបតី លីនដុង ចនសាន់ (Lyndon Johnson) ការតំឡើង ការចំណាយសំរាប់កិច្ចការយោធាខាងក្រៅប្រទេសកាន់តែផ្តល់ផលអាក្រក់ជាបណ្តើរដល់តំលៃប្រាក់ដុល្លា ដែលកំពុងតែមានតំលៃខ្ពស់ជាងតំលៃពិត ស្ថិតនៅក្រោមអត្រាប្តូរប្រាក់ថេរកំណត់ដោយប្រព័ន្ធ ប្រ៊ឺតុនវ៉ូត (Bretton Woods)។ ដោយមានភាពបរាជ័យជាបន្តបន្ទាប់គ្នា ប្រព័ន្ធនេះត្រូវបានគេរំលាយចោលនៅចន្លោះឆ្នាំ ១៩៦៨ និង ឆ្នាំ ១៩៧៣។ ដោយប្រាក់ដុល្លា មិនអាចធ្វើការដោះដូរជាមាសបានទៀតនោះ លោហធាតុមានតំលៃលែងមានតួនាទីសំខាន់ឬក៏សឹងតែគ្មានមុខងារដ៏មានសារៈប្រយោជន៏ នៅក្នុងប្រព័ន្ធរូបិយវត្ថុអន្តរជាតិ ។ ទោះជាយ៉ាងណាសង្គ្រាមនៅប្រទេសវៀតណាម មិនមែនជាបញ្ហាតែមួយគត់ ដែលធ្វើអោយមានការធ្លាក់ចុះនេះ ប៉ុន្តែតួនាទីជាកត្តាលីកររបស់វា ពិតជាមានកំរិតចំបងមួយដែរ ។

## ៨ – សកលភាវូបនីយ៍កម្មទីផ្សារហិរញ្ញវត្ថុ




លំហូរហិរញ្ញវត្ថុវិស័យឯកជនស្ថិតក្នុងទំហំ និង សារៈសំខាន់ដែលនៅមានកំរិត នៅពេលដែលមូលនិធិរូបិយវត្ថុអន្តរជាតិត្រូវបានបង្កើតឡើង ។ លំហូរពាណិជ្ជកម្ម ត្រូវបានផ្គត់ផ្គង់ហិរញ្ញប្បទាន ភាគច្រើនដោយឥណទានពាណិជ្ជកម្ម ហើយសេដ្ឋកិច្ចវិទូជាច្រើនបានចាត់ទុកថា លំហូរផលប័ត្រ (Portfolio) ឆ្លងកាត់ព្រំដែនជាបញ្ហារំខានបង្កឱ្យមានអស្ថេរភាពដ៏មានសក្តានុពលភាពផង និង ក៏ជាប្រភពនៃវិនិយោគមូលធនដ៏មានសក្តានុពលផងដែរ ។

លំដាប់ និង សារៈសំខាន់នៃលំហូរមូលធនបានចាប់ផ្តើមកើនឡើងនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ នៅពេលដែលប្រទេសទាំងឡាយនៅអឺរ៉ុបបានចាប់ផ្តើមបង្កើតឡើងវិញជាបណ្តើរៗនូវប្រព័ន្ធប្តូរប្រាក់។ ទោះជាយ៉ាងណាក៏ដោយ ការកើនឡើងដំបូងច្រើនបំផុតគឺនៅទសវត្សរ៍ឆ្នាំ១៩៧០ ដោយមានការងើបឡើងទីផ្សារ "អឺរ៉ូដុល្លា"(Eurodollar) និងទីផ្សារហិរញ្ញវត្ថុក្រៅស្រុក ។ មានកត្តាជំរុញផ្សេងទៀតដូចជា ការកើនឡើងជាបន្តបន្ទាប់នៃ"ដុល្លាប្រេង"(Petrodollar)ដោយប្រទេសដែលនាំប្រេងចេញនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ និងការប្រើប្រាស់ឡើងវិញនូវទ្រព្យធនទាំងនេះសំរាប់ប្រទេសនាំប្រេងចូលដែលជាប្រទេសខ្ចីប្រាក់នានា តាមរយៈធនាគារអន្តរជាតិធំៗ។ នៅទសវត្សរ៍ឆ្នាំ ១៩៩០ លំហូរឆ្លងព្រំដែនបានក្លាយជាប្រភពធនធានហិរញ្ញវត្ថុដ៏សំខាន់ទាំងសំរាប់សេដ្ឋកិច្ចដែលមានឧស្សាហកម្មជឿនលឿន និង សេដ្ឋកិច្ចទីផ្សារដែលទើបតែងើបឡើងជុំវិញពិភពលោក ហើយរចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ក្លាយជាមានភាពស្មុគ្រស្មាញដែលទំហំរបស់វាមិនអាចធ្វើការវាស់វែងបាន និង ការគ្រប់គ្រងវាមានកំរិតតិចជាងមុនច្រើន ។

ផលប៉ះពាល់មួយនៃសកលភាវូបនីយ៍កម្មហិរញ្ញវត្ថុគឺថា ការផ្តល់ហិរញ្ញវត្ថុរបស់មូលនិធិរូបិយវត្ថុអន្តរជាតិកាន់តែមានចំនួនតិច សំរាប់ផ្តល់អោយអ្នកដែលអាចសុំខ្ចីដែលមានចំនួនច្រើន។ ក្នុងដំណាក់កាលដំបូងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ប្រទេសដែលកំពុងប្រឈមមុខជាមួយគំលាតហិរញ្ញប្បទាន សំរាប់ជញ្ជីងទូទាត់របស់ពួកគេជាញឹកញយ បានបំបិទគំលាតទាំងនេះ ដោយគ្រាន់តែធ្វើការខ្ចីប្រាក់ពីមូលនិធិរូបិយវត្ថុអន្តរជាតិ។ នៅទសវត្សរ៍ឆ្នាំ ១៩៨០ កម្មវត្ថុរបស់ប្រទេសទាំងនេះ គឺដើម្បីយកមកធ្វើជាកត្តាលីករសំរួលលំហូរចូលនៃមូលធនផ្សេងទៀត ដោយធ្វើការខ្ចីប្រាក់មួយចំនួនតូចពីមូលនិធិរូបិយវត្ថុអន្តរជាតិ សំរាប់ផ្គត់ផ្គង់នូវកញ្ចប់នៃកំណែទំរង់គោលនយោបាយដែលបានព្រមព្រៀងគ្នាពីមុន និង ដោយសង្ឃឹមទុកថា ពួកគេអាចធ្វើការបញ្ចុះបញ្ចូលអ្នកផ្តល់ ឥណទានផ្សេងទៀតថា ប្រទេសរបស់ខ្លួនមានទស្សនវិស័យល្អ។ បញ្ហាចោទនោះ គឺមិនមែនដោយសារបរិមាណនៃទឹកប្រាក់ប៉ុន្មានទេ តែគឺគុណភាពនៃកំណែទំរង់នានា ។ សកលភាវូបនីយ៍កម្មបានប្តូរទាំងស្រុងនូវទំនាក់ទំនងរវាងមូលនិធិរូបិយវត្ថុអន្តរជាតិ និង សមាជិកខ្ចីប្រាក់ និង រវាងមូលនិធិរូបិយវត្ថុអន្តរជាតិ និង អ្នកផ្តល់ឥណទានផ្លូវការ និង ឯកជននានា ។

ផលប៉ះពាល់មួយទៀត គឺវាធ្វើអោយចុះខ្សោយចរិកសហជីពឥណទានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុងនាមជាស្ថាប័នសមាជិកភាពមួយ ពីព្រោះនៅទសវត្សរ៍ឆ្នាំ ១៩៨០ ប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿនជាងគេ អាចមានលទ្ធភាពផ្គត់ផ្គង់ហិរញ្ញវត្ថុលើការទូទាត់ពាណិជ្ជកម្មក្រៅប្រទេសរបស់ខ្លួនតាមរយៈលំហូរ(សាច់ប្រាក់)

ឯកជន ហើយពួកគេមិនចាំបាច់ខ្ចីប្រាក់ពីមូលនិធិរូបិយវត្ថុអន្តរជាតិឡើយ ។ ប្រទេសដែលជាសមាជិកភាគច្រើនរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ បានចែកជាក្រុមអ្នកផ្តល់ឥណទាន និង ក្រុមកូនបំណុលជារហូតមក ។

ផលប៉ះពាល់ទី ៣ នៃការធ្វើសកលភាវូបនីយ៍កម្មហិរញ្ញវត្ថុគឺថា ប្រទេសដែលមានទីផ្សារហិរញ្ញវត្ថុងើបឡើងក្លាយជាអ្នកដែលពឹងផ្អែកលើលំហូរចូលមូលធនឯកជន ដែលមិនស្ថិតស្ថេរ និង មិនអាចទុកចិត្តបាននៅពេលដែលស្ថានភាពសេដ្ឋកិច្ច ទាំងនៅក្នុងតំបន់ និង ជាសកលធ្លាក់ចុះខ្សោយ។ នៅពេលដែលលំហូរទាំងនេះបញ្ច្រាសទៅវិញនៅពាក់កណ្តាលទី ២ នៃទសវត្សរ៍ឆ្នាំ ១៩៩០ ប្រទេសដែលមានប្រាក់ចំណូលជាមធ្យមជាច្រើន ដូចជាប្រទេសម៉ិកស៊ិក ក្នុងឆ្នាំ ១៩៩៥ ប្រទេសថៃ ឥណ្ឌូណេស៊ី និង កូរ៉េ ក្នុងឆ្នាំ ១៩៩៧ ប្រទេសរុស្ស៊ី ក្នុងឆ្នាំ ១៩៩៨ និង ប្រទេសប្រេស៊ីល ក្នុងឆ្នាំ ១៩៩៩ បានបែរមករកមូលនិធិរូបិយវត្ថុអន្តរជាតិវិញ ដើម្បីសុំជំនួយហិរញ្ញវត្ថុក្នុងទំហំទឹកប្រាក់ដែលធំជាងទំហំទឹកប្រាក់ដែលមូលនិធិរូបិយវត្ថុអន្តរជាតិ ធ្លាប់បានផ្តល់អោយពីដំណាក់កាលដំបូងក្នុងករណីមុនៗ។

## ៩- វិបត្តិបំណុលអន្តរជាតិ



នៅក្នុងខែសីហាឆ្នាំ ១៩៨២ ស្ថានភាពធ្លាក់ចុះដុនដាបជាបណ្តើរៗនៃស្ថានភាពទីផ្សារ បំណុលអន្តរជាតិរយៈពេល ២ឆ្នាំ ស្រាប់តែបានបង្កើនល្បឿន និង បង្កអោយមានវិបត្តិសេដ្ឋកិច្ច និង ហិរញ្ញវត្ថុធំៗភ្លាមៗ។ ប្រទេសនានាដែលស្ថិតនៅវាយប៉ាយមួយចំនួន រួមមានប្រទេសហុងគ្រី ម៉ារុក ប៉ូឡូញ និងយូហ្គោស្លាវី សុទ្ធតែបានឃើញធនាគារដែលផ្តល់ឥណទាន របស់ប្រទេសពួកគេបែរខ្នងអោយនៅឆ្នាំ ១៩៨១ និងនៅពាក់កណ្តាលទី ១ នៃឆ្នាំ ១៩៨២។ នៅពេលធនាគារនានា បានដកខ្លួនចេញភ្លាមៗពីប្រទេសម៉ិកស៊ិក វិបត្តិបានកើតឡើងក្នុងប្រព័ន្ធសមាមាត្រ។ ក្នុងរយៈពេលពីរបីខែក្រោយមកទៀត ប្រទេសអាហ្សង់ទីន ប្រេស៊ីល ឆីលលី ក៏ស្ថិតក្នុងភាពអាសន្នដូចគ្នាដែរ ហើយវិបត្តិនេះបន្តសាយភាយពាសពេញ។ រហូតដល់មុនឆ្នាំ ១៩៩០ នៅពេលដែលអត្រាការប្រាក់ពិភពលោកមានភាពនឹងនទៅវិញនិងបំណុលធនាគាររបស់ប្រទេសកំពុងអភិវឌ្ឍន៍ដែលជំពាក់បំណុលគេច្រើនបំផុតកំពុងត្រូវបានជំនួសដោយប័ណ្ណប្រាឌី (Brady Bonds) ទើបអាចប្រកាសបានថា វិបត្តិទាំងនេះត្រូវបានបញ្ចប់ ។ វិបត្តិបំណុលទាំងនោះបានកែប្រែមូលនិធិរូបិយវត្ថុអន្តរជាតិ ដោយគ្រវែងមូលនិធិនេះ អោយទៅជាអ្នកគ្រប់គ្រងវិបត្តិអន្តរជាតិ ។ នៅពេលដែលវិបត្តិនានាកើតឡើងជាបន្តបន្ទាប់បាន ក្នុងទស្សវត្ស ឆ្នាំ ១៩៩០ ដូចដែលបានបញ្ជាក់ខាងដើម មូលនិធិរូបិយវត្ថុអន្តរជាតិ អាចបានដកបទពិសោធន៍ពីមុនទាំងនេះ ទោះបីជាមូលនិធិនេះត្រូវតែព្យាយាមផងដែរ ដើម្បីរកដំណោះស្រាយនានាសំរាប់ស្ថានភាពដែលមានភាពស៊ាំញ៉ាំ និង ភាពឆ្លងរាលដាលលឿននៅពេលវិបត្តិរីករាលដាលជុំវិញ ពិភពលោក។

## ១០-ការដួលរលំនៃកុម្មុយនីស្តនិយម



ការបាក់បែកកំពែងទីក្រុងប៊ែឡាំង ក្នុងឆ្នាំ ១៩៨៩ និងការរំលាយនៃសហភាពសូវៀត ក្នុងឆ្នាំ ១៩៩១ បានជំរុញអោយមូលនិធិរូបិយវត្ថុអន្តរជាតិនៅទីបញ្ចប់ស្ទើរតែក្លាយជាស្ថាប័នជាសកល។ ក្នុងរយៈពេលតែ ៣ ឆ្នាំ មានសមាជិកភាព កើនឡើង ពី ១៥២ ប្រទេសទៅ ១៧២ ប្រទេស គឺជាការកើនឡើងយ៉ាងឆាប់រហ័សបំផុត ចាប់តាំងពីការសុំចូលក្នុងចំនួនដ៏ច្រើន របស់ប្រទេសនៅទ្វីបអាហ្វ្រិក ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០។ (ឥឡូវនេះមូលនិធិរូបិយវត្ថុអន្តរជាតិមានសមាជិកទាំងអស់ចំនួន ១៨៤ប្រទេស) មានសមាជិកថ្មីជាច្រើនត្រូវការខ្ចីប្រាក់ពីមូលនិធិរូបិយវត្ថុអន្តរជាតិ ហើយស្ទើរតែគ្រប់ប្រទេសទាំងអស់នោះ ត្រូវការជំនួយបច្ចេកទេស និងការពិគ្រោះយោបល់ជាប្រចាំ ។ ហេតុដូចនេះហើយចំនួនបុគ្គលិករបស់មូលនិធិរូបិយវត្ថុអន្តរជាតិមានការកើនឡើងស្ទើរតែ ៣០ ភាគរយ ក្នុងរយៈពេល ៦ ឆ្នាំ។ គណៈកម្មការប្រតិបត្តិដែលមានការកើនឡើងពី ២២ កៅអី ទៅ ២៤ កៅអី ដើម្បីទទួលយកនាយក (ប្រតិបត្តិ) នានាមកពីប្រទេសរុស្ស៊ី និង ស្វីស និង នាយកនានា ដែលមានបច្ចុប្បន្នបានឃើញមណ្ឌលរបស់ខ្លួនមានការកើនឡើងមួយចំនួន ថែមទៀត ។

## សេចក្តីសន្និដ្ឋាន

សេដ្ឋកិច្ចពិភពលោក និង មូលនិធិរូបិយវត្ថុអន្តរជាតិមានការផ្លាស់ប្តូរជាច្រើនក្នុងរយៈពេលតែ ៦ ទសវត្សរ៍តែប៉ុណ្ណោះ ចាប់តាំងពី ប្រ៊ីតុន វ៊ូត (Bretton Woods) មក។ ចំនួនទឹកប្រាក់ដែលមូលនិធិរូបិយវត្ថុអន្តរជាតិអោយខ្ចីភាគច្រើន បានក្លាយជាកំចីនៅពេលមានវិបត្តិ ហើយការជាប់ទាក់ទិនរបស់មូលនិធិរូបិយវត្ថុអន្តរជាតិក្នុងការការពារ និងដោះស្រាយវិបត្តិ ក៏កើនឡើងប្រដុំត្រសងដែរ។ ដោយសារបច្ចុប្បន្ននេះ សមាជិកចំនួនជាងពាក់កណ្តាលមានតួនាទីអ្នកផ្តល់ឥណទានជាប្រចាំ ឬ កូនបំណុលគេជាប្រចាំ ហើយមានក្តីសង្ឃឹមតិចតួចណាស់អំពីការផ្លាស់ប្តូរក្រុម រដ្ឋជាច្រើនហាក់ដូចជាយល់ឃើញថាខ្លួនគេមានតួនាទីជាសមាជិកក្រុមមួយបែបនេះ ជាជាងយល់ឃើញថា ពួកគេជាផ្នែកមួយនៃសហគមន៏សកលលោក។ សមាជិកភាពបានរីកកាន់តែធំឡើងៗ មានភាពខុសៗគ្នា និង ស្ទើរតែជាសកល ហើយទន្ទឹមនឹងនេះដែរការទទួលខុសត្រូវរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុងការគ្រប់គ្រងសេដ្ឋកិច្ចពិភពលោកមានការកើនឡើងប្រដុំត្រសងគ្នាដែរ ។ ទំហំនៃការទាក់ទិនរបស់មូលនិធិរូបិយវត្ថុអន្តរជាតិនៅក្នុងការធ្វើគោលនយោបាយ ក្នុងប្រទេសដែលជាសមាជិកនានា ជាពិសេសប្រទេស ដែលសុំខ្ចីប្រាក់មានការកើនឡើងយ៉ាងធំធេង ។

ការវិវត្តិរបស់មូលនិធិរូបិយវត្ថុអន្តរជាតិត្រូវបានជំរុញ និង មានភាពចាំបាច់ដោយសារការផ្លាស់ប្តូរនានានៃស្ថានភាព សេដ្ឋកិច្ច និង នយោបាយរបស់ពិភពលោក។ ប្រសិនបើលំដាប់ព្រឹត្តិការណ៏ដែលគេបានកត់ត្រានៅទីនេះ មិនបានផ្តល់ផលប៉ះពាល់ដល់មូលនិធិរូបិយវត្ថុអន្តរជាតិទៅតាមខ្សែសង្វាក់ទាំងនេះទេ ស្ថាប័ននេះប្រហែលនឹងបានក្លាយជាស្ថាប័នតូច និង រហូតគ្មានភាពសំខាន់។ ភាពប្រឈមរបស់មូលនិធិរូបិយវត្ថុអន្តរជាតិតែងតែជាការប្រកាន់ខ្ជាប់នូវស្នូលដ៏សំខាន់របស់ខ្លួន(អាណត្តិដើមដែលមានភាពចង្អៀតគឺដើម្បីលើកកំពស់នៃការកែតំរូវនៃការទូទាត់ដ៏មានរបៀបរៀបរយ និង ដើម្បីលើកកំពស់ស្ថេរភាពហិរញ្ញវត្ថុពិភពលោក) ក្នុងខណៈពេលដែលកំពុងសំរបសកម្មភាពរបស់ខ្លួនទៅតាមកាលៈទេសៈ និងគំនិតថ្មីៗ។ ខួបលើកទី ៦០ របស់ប្រព័ន្ធប្រ៊ីតុន វ៊ូត (Bretton Woods) ក្នុងឆ្នាំ ២០០៤ បានផ្តល់សន្ទុះសំរាប់មូលនិធិរូបិយវត្ថុអន្តរជាតិក្នុងការឆ្លើយតបទៅនឹងភាពប្រឈមនេះ តាមរយៈដាក់អោយមានការពិនិត្យឡើងវិញនៃយុទ្ធសាស្ត្រ (សូមមើលទំព័រទី ៧) ក្នុងគោលបំណងបោះទីតាំងរបស់ស្ថាប័ននេះ អោយឆ្លើយតបយ៉ាងទន់ភ្លន់ ទៅនឹងភាពប្រឈមនៅពេលខាងមុខទៀត ដែលសេដ្ឋកិច្ចពិភពលោកត្រូវធ្វើដំណើរឆ្លងកាត់ជាច្រើនទសវត្សរ៍ខាងមុខ។

លោក ខេនស៏ (Keynes) និងលោក វ៉ៃ (White) បានបង្កើតមូលនិធិរូបិយវត្ថុអន្តរជាតិ ឡើងដោយសារតែពួកគាត់ មានជំនឿថាពិភពលោកនេះត្រូវការស្ថាប័នផ្លូវការមួយសំរាប់ជំរុញដល់កិច្ចសហប្រតិបត្តិការណ៏ ជាពហុភាគីជំនួសអោយគោលនយោបាយ សេដ្ឋកិច្ចបិទ និង ដើម្បីប៉ះប៉ូវដល់ភាពមានកំណត់នៃលក្ខណៈគ្រឹះរបស់ទីផ្សារឯកជននានា ។ ទោះបីជាពិភពលោក និង ស្ថាប័ននានាមានការផ្លាស់ប្តូរ គោលដៅទាំងអស់នោះនៅតែជាចំណុចសំខាន់ ចំពោះសនិទានភាពនៃតួនាទីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។ ■

*លោក ជេម ប៊ូតុន (James Boughton) គឺជាជំនួយការនាយកនៃនាយកដ្ឋានអភិវឌ្ឍន៍គោលនយោបាយ និង ពិនិត្យឡើងវិញរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ និង ជាប្រវត្តិវិទូផ្លូវការរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ។*

# ការចាត់ចែងមូលនិធិរូបិយវត្ថុអន្តរជាតិ

ទោះបីជាមូលនិធិរូបិយវត្ថុអន្តរជាតិ ជាភ្នាក់ងារឯកទេសមួយរបស់អង្គការសហប្រជាជាតិ និង បានចូលរួមក្នុង ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ មូលនិធិរូបិយវត្ថុអន្តរជាតិធ្វើកិច្ចការងារប្រកបដោយភាពឯករាជ្យ និង មានធម្មនុញ្ញ រចនាសម្ព័ន្ធគ្រប់គ្រងច្បាប់ និង ហិរញ្ញវត្ថុផ្ទាល់។

មូលនិធិរូបិយវត្ថុអន្តរជាតិមានប្រទេសជាសមាជិកចំនួន ១៨៤ មានសមាជិកតិចជាងអង្គការសហប្រជាជាតិតែ ៧ ប្រទេសប៉ុណ្ណោះ។ ចំនុចខុសគ្នានោះ គឺដោយសារប្រទេសគុយបា សាធារណរដ្ឋប្រជាមានិតកូរ៉េ និង ប្រទេសតូចៗបំផុតចំនួន ៥ គឺ : ប្រទេសអានដូរ៉ា (Andorra) ប្រទេសលាចតិនស្តង់ (Liechtenstein) និង ម៉ូណាកូ (Monaco) ក្នុងទ្វីបអឺរ៉ុប និង ប្រទេសដែលនៅក្នុងកោះនរុ (Nauru) និង កោះទូវ៉ាលូ (Tuvalu) ក្នុងមហាសមុទ្រប៉ាស៊ីហ្វិក។ គុយបា ជាប្រទេសសមាជិកដើមរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ តែប្រទេសនេះបានដកសមាជិកភាពនៅឆ្នាំ ១៩៦៤។ ប្រទេសទាំង ៦ ដទៃទៀត មិនដាក់ពាក្យសុំចូលជាសមាជិកនៅឡើយ។ ដើម្បីចូលជាសមាជិកប្រទេសនីមួយៗត្រូវដាក់ពាក្យសុំចូល បន្ទាប់មកត្រូវទទួលស្គាល់ដោយប្រទេសសមាជិកបច្ចុប្បន្នភាគច្រើន។ ការត្រួតពិនិត្យផ្នែកនយោបាយរបស់មូលនិធិរូបិយវត្ថុអន្តរជាតិគឺជាកាតព្វកិច្ច របស់គណៈកម្មការរូបិយវត្ថុអន្តរជាតិ និង ហិរញ្ញវត្ថុ (IMFC) ដែលមានសមាជិកទាំង ២៤ ជារដ្ឋមន្ត្រីហិរញ្ញវត្ថុ ឬជាទេសាភិបាល ធនាគារកណ្តាលមកពីប្រទេស និង មណ្ឌលដូចគ្នា ដែលពួកគេតំណាងនៅក្នុងជួរគណៈកម្មការប្រតិបត្តិ (សូមមើលតារាងរចនាសម្ព័ន្ធគ្រប់គ្រងទំព័រ ៣៣)។ គណៈកម្មការកិច្ចការហិរញ្ញវត្ថុ និង រូបិយវត្ថុអន្តរជាតិធ្វើការជួបជុំគ្នាចំនួន ២ដង ក្នុង១ឆ្នាំ និង ធ្វើការផ្តល់ឱវាទដល់មូលនិធិរូបិយវត្ថុអន្តរជាតិ អំពីទិសដៅគោលនយោបាយចំបងៗ។

សមាជិករបស់គណៈកម្មការរូបិយវត្ថុអន្តរជាតិ និង ហិរញ្ញវត្ថុ ភាគច្រើនក៏ជាសមាជិករបស់ក្រុមប្រឹក្សាភិបាល (Board of Governors) ផងដែរ ដែលប្រទេសជាសមាជិកនីមួយៗមានអភិបាលម្នាក់។ ក្រុមប្រឹក្សាភិបាលជួបជុំគ្នា ១ ដង រយៈពេលមួយឆ្នាំ និង ធ្វើការបោះឆ្នោតលើការសំរេចចិត្តសំខាន់ៗរបស់ស្ថាប័ន ដូចជា ថាតើត្រូវធ្វើការបង្កើនធនធានហិរញ្ញវត្ថុ របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។ គណៈកម្មការអភិវឌ្ឍន៏ ក៏ដូចជាគណៈកម្មការរូបិយវត្ថុអន្តរជាតិ និង ហិរញ្ញវត្ថុដែរ មានសមាជិក ២៤ រូប ដែលមានឋានៈជារដ្ឋមន្ត្រីធ្វើការផ្តល់ឱវាទដល់ក្រុមប្រឹក្សាភិបាល របស់មូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោកអំពីបញ្ហាដែលប្រទេសកំពុងអភិវឌ្ឍន៏ជួបប្រទះ។ គណៈកម្មការនេះជួបប្រជុំគ្នា ២ ដងក្នុងមួយឆ្នាំ។

ប្រធានប្រតិបត្តិរបស់មូលនិធិរូបិយវត្ថុអន្តរជាតិគឺជានាយកគ្រប់គ្រង (Managing Director) ដែលត្រូវបានគេជ្រើសរើស ដោយគណៈកម្មការប្រតិបត្តិ (Executive Board) (ដែលគាត់ដឹកនាំ) អោយបំរើការងារក្នុងអាណត្តិរយៈពេល ៥ឆ្នាំ។ នាយកគ្រប់គ្រង (ជាទំនៀមទំលាប់ជាជនជាតិអឺរ៉ុប) ដែលត្រូវជួយដោយអនុប្រធានចំនួន ៣នាក់: នាយករងទី ១ (តែងតែ ជាជនជាតិអាមេរិក) និងនាយករង ២ នាក់ ផ្សេងទៀត (មកពីប្រទេសផ្សេងៗ) ។ គណៈកម្មការប្រតិបត្តិដែលជាអ្នករៀបចំគោលនយោបាយ និង ធ្វើការទទួលខុសត្រូវចំពោះការធ្វើការសំរេចចិត្តនានា រួមមាននាយកប្រតិបត្តិ (Executive Directors) ចំនួន ២៤ រូប។ ប្រទេស ៥ ដែលមានកូតាច្រើនជាងគេបំផុតគឺ សហរដ្ឋអាមេរិក ប្រទេសជប៉ុន អាល្លឺម៉ង់ បារាំង និង ចក្រភពអង់គ្លេស តែងតាំងនាយកនានា។ ប្រទេសចំនួន ៣ ផ្សេងទៀតមាន ចិន រុស្ស៊ី និង សាវឌីអារ៉ាប់ប៊ី ដែលមានកូតា ច្រើនគ្រប់គ្រងដើម្បីជ្រើសរើសនាយកប្រតិបត្តិដោយពួកគេផ្ទាល់។ ប្រទេសចំនួន ១៧៦ ផ្សេងទៀត ត្រូវបានគេរៀបចំដាក់ជាមណ្ឌលចំនួន ១៦ ដែលមណ្ឌលនីមួយៗធ្វើការជ្រើសរើសនាយកប្រតិបត្តិដោយខ្លួនឯង ។ មណ្ឌលនីមួយៗត្រូវបង្កើតឡើង ដោយប្រទេសដែលមានផលប្រយោជន៏ប្រហាក់ប្រហែលគ្នា ហើយជាទូទៅ ជាប្រទេសដែលមកពីតំបន់ជាមួយគ្នា ដូចជាប្រទេស ដែលនិយាយភាសាបារាំងនៅក្នុងទ្វីបអាហ្វ្រិក (សូមមើលតារាងនៅទំព័រ ១៥)។

មូលនិធិរូបិយវត្ថុអន្តរជាតិ មានបុគ្គលិកប្រហែល ២៧00 នាក់មកពីប្រទេសចំនួន ១៤០ ដែលពួកគេភាគច្រើន ធ្វើការនៅទីស្នាក់ការកណ្តាលរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ដែលស្ថិតនៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី។ មានបុគ្គលិកមួយចំនួនតូច ដែលធ្វើការនៅតាមតំបន់ ឬនៅតាមការិយាល័យក្នុងស្រុកនៅលើពិភពលោក។ បុគ្គលិករបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ត្រូវបានគេរៀបចំដាក់ទៅតាមនាយកដ្ឋាន ដែលមានការទទួលខុសត្រូវតាមតំបន់ មុខងារ ពតិមាន និង ទំនាក់ទំនង និង ការគាំទ្រ ។ បុគ្គលិកទាំងឡាយធ្វើការតាមដានការងារ ការអភិវឌ្ឍសេដ្ឋកិច្ចសកលលោក សេដ្ឋកិច្ចតំបន់ ឬសេដ្ឋកិច្ចរបស់ប្រទេសជាក់លាក់មួយ និង ធ្វើការវិភាគលើដំណើរការអភិវឌ្ឍសេដ្ឋកិច្ច និង គោលនយោបាយដែលបង្កើតជាមូលដ្ឋានគ្រឹះរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុងការធ្វើប្រតិបត្តិការផ្តល់យោបល់ ការរៀបចំគោលនយោបាយ ក្នុងការផ្តល់ប្រាក់កំចី និង ការផ្តល់ជំនួយបច្ចេកទេស។

### តើមូលនិធិរូបិយវត្ថុអន្តរជាតិបានប្រាក់ពីណាមក?

មូលនិធិរូបិយវត្ថុអន្តរជាតិ ជាសហករណ៏ហិរញ្ញវត្ថុដែលមានលំនាំដូចជាសហព័ន្ធផ្តល់ឥណទាន (Credit Union) ដែរ។ ក្នុងការរួបរួមគ្នានេះ ប្រទេសសមាជិកនីមួយៗបង់ប្រាក់ក្នុងទំរង់ការណ៏ចុះបញ្ជី (Subscription) ដែលគេហៅថា "កូតា" (Quota) ។ កូតារបស់ប្រទេសនីមួយៗ ត្រូវបានគេកំណត់ដោយលំដាប់សេដ្ឋកិច្ចរបស់ខ្លួនប្រៀបធៀបទៅនឹងសមាជិកផ្សេងៗ និង លើកយកមកពិចារណាផងដែរ នូវទំហំផលទុនជាតិ (ដុល) GDP ប្រតិបត្តិការគណនីចរន្តនៃពាណិជ្ជកម្មក្រៅប្រទេស និង ធនធានបំរុងជាផ្លូវការ (Official Reserves) របស់ប្រទេស ។ កូតាជាអ្នកកំណត់ការសុំទិញប្រាក់ទុន (Capital Subscription) ចំពោះមូលនិធិរូបិយវត្ថុអន្តរជាតិ និង ដាក់ការកំណត់ចំនួនទឹកប្រាក់ដែលសមាជិកនិមួយៗអាចខ្ចីបាន។ កូតាក៏ជួយកំណត់អំណាច ក្នុងការធ្វើការបោះឆ្នោតរបស់សមាជិកផងដែរ។

ការបូកផ្សំគ្នានៃការទិញប្រាក់ទុនទាំងអស់របស់សមាជិក នៃមូលនិធិរូបិយវត្ថុអន្តរជាតិ បង្កើតបានជាធនធានមួយដែល មូលនិធិរូបិយវត្ថុអន្តរជាតិប្រើប្រាស់សំរាប់ផ្តល់ជាជំនួយបណ្តោះអាសន្នដល់ប្រទេសនានាដែលជួបប្រទះបញ្ហាផ្នែកហិរញ្ញវត្ថុ ។ ធនធានទាំងនេះ អាចអោយមូលនិធិរូបិយវត្ថុអន្តរជាតិ ផ្តល់ហិរញ្ញប្បទានដល់ជញ្ជីងទូទាត់ ដើម្បីគាំទ្រដល់ប្រទេសសមាជិក ក្នុងការអនុវត្តន៏ការកែតំរូវសេដ្ឋកិច្ច និង កម្មវិធីកំណែទំរង់នានា។

ក្នុងចន្លោះពេលដែលគេកំណត់ទៀងទាត់មិនលើសពី៥ឆ្នាំ គណៈកម្មការប្រតិបត្តិរបស់មូលនិធិរូបិយវត្ថុអន្តរជាតិពិនិត្យ ឡើងវិញលើកូតារបស់សមាជិកនានា និង ធ្វើការសំរេចចិត្ត ដោយគិតដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាសកល និង ការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ចរបស់សមាជិកទាំងនោះ ធៀបទៅនឹងសមាជិកដទៃផ្សេងៗទៀត ថាតើត្រូវលើកសំណើដើម្បីធ្វើការកែតំរូវ កូតា ដាក់ជូនក្រុមប្រឹក្សាភិបាល ឬយ៉ាងណា។ ដើម្បីជំរុញអោយមានសំលេងមិនលំអៀង និងតំណាងនៃប្រទេសសមាជិកទាំងអស់ ការបែងចែកផ្តល់កូតាកំពុងស្ថិតនៅក្នុងការពិនិត្យឡើងវិញ ដើម្បឆ្លុះបញ្ចាំងអំពីការផ្លាស់ប្តូរសំខាន់ៗក្នុងទំងន់ និង តួនាទីរបស់ប្រទេសនានាក្នុងសេដ្ឋកិច្ចពិភពលោក ។ នាយកគ្រប់គ្រងធ្វើការជាមួយគណៈកម្មការរូបិយវត្ថុអន្តរជាតិ និង ហិរញ្ញវត្ថុ និង គណៈកម្មការប្រតិបត្តិដើម្បីលើកជាសំណើដែលមានភាពប្រាកដប្រជា ដើម្បីសុំការយល់ព្រមនៅឯកិច្ចប្រជុំប្រចាំឆ្នាំ ២០០៦ នៅប្រទេសសិង្ហបូរី ។

ប្រទេសទាំងអស់ត្រូវបង់ប្រាក់ចំនួន ២៥ ភាគរយនៃការសុំទិញកូតាជាទ្រព្យបំរុងកំណត់ហៅថា សិទ្ធិដកប្រាក់ពិសេស (SDRs) (សិទ្ធិដកប្រាក់ពិសេសជាឯកតានៃគណនីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ) ឬជារូបិយប័ណ្ណសំខាន់ៗ (ដុល្លាអាមេរិក ប្រាក់អឺរ៉ូ ប្រាក់យ៉េនរបស់ជប៉ុន ឬ ផោនរបស់អង់គ្លេស)។ មូលនិធិរូបិយវត្ថុអន្តរជាតិ អាចសុំអោយបង់ប្រាក់ដែលនៅសល់ ជាទំរង់រូបិយប័ណ្ណរបស់សមាជិកខ្លួន ដែលសំរាប់ផ្តល់ប្រាក់កំចីទៅពេលត្រូវការ ។ កូតាសរុបរបស់មូលនិធិរូបិយវត្ថុអន្តរជាតិមានចំនួនស្មើនឹង ២១៣,៥ ពាន់លាន SDR (តំលៃប្រហែលជា ៣២៤ ពាន់លាន ដុល្លា)។ អំណាចបោះឆ្នោតរបស់ប្រទេសនីមួយៗ គឺជាការសរុបនៃ "ការបោះឆ្នោតមូលដ្ឋាន" និង ការបោះឆ្នោតដោយផ្អែកលើចំនួនកូតា ។ សមាជិកមូលនិធិរូបិយវត្ថុអន្តរជាតិនីមួយៗ នៃមូលនិធិរូបិយវត្ថុអន្តរជាតិ មានសន្លឹកឆ្នោតមូលដ្ឋានចំនួន ២៥០ (ដូចដែលបានកំណត់ដោយមាត្រាទាំងឡាយនៃកិច្ចសន្យាថា មានចំនួនស្មើគ្នាសំរាប់សមាជិកទាំងអស់) បូកជាមួយនិងសន្លឹកឆ្នោត ១ សន្លឹក បន្ថែមទៀតសំរាប់រាល់ ១០០ ០០០ SDR នៃកូតា ។

ប្រសិនបើមានករណីចាំបាច់ មូលនិធិរូបិយវត្ថុអន្តរជាតិ អាចសុំខ្ចីប្រាក់ បន្ថែមលើធនធានដែលមានស្រាប់បានមកពី កូតារបស់ខ្លួន ។ មូលនិធិរូបិយវត្ថុអន្តរជាតិ មានរបៀបពីរ ក្នុងការខ្ចីប្រាក់ពីប្រទេសដែលជាសមាជិក ដើម្បីយកមកដោះស្រាយ ចំពោះការគំរាមកំហែងនានាចំពោះប្រព័ន្ធរូបិយវត្ថុអន្តរជាតិ ។ ស្ថិតក្រោម ការរៀបចំទាំងពីរប្រភេទ ដែលគេបានដាក់បញ្ចូលគ្នា មូលនិធិរូបិយវត្ថុអន្តរជាតិ មានធនធានរហូតដល់ ៣៤ ពាន់លាន SDR (មានតំលៃប្រហែលជា ៤៩ ពាន់លានដុល្លាអាមេរិក) ដើម្បីអោយប្រទេសសមាជិកខ្ចី។

ប្រាក់កំចីសម្បទាន និង ប្រាក់ជំនួយលុបបំណុលសំរាប់អោយប្រទេសដែលមានប្រាក់ចំណូលទាប បានមកពីមូលនិធិមរតក (Trust Funds) ដែលគ្រប់គ្រងដោយមូលនិធិរូបិយវត្ថុអន្តរជាតិ។

**ការបង់ប្រាក់អោយមូលនិធិរូបិយវត្ថុអន្តរជាតិ**

ដូចគ្នាទៅនឹងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀតដែរ មូលនិធិរូបិយវត្ថុអន្តរជាតិ បានទទួលប្រាក់ចំណូលពីការប្រាក់ និង កំរៃលើប្រាក់កំចី និងការប្រើប្រាក់ចំណូលដើម្បីចំណាយរដ្ឋបាល និងសំរាប់បង្កើនតុល្យការការពារវិបត្តិនានា។ នៅក្នុងឆ្នាំហិរញ្ញវត្ថុ ២០០៦ ការប្រាក់ និង តំលៃសេវាកម្មដែលទទួលបានពីប្រទេសខ្ចីប្រាក់ និងប្រាក់ចំណូលផ្សេងៗទៀតសរុបទាំងអស់មានចំនួន ២,៥ ពាន់លានដុល្លាអាមេរិក ចំណែកឯការបង់ប្រាក់ការ ចំពោះចំណែកមួយនៃការសុំទិញកូតារបស់សមាជិកដែលសំរាប់ប្រើប្រាស់ក្នុងការធ្វើប្រតិបត្តិការណ៍របស់អង្គការ មានចំនួនកើនឡើងដល់ ១,២ ពាន់លានដុល្លា។ ការចំណាយរដ្ឋបាល (បូករួមទាំងប្រាក់បៀវត្សបុគ្គលិក ប្រាក់សោធនិវត្តិន៏ ការធ្វើដំណើរ និងសំភារៈ) សរុបមាន ១ ពាន់លានដុល្លាអាមេរិក។ ប្រាក់នៅសល់ ចំនួន ០,៣ ពាន់លានដុល្លាអាមេរិក ត្រូវបានដាក់បន្ថែមទៅលើធនធានបំរុងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ។ ក្របខណ្ឌប្រាក់ចំណូលនាពេលបច្ចុប្បន្នពឹងផ្អែកភាគច្រើនទៅលើប្រាក់ចំណូលពីការអោយខ្ចីប្រាក់ ។ អាទិភាពសំរាប់មូលនិធិរូបិយវត្ថុអន្តរជាតិ ពេលខាងមុខ គឺបង្កើតក្របខ័ណ្ឌថ្មី ដែលអាចបង្កើតប្រភពចំណូលជាប្រចាំ និង ទុកចិត្តបាននៅក្នុងរយៈពេលវែង។ ក្នុងសកម្មភាព ដំបូងគណៈកម្មការប្រតិបត្តិរបស់មូលនិធិរូបិយវត្ថុអន្តរជាតិផ្តល់ការអនុម័តលើការបង្កើត គណនីវិនិយោគដែលមានទឹកប្រាក់ ៨,៧ ពាន់លានដុល្លា ដែលគេសង្ឃឹមថា វាអាចជួយជំរុញប្រាក់ចំណូលរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុងរយៈពេលមធ្យម។ ក្នុងខែឧសភា ឆ្នាំ ២០០៦ មូលនិធិរូបិយវត្ថុអន្តរជាតិបានធ្វើការតែងតាំងគណៈកម្មការពីខាងក្រៅមួយនៃ "បុគ្គលជាន់ខ្ពស់នានា " ដើម្បីផ្តល់ការវាយតំលៃដោយឯករាជ្យលើជំរើសដែលអាចផ្តល់ហិរញ្ញវត្ថុ សំរាប់ការចំណាយចាត់ចែងមូលនិធិរូបិយវត្ថុអន្តរជាតិក្នុងពេលអានាគត ។ ■

### មូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោក_តើមានភាពខុសគ្នាដូចម្តេចខ្លះ?

មូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោកត្រូវបានចាប់កំណើតឡើងនៅក្នុងកិច្ចប្រជុំ ប្រឺតុន វ៉ូត (Bretton Woods) នៅខែកក្កដា ឆ្នាំ១៩៤៤ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការណ៍សេដ្ឋកិច្ចអន្តរជាតិ និងជួយបង្កើតសេដ្ឋកិច្ចពិភពលោកមួយដែលមានស្ថេរភាព និង ភាពរុងរឿង។ ទោះបីជាគោលបំណងទាំងនេះ ឋិតនៅតែជាមូលដ្ឋានចំបងរបស់ស្ថាប័នទាំងពីរក៏ដោយអាណត្តិ និង មុខងាររបស់ស្ថាប័នទាំងពីរនេះមានភាពខុសគ្នា ហើយកិច្ចការរបស់ស្ថាប័នទាំងពីរនេះវិវត្តន៍ដើម្បីឆ្លើយតបទៅតាមការអភិវឌ្ឍន៍សេដ្ឋកិច្ច និង ការប្រឈមថ្មីៗ ។

មូលនិធិរូបិយវត្ថុអន្តរជាតិ ជំរុញកិច្ចសហប្រតិបត្តិការណ៍រូបិយវត្ថុអន្តរជាតិ និង ជួយប្រទេសជាសមាជិក តាមរយៈការផ្តល់ឱវាទក្នុងការរៀបចំគោលនយោបាយ ផ្តល់ប្រាក់កំចីបណ្តោះអាសន្ន និង ជំនួយបច្ចេកទេស ដើម្បីអោយប្រទេសទាំងនេះអាចបង្កើត និង ថែរក្សាស្ថេរភាពហិរញ្ញវត្ថុ និងផ្តល់ភាពរស់រានដល់វិស័យក្រៅស្រុក និង កសាង និង រក្សាសេដ្ឋកិច្ចអោយមានភាពមាំមួន ។ ប្រាក់កំចីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ត្រូវបានគេផ្តល់អោយដើម្បីគាំទ្រដល់កម្មវិធីគោលនយោបាយដែលគេរៀបចំឡើង ដើម្បីដោះស្រាយបញ្ហាជញ្ជីងទូទាត់ គឺថាចំពោះស្ថានភាពដែលប្រទេសនោះ មិនអាចទទួលហិរញ្ញប្បទានដែលមានលក្ខខណ្ឌអនុគ្រោះគ្រប់គ្រាន់ ដើម្បីបំពេញកាតព្វកិច្ចក្នុងការទូទាត់អន្តរជាតិ ។ ប្រាក់កំចីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិមួយចំនួនគឺមានរយៈពេលខ្លី ទទួលបានមូលនិធិតាមរយៈការផ្តល់វិភាគទានតាមកូតាផ្តល់អោយដោយសមាជិកនានា។ ប្រាក់កំចីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិផ្សេងៗទៀត គឺសំរាប់រយៈពេលវែងជាងនេះដោយគិតទាំងប្រាក់កំចីសម្បទានដែលផ្តល់ដល់ប្រទេសជាសមាជិកនានា ដែលមានប្រាក់ចំណូលទាប ដោយផ្អែកលើមូលដ្ឋាន នៃការផ្តល់ឧបត្ថមធនបានមកពីការលក់មាសដែលមានពីមុនរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ និង ការជួយផ្តល់វិភាគទានរបស់ប្រទេសដែលជាសមាជិក។ ក្នុងកិច្ចការងាររបស់ខ្លួននៅក្នុងប្រទេសនានា ដែលមានប្រាក់ចំណូលទាប ការយកចិត្តទុកដាក់ចំបងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ គឺ ផ្តោតទៅលើវិធី ដែលធ្វើអោយគោលនយោបាយ ម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចចូលរួមចំណែកដាក់ចេញនូវមូលដ្ឋានគ្រឹះសំរាប់អោយមានការអភិវឌ្ឍប្រកបដោយចីរភាព និង មានការកាត់បន្ថយភាពក្រីក្រ។ បុគ្គលិកជំនាញរបស់មូលនិធិរូបិយវត្ថុអន្តរជាតិភាគច្រើនជាសេដ្ឋកិច្ចវិទូ។

ធនាគារពិភពលោកធ្វើការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចដែលមានរយៈពេលវែង និង ការកាត់បន្ថយភាពក្រីក្រ ដោយផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និង ជំនួយបច្ចេកទេស គិតរួមទាំងការជួយប្រទេសនីមួយៗក្នុងការធ្វើកំណែទំរង់លើវិស័យសំខាន់ៗ ឬ អនុវត្តគំរោងជាក់លាក់មួយចំនួន ឧទាហរណ៏ដូចជា ការកសាងសាលារៀន និង មណ្ឌលសុខភាព ការផ្តល់ទឹក និង ភ្លើង ការប្រយុទ្ធប្រឆាំងទៅនឹងជំងឺរាតត្បាត និង ការការពារបរិស្ថាន។ ជំនួយផ្នែកហិរញ្ញវត្ថុរបស់ធនាគារពិភពលោកជាទូទៅមានរយៈពេលវែង និង ទទួលមូលនិធិតាមរយៈការផ្តល់វិភាគទានរបស់ប្រទេសសមាជិក និងការបោះប័ណ្ណ (bond)។ បុគ្គលិករបស់ធនាគារពិភពលោកមានជំនាញដែលគ្រប់ដណ្តប់ទៅលើមុខជំនាញច្រើនបែបជាងបុគ្គលិកមូលនិធិរូបិយវត្ថុអន្តរជាតិ ។

មូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោកធ្វើកិច្ចសហប្រតិបត្តិការណ៍ជាមួយគ្នាក្នុងផ្នែកជាច្រើន ជាពិសេស ក្នុងការគាំទ្រដល់រដ្ឋាភិបាលក្នុងការអនុវត្តយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសនានាដែលមានប្រាក់ចំណូលទាប ផ្តល់នូវការលុបបំណុលដល់ប្រទេសដែលក្រីក្របំផុត និង ជួយប៉ាន់ប្រមាណលើវិស័យហិរញ្ញវត្ថុនានារបស់ប្រទេសទាំងនោះ។ ស្ថាប័នទាំងពីរនេះ ធ្វើការប្រជុំរួមគ្នាពីរដងក្នុងមួយឆ្នាំ។

## តំណាងរបស់ប្រទេស និង សន្លឹកឆ្នោតនៅលើគណៈកម្មការប្រតិបត្តិ នៃមូលនិធិរូបិយវត្ថុអន្តរជាតិ (ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៦)

គណៈកម្មការប្រតិបត្តិ (Executive Board) មាននាយកប្រតិបត្តិ (Directors) ២៤ រូប ដែលតំណាងអោយប្រទេសនីមួយៗ ឬក្រុមប្រទេសទាំងឡាយ ។ ឈ្មោះរបស់នាយកម្នាក់ៗត្រូវគេសរសេរឡើងជាអក្សរដិតខ្លាំង ហើយឈ្មោះរបស់នាយកជំនួសសរសេរ ជាអក្សរទ្រេត ។ អំណាចក្នុងការបោះឆ្នោតរបស់ប្រទេសនីមួយៗ ត្រូវបានគេបង្ហាញនៅក្នុងវង់ក្រចក ។ សំរាប់មណ្ឌលនីមួយៗ សន្លឹកឆ្នោតសរុប និង អំណាចក្នុងការបោះឆ្នោតត្រូវគេសរសេរនៅខាងក្រោមបញ្ជីនៃប្រទេស ។ ចំនួនសរុបអាចល្អៀង បើសិនគេបូកបញ្ចូលគ្នាដោយសារមានការកាត់ខ្ទង់ ។

**ណាស៊ី ភី ហ្សាក់លីន (Nancy P. Jacklin)**
*មិក ឡាន់សាហ្គ័រ (Meg Lundsager)*
សហរដ្ឋអាមេរិក
មាន ៣៧១.៧៤៣ សន្លឹក (១៧,០៨ %)

**ស៊ីជីអុ កាស៊ីវ៉ាហ្គិ (Shigeo Kashiwagi)**
*មីជីអុ គីតាហារ៉ា (Michio Kitahara)*
ប្រទេសជប៉ុន
១៣៣.៣៧៨ សន្លឹក (៦,១៣%)

**ខាលហេន ប៊ីសស្កូហ្វប៊ែរហ្គ័រ (Karlheinz Bischofberger)**
*ហ្គ័ត មីសស្ន័រ (Gert Meissner)*
ប្រទេសអាឡឺម៉ង់
១៣០.៣៣២ សន្លឹក (៥,៩៩%)

**ព្យែរ ឌូកែស (Pierre Duquesne)**
*អូលីវីយេ៉ គុយនី (Olivier Cuny)*
ប្រទេសបារាំង
១០៧.៦៣៥ សន្លឹក (៤,៩៥%)

**ថម ស្កូល័រ (Tom Scholar)**
*អែនឌ្រូ ហូស៊ែរ (Andrew Hausere)*
រាជាណាចក្រអង់គ្លេស
១០៧.៦៣៥ សន្លឹក (៤,៩៥%)

**វីលី គីកេន (Willy Kiekens)**(ប្រទេសបែលហ្ស៊ិក)
*ចូហាន់ ប្រ៉ាដ័រ (Johann Prader) (ប្រទេសអូទ្រីស)*
ប្រទេសអូទ្រីស (0,៨៧%)
ប្រទេសបេ៊លឡារុស (0,១៩%)
ប្រទេសបែ៊លហ្ស៊ិក (២,១៣%)
សាធារណៈរដ្ឋឆែក (0,៣៩%)
ប្រទេសហុងហ្គារី (0,៤៩%)
កាហ្សាក់ស្ថែន (0,១៨%)
ប្រទេសឡុចហ្សមប៊ួ (0,១៤%)
សាធារណៈរដ្ឋស្លូវ៉ាក់ (0,១៨%)
ប្រទេសស្លូវ៉ានី (0,១២%)
ប្រទេសតួគី (0,៤៦%)
១១១.៦៩៦ សន្លឹក (៥,១៣%)

**ជេរ៉ូអែន គ្រីមមែន (Jeroen Kremers)** (ប្រទេសហូលង់)
*យូរី ជី យ៉ាគូសា (Yuriy G. Yakusha) (ប្រទេសអ៊ុយក្រែន)*
ប្រទេសអាមីនៀ (0,0៥%)
ប្រទេសប៊ូស្នៀ និងហឺហ្សេហ្គូវីណា (0,0៩%)
ប្រទេសប៊ុលហ្គារី (0,៣១%)
ប្រទេសក្រូអាទី (0,១៨%)
ប្រទេសសាយព្រឹស (0,0៨%)
ប្រទេសច័រជៀ (0,0៨%)
ប្រទេសអ៊ីស្រាអែល (0,៤៤%)
ប្រទេសម៉ាសេដូនៀ (0,0៤%)
ប្រទេសម៉ូលដូវ៉ា (0,0៧%)
ប្រទេសហូឡង់ (២,៣៩%)
ប្រទេសរ៉ូម៉ានៀ (0,៤៩%)
ប្រទេសអ៊ុយក្រែន (0,៦៤%)
១០៥.៤១២ សន្លឹក (៤,៨៤%)

**ម័រហេស្ស ស្វ័ត (Moisés Schwartz)** (ប្រទេសម៉ិកស៊ិក)
*ម៉ារី ដឺហ្គ័រ (Mary Dager) (ប្រទេសវេនេស្វេឡា)*
ប្រទេសកូស្តារីកា (0,0៩%)
ប្រទេសអែលសាល់វ៉ាឌ័រ (0,0៩%)
ប្រទេសហ្គាតេម៉ាឡា (0,១១%)
ប្រទេសហុងឌូរាស់ (0,0៧%)
ប្រទេសម៉ិកស៊ិក (១,២0%)
ប្រទេសនីការ៉ាហ្គា (0,0៧%)
ប្រទេសអេស្ប៉ាញ (១,៤២%)
ប្រទេសវេនេស្វេឡា, សាធារណរដ្ឋបូលីវ៉ានៀ (១,២៤%)
៩២.៩៨៩ សន្លឹកឆ្នោត (៤,២៧%)

**អារីសហ្គូ សាឌុន (Arrigo Sadun)** (ប្រទេសអ៊ីតាលី)
*មីរ៉ាដា ស្សាហ្វា (Miranda Xafa) (ប្រទេសក្រិច)*
ប្រទេសអាល់បានៀ (0,0៣%)
ប្រទេសក្រិច (0,៣៩%)
ប្រទេសអ៊ីតាលី (៣,២៦%)
ប្រទេសម៉ាល់តា (0,0៦%)
ប្រទេសព័រទុយហ្គាល់ (0,៤១%)
ប្រទេសសាន់ម៉ារីណូ (0,0២%)
ប្រទេសទីម័រឡេស (0,0២%)
៩0.៩៦៨ សន្លឹកឆ្នោត (៤,១៨%)

**ចូណាថាន់ ហ្វ្រិក (Jonathan Fried)** (ប្រទេសកាណាដា)
*ភីតថ័រ ឆាលលីថុន (Peter Charleton) (ប្រទេសអៀរឡង់)*
ប្រទេសអែនទីកា និង បាប៊ូដា (0,0២%)
ប្រទេសបាហាម៉ាស (0,0៧%)
ប្រទេសបាបាដូស (0,0៤%)
ប្រទេសបេលីស្ស (0,0២%)
ប្រទេសកាណាដា (២,៩៥%)
ប្រទេសដូមីនីកា (0,0២%)
ប្រទេសគ្រីណាដា (0,0២%)
ប្រទេសអៀរឡង់ (0,៤0%)
ប្រទេសហ្សាម៉ៃកា (0,១៤%)
រដ្ឋ ខិត និង នេវីស (0,0២%)
រដ្ឋ ឡូសសៀរ (0,0២%)
រដ្ឋ វីនសិន និង គ្រីណាឌីនរ (0,0២%)
៨0.៦៣៦ សន្លឹក (៣,៧១%)

**ទូម៉ាស សាអានែហេមូ (Tuomas Saarenheimo)**
**(ប្រទេសហ្វាំងឡង់ដ៍)**
*ចបថូវ៉ាដ័រ ស៊ីគ័រគីសាន់ (Jon Thorvardur Sigurgeirsson)*
*(ប្រទេសអាយស៍ឡិន)*
ប្រទេសដិនម៉ាក (0,៧៧%)
ប្រទេសអេត្សូនៀ (0,0៤%)
ប្រទេសហ្វាំងឡង់ដ៍ (0,៥៩%)
ប្រទេសអាយឡិន (0,0៧%)
ប្រទេសឡែតវៀ (0,0៧%)
ប្រទេសលីទុយនៀ (0,0៨%)
ប្រទេសណរវ៉េ (0,៧៨%)
ប្រទេសស៊ុយអែត (១,១២%)
៧៦.២៧៦ សន្លឹក (៣,៥១%)

**ជង់ ណាមអូ (Jong Nam Oh)** (ប្រទេសកូរ៉េ)
*រីកឆាត មូរ៉េ (Richard Murray) (ប្រទេសអូស្ត្រាលី)*
ប្រទេសអូស្ត្រាលី (១,៥0%)
ប្រទេសគិរិបាទី (0,0១%)
ប្រទេសកូរ៉េ (0,៧៦%)
កោះម៉ាសាល, អានឡិន (0,0១%)
ប្រទេសមីក្រូណេស៊ា, សហព័ន្ធ (0,0១%)
ប្រទេសម៉ុងហ្គោលី (0,0៤%)
ប្រទេសញូស៊ីឡិន (0,៤២%)
ប្រទេសផ្លូឡ (0,0១%)
ប្រទេសផាផួរ ញូ ហ្គិនា (0,0៧%)
ប្រទេសហ្វីលីពីន (0,៤២%)
ប្រទេសសាមូ៉ (0,0២%)
ប្រទេស សេឆិលិស (0,0២%)
ប្រទេស សូលូមូ អាយឡិន (0,0២%)
ប្រទេសវ៉ាន់ ញូអែតធួ (0,0២%)
៧២.៤២៣ សន្លឹក (៣,៣៣%)

**សេ សាក់គួរសាអាឡាន (A. Shakour Shaalan)**
**(ប្រទេសអេហ្ស៊ីប)**
*សាមៀរ អែលខូរី (Samir El-Khouri) (ប្រទេសលីបានិន)*
ប្រទេសបារ៉ែន (0,0៧%)
ប្រទេសអេហ្ស៊ីប (0,៤៥%)
ប្រទេសអ៊ីរ៉ាក់ (0,៥៦%)
ប្រទេសហ្សកដង់ (0,0៩%)
ប្រទេស គុយវ៉ែត (0,៦៥%)
ប្រទេសលីបាណិន (0,១១%)
ប្រទេសលីប៊ីយ៉ា អារ៉ាប់ ហ្សាម៉ាហ៊ីរីយ៉ា (0,៥៣%)
ប្រទេសម៉ាឌីវ (0,0២%)
ប្រទេស អូម៉ាន (0,១0%)
ប្រទេសកាតា (0,១៣%)
ប្រទេសសាធារណៈរដ្ឋស៊ីយរិយ៉ាន អារ៉ាប់ (0,១៥%)
ប្រទេសសហរដ្ឋអារ៉ាប់អេមីរេត (0,២៩%)
ប្រទេស សាធារណៈរដ្ឋ យីមិន (0,១២%)
៧0.៨៥២ សន្លឹក (៣,២៦%)

**ស៊ូឡៃម៉ែន អ៊ឹម អាល់ថឺគី (Sulaiman M. Al-Turki)**
*អាប់ដាឡាស អេស អាឡាហ្សាស (Abdallah S. Alazzaz)*
ប្រទេស សូដឺ អារាប៊ី
៧0.១0៥ សន្លឹក (៣,២២%)

**ហូអ៊ី អេងផង (Hooi Eng Phang)** (ប្រទេសម៉ាឡេស៊ី)
*ម៉េត សុកាដា (Made Sukada) (ប្រទេសឥណ្ឌូនេស៊ី)*
ប្រទេស ប្រុយណេ ដារ៉ូសាលឹម (0,១១%)
**ប្រទេស កម្ពុជា (0,0៥%)**
ប្រទេសហ្វីជី (0,0៤%)
ប្រទេស ឥណ្ឌូណេស៊ី (0,៩៧%)
ប្រទេសសាធារណៈរដ្ឋប្រជាមានិតឡាវ (0,0៤%)
ប្រទេសម៉ាឡេស៊ី (0,៧0%)
ប្រទេស មីយ៉ានម៉ា (0,១៣%)
ប្រទេស ណេប៉ាល់ (0,0៤%)
ប្រទេស សិង្ហបូរី (0,៤១%)
ប្រទេស ថៃ (0,៥១%)
ប្រទេស តុងហ្វា (0,0១%)
ប្រទេស វៀតណាម (0,១៦%)
៦៩.0១៩ សន្លឹក (៣,១៧%)

**ភីតថ័រ ជ. ងុមប៊ូលូ (Peter J. Ngumbullu)**
**(ប្រទេសតាន់ហ្សាញ៉ា)**
*ភីតថ័រ ហ្គាកុនុ (Peter Gakunu) (ប្រទេសកេនយ៉ា)*
ប្រទេសអង់ហ្គូឡា (0,១៤%)
ប្រទេស បូស្វាវ៉ាណា (0,0៤%)
ប្រទេសប៊ូរូនឌី (0,0៥%)
ប្រទេសអេរិតទ្រា (0,0២%)
ប្រទេសអេត្យូពី (0,0៧%)
ប្រទេសហ្គាមប្បៀ (0,0៣%)
ប្រទេស កេនយ៉ា (0,១៤%)
ប្រទេសលេសូថូ (0,0៣%)
ប្រទេសម៉ាឡាវី (0,0៤%)
ប្រទេសម៉ូសាមបីក (0,0៦%)
ប្រទេសណាមិបៀ (0,0៧%)
ប្រទេសនីហ្សេរៀ (0,៨២%)
ប្រទេសស៊ីអ៊ីរ៉ា ឡេអូន (0,0៦%)
ប្រទេស អាហ្វ្រិកខាងត្បូង (0,៨៧%)
ប្រទេសសូដង់ (0,0៩%)
ប្រទេស ស្វាស៊ីឡិន (0,0៣%)
ប្រទេសតានហ្សាញ៉ា (0,១0%)
ប្រទេសជូហ្គានដា (0,0៩%)
ប្រទេសសាមបៀ (0,២៤%)
៦៥.២២១ សន្លឹក (៣,00%)

**វ៉ង្គ ហ្សាវយី (WANG Xiaoyi)**
*ជីអ៊ី ហ្វួងយ៉ុង (GE Huayong)*
ប្រទេសចិន
៦៣.៩៤២ សន្លឹក (២,៩៤%)

**ថមម៉ាស ម៉ូហ្ស័រ (Thomas Moser)** (ប្រទេសស្វីស)
*អងហ្សេស រ៉ាក់កូ (Andrzej Raczko) (ប្រទេសប៉ូឡូញ)*
ប្រទេស អាហ្សេរបាយហ្សាន (0,0៩%)
ប្រទេស សាធារណៈរដ្ឋ គីហ្ស៊ីស (0,0៥%)
ប្រទេស ប៉ូឡូញ (0,៦៤%)
ប្រទេស ស៊ែប៊ៀ និងម៉ុងធិនិហ្គ្រូ (0,២៣%)
ប្រទេស ស្វីស (១,៦១%)
ប្រទេស តាជីគីស្ថាន (0,0៥%)
ប្រទេស ទើកមិនីស្ថាន (0,0៥%)
ប្រទេស យូសបេគីស្ថាន (0,១៤%)
៦១.៨២៧ សន្លឹក (២,៨៤%)

**អាលេកសី វីម៉ូជីន (Aleksei V. Mozhin)**
*អង់ឌ្រេ លូស្ស៊ីន (Andrei Lushin)*
សហព័ន្ធរុស្ស៊ី
៥៩.៧0៤ សន្លឹក (២,៧៤%)

**អាបាស់ មីរ៉ាខរ (Abbas Mirakhor)**
**(សាធារណៈរដ្ឋឥស្លាម អ៊ីរង់)**
*ម៉ូហាម៉ាត់ ដៃរ៉ី (Mohammed Daïri) (ប្រទេស ម៉ូរ៉ុក)*
ប្រទេស អាហ្គានីស្ថាន់ (0,0៩%)
ប្រទេស អាលជីរៀ (0,៥៩%)
ប្រទេស ហ្គាណា (0,១៨%)
ប្រទេសអ៊ីរ៉ង់,សាធារណរដ្ឋឥស្លាម (0,៧0%)
ប្រទេស ម៉ូរ៉ុក (0,២៨%)
ប្រទេស ប៉ាគីស្ថាន (0,៤៩%)
ប្រទេស ទូនីស៊ៀ (0,១៤%)
៥៣.៦៦២ សន្លឹក (២,៤៧%)

**អេតឌូដូ លីយ៉ូ (Eduardo Lyo)** (ប្រទេសប្រេស៊ីល)
*រ៉ូប៊ែតតូ ស្តេនន័រ (Roberto Steiner) (ប្រទេសកូឡុបប៊ៀ)*
ប្រទេស ប្រេស៊ីល (១,៤១%)
ប្រទេស កូឡុមប៊ៀ (0,៣៧%)
ប្រទេស សាធារណៈរដ្ឋ ឌូមីនិខែន (0,១១%)
ប្រទេស អេក្វាដ័រ (0,១៥%)
ប្រទេស ហ្គួយ៉ាណា (0,0៥%)
ប្រទេស ហៃយទី (0,0៥%)
ប្រទេស ប៉ាណាម៉ា (0,១១%)
ប្រទេស ស៊ូរីណេម (0,0៥%)
ប្រទេស ទ្រីនិឌែដ និង តូបាហ្គូ (0,១៧%)
៥៣.៦៣៤ សន្លឹក (២,៤៦%)

**ប៊ី ភី មីស្រា (B.P. Misra)** (ប្រទេសឥណ្ឌា)
*អាម៉ាស់ ឧថុម ហេរ៉ាត់ (Amal Uthum Herat)*
*(ប្រទេសស្រីលង្កា)*
ប្រទេសបង់ក្លាដែស (0,២៦%)
ប្រទេស ពហុតាន (0,0១%)
ប្រទេស ឥណ្ឌា (១,៩៣%)
ប្រទេស ស្រីលង្កា (0,២0%)
៥២.១១២ សន្លឹក (២,៣៩%)

**អ៊ិកទ័រ អារច័ររ៉េស (Héctor R. Torres)**
**(ប្រទេសអាជិនធីណា)**
*ហ្សាវីយេ ស៊ីលវ៉ារ៉ូអេត (Javier Silva-Ruete) (ប្រទេសប៉េរូ)*
ប្រទេស អាជិនធិណា (0,៩៩%)
ប្រទេស បូលិវៀ (0,0៩%)
ប្រទេស ឈីលី (0,៤១%)
ប្រទេសប៉ារ៉ាហ្គាយ (0,0៦%)
ប្រទេស ប៉េរូ (0,៣១%)
ប្រទេសអ៊ុយរ៉ាហ្គាយ (0,១៥%)
៤៣.៣៩៥ សន្លឹក (១,៩៩%)

**ដាមីញ៉ាណ អុងដូ ម៉ាន (Damian Ondo Mañe)**
**(ប្រទេសអេក្វាឌ័រ ហ្គីតនី)**
*ឡូរៀន ឌុបប៊ិលយូ រូតាយីសៀរ (Laurean W. Rutayisire)*
*(ប្រទេសរវ៉ាន់ដា)*
ប្រទេសបេ៊ណាំង (0,0៤%)
ប្រទេស ប៊ឺគីណា ហ្វាសូ (0,0៤%)
ប្រទេស កាម៉ារ៉ូន (0,១0%)
ប្រទេស ខេប វើដ (0,0២%)
សាធារណរដ្ឋអាហ្វ្រិកកណ្តាល (0,0៤%)
ប្រទេស ឆាត (0,0៤%)
ប្រទេស កូម៉ូរូស (0,0២%)
ប្រទេស កុងហ្គូ សាធារណរដ្ឋប្រជាធិបតេយ្យ (0,២៦%)
ប្រទេស កុងហ្គោ សាធារណរដ្ឋ (0,0៥%)
ប្រទេស កូតឌីវ័រ (0,១៦%)
ប្រទេស ជីប៊ូទី (0,0២%)
ប្រទេស អេក្វាទ័រ ហ្គីតនី (0,0៣%)
ប្រទេស ហ្គាប៊ុង (0,0៨%)
ប្រទេស ហ្គីតនី (0,0៦%)
ប្រទេស ហ្គីនី ប៊ីសូ (0,0២%)
ប្រទេស ម៉ាដាហ្គាស្កា (0,0៧%)
ប្រទេស ម៉ាលី (0,0៥%)
ប្រទេស ម៉ូរីតានៀ (0,0៤%)
ប្រទេស ម៉ូរីធីយើស (0,0៦%)
ប្រទេស នីហ្គ័រ (0,0៤%)
ប្រទេស រវ៉ាន់ដា (0,0៥%)
ប្រទេស សៅតូម៉េ និង ប្រ៊ីនស៊ីប (0,0១%)
ប្រទេស សេណេហ្គាល់ (0,0៩%)
ប្រទេស តូហ្គូ (0,0៥%)
៣0.៧៤៩ សន្លឹក (១,៤១%)

ទាំងនេះមិនបានរាប់បញ្ចូលសន្លឹកឆ្នោតរបស់ប្រទេស ឡាយបេរៀ សូមាលី និង ហ្ស៊ីមបាវ៉េ ឡើយ ដែលតំណាងរបស់ប្រទេសទាំងនេះ ត្រូវបានគេព្យួរទុកសិនដោយសារ ពួកគេជំពាក់យ៉ាងយូរនូវបំណុលដែលហួសកាលកំណត់សង ចំពោះមូលនិធិរូបិយវត្ថុអន្តរជាតិ ។




Bernd Jonkmanns/laif/Aurora & Quanta Productions, Inc.

# ជំរុញ សេដ្ឋកិច្ច ឱ្យមានសុខភាពរឹងមាំ

កិច្ចការសំខាន់បំផុតរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) គឺការជំរុញកិច្ចសហប្រតិបត្តិការ ក្នុងផ្នែករូបិយវត្ថុអន្តរជាតិ និង លើកស្ទួយស្ថេរភាពសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅក្នុងបណ្តាប្រទេសជាសមាជិក និង នៅក្នុងពិភពលោក ដើម្បីជាមូលដ្ឋាន សំរាប់កំណើនសេដ្ឋកិច្ចប្រកបដោយចិរភាពដែលជាកត្តាដ៏សំខាន់បំផុតសំរាប់ការលូតលាស់ សេដ្ឋកិច្ចមានចិរភាពដើម្បីលើកស្ទួយជីវភាពរស់នៅ និង កាត់បន្ថយភាពក្រីក្រ ។ ការលើកតំកើងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺជាផ្នែកមួយដែលធ្វើឡើងក្នុងគោលបំណងជៀសវាងនូវវិបត្តិសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលអាចបំផ្លាញការងារ កាត់បន្ថយកំរិតចំណូល និងបង្កឱ្យមានក្តីឈឺចាប់ដ៏ធ្ងន់ធ្ងរចំពោះមនុស្សជាតិ ។ យ៉ាងណាមិញ ការងារនេះ ក៏ដើម្បីបញ្ចៀសនូវភាពយោលយោគក្នុងសកម្មភាពសេដ្ឋកិច្ច កំរិតអតិផរណាខ្ពស់ និង ការប្រែប្រួលខ្លាំងជ្រុលនៃអត្រាប្តូរប្រាក់ និង ទីផ្សារហិរញ្ញវត្ថុ ។ រាល់អស្ថេរភាពទាំងនេះ អាចបង្កើតឱ្យមានភាពមិនច្បាស់លាស់ និងធ្វើឱ្យប៉ះពាល់ដល់ការវិនិយោគរាំងស្ទះកំណើនសេដ្ឋកិច្ច និង ប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជន ។

ទីផ្សារសេដ្ឋកិច្ចដ៏ពុះកញ្ជ្រោល រមែងតែងតែរួមផ្សំទៅដោយអស្ថេរភាពក្នុងកំរិតណាមួយ និង ការផ្លាស់ប្តូរផ្នែករចនាសម្ព័ន្ធជាបន្តបន្ទាប់ ។ បញ្ហាប្រឈមរបស់អ្នកបង្កើតគោលនយោបាយទាំងឡាយ គឺការកាត់បន្ថយអស្ថេរភាពដោយមិនចាំបាច់ ឱ្យមានការប៉ះពាល់ដល់សមត្ថភាពនៃប្រព័ន្ធសេដ្ឋកិច្ចក្នុងការលើកស្ទួយជីវភាពរស់នៅ តាមរយៈការលើកស្ទួយផលិតភាព និង ប្រសិទ្ធភាពខ្ពស់ និង បង្កើតការងារច្រើនជាងមុន ។

តាមរយៈបទពិសោធន៏កន្លងមក បានបង្ហាញឱ្យឃើញថា បណ្តាប្រទេសដែលមានកំណើនសេដ្ឋកិច្ចខ្លាំង និង អត្រាការងារខ្ពស់ ហើយមានកំរិតអស្ថេរភាពសេដ្ឋកិច្ចទាបបំផុតនោះ គឺជាប្រទេសដែលអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច (គោលនយោបាយសារពើពន្ធ រូបិយវត្ថុ និង អត្រាប្តូរប្រាក់) បានត្រឹមត្រូវ អនុញ្ញាតិឱ្យទីផ្សារដំណើរការជាមួយនឹងការអនុវត្តន៏ គោល

ផ្សារទំនើបថ្មីៗដូចជាមួយនេះ នៅអានដ្រា ប្រ៉ាដេស ដែលកំពុងផុសឡើងទូទាំងប្រទេសឥណ្ឌា

នយោបាយផ្នែកនិយ័តកម្ម និង រចនាសម្ព័ន្ធ និង មានប្រព័ន្ធសុវត្ថិភាពសង្គមសមស្រប បើកចំហរទីផ្សារ សំរាប់ពាណិជ្ជកម្មអន្តរជាតិ ស្ថាបនានូវស្ថាប័នបង្កើតគោលនយោបាយសេដ្ឋកិច្ច និង និយ័តកម្មរឹងមាំ ជំរុញឱ្យមានការអភិវឌ្ឍន៏ប្រព័ន្ធហិរញ្ញវត្ថុរឹងមាំ ប្រមូលចងក្រង តាមដាន និង ផ្សព្វផ្សាយនូវទិន្នន័យដែលមានគុណភាពខ្ពស់ និង ប្រកាន់យកនូវអភិបាលកិច្ចល្អ ។

មូលនិធិរូបិយវត្ថុអន្តរជាតិ ជំរុញឱ្យមានស្ថេរភាពក្នុងប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិ តាមរយៈមុខងារសំខាន់ៗបីរបស់ខ្លួនរួមមាន :

***ការត្រួតពិនិត្យតាមដាន***（Surveillance）: មូលនិធិរូបិយវត្ថុអន្តរជាតិមានការទទួលខុសត្រូវចំពោះការត្រួតពិនិត្យលើប្រព័ន្ធរូបិយវត្ថុអន្តរជាតិ និង ការប្រតិបត្តិរបស់ប្រទេសជាសមាជិកនីមួយៗ ចំពោះកាតព្វកិច្ចក្នុងការអនុវត្តន៏គោលនយោបាយដែលនាំឱ្យមានកំណើនរៀបរយ និង ស្ថេរភាពនៃតំលៃជួយជំរុញឱ្យមានយន្តការប្តូរប្រាក់មានស្ថេរភាព និង ជៀសវាងមិនឱ្យមានការបំភ្លែអត្រាប្តូរប្រាក់ ព្រមទាំងផ្តល់ឱ្យមូលនិធិរូបិយវត្ថុអន្តរជាតិ នូវទិន្នន័យអំពីសេដ្ឋកិច្ច របស់ប្រទេសខ្លួន ។ មូលនិធិរូបិយវត្ថុអន្តរជាតិ អនុវត្តការទទួលខុសត្រូវនេះដោយធ្វើការតាមដានស្ថានភាពសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជុំវិញពិភពលោក និង ពិនិត្យមើលថា តើគោលនយោបាយក្នុងបណ្តាប្រទេសជាសមាជិកត្រឹមត្រូវទៅតាមទស្សនៈរបស់ជាតិ ក៏ដូចជាអន្តរជាតិដែរឬទេ ។ មូលនិធិរូបិយវត្ថុអន្តរជាតិ ជួយដាស់តឿនប្រទេសជាសមាជិកអំពីគ្រោះថ្នាក់ដែលអាចនឹងកើតឡើង ដែលអនុញ្ញាតឱ្យរដ្ឋាភិបាលប្រទេសទាំងនោះធ្វើការទប់ស្កាត់ទុកជាមុន ។

***ការផ្តល់ប្រាក់កម្ចី:*** មូលនិធិរូបិយវត្ថុអន្តរជាតិ ផ្តល់កម្ចីឱ្យបណ្តាប្រទេសដែលមានបញ្ហាលំបាកផ្នែកជញ្ជីងពាណិជ្ជកម្ម ។ គោលបំណងចំបងៗនៃការផ្តល់ប្រាក់កម្ចីទៅឱ្យបណ្តាប្រទេសដែលមានចំណូលទាប គឺដើម្បីជំរុញកំណើនសេដ្ឋកិច្ច និង ការកាត់បន្ថយភាពក្រីក្រ ។

***ជំនួយការបច្ចេកទេស និង ការបណ្តុះបណ្តាល:*** មូលនិធិរូបិយវត្ថុអន្តរជាតិ ជួយរដ្ឋាភិបាលជាសមាជិកក្នុងការអភិវឌ្ឍន៏ស្ថាប័នគោលនយោបាយ និង ឧបករណ៏គោលនយោបាយសេដ្ឋកិច្ចឱ្យបានរឹងមាំ ។

### ការត្រួតពិនិត្យតាមដាន ដែលកំពុងមានសកម្មភាព

ជាមួយនឹងសមាជិកភាពដែលសឹងតែមានលក្ខណៈជាសកល មូលនិធិរូបិយវត្ថុអន្តរជាតិបានផ្តល់ជាវេទិកាអន្តរជាតិមួយ ដែលសមាជិកទាំងអស់អាចពិភាក្សាអំពីការអភិវឌ្ឍន៏នៅក្នុងរង្វង់សេដ្ឋកិច្ចរបស់ពួកគេនីមួយៗ និង នៅក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចសកលលោក។ នៅក្នុងកំឡុងពេលប៉ុន្មានទសវត្សរ៏កន្លងមកនេះ ឧបសគ្គដ៏ធំមួយចំពោះស្ថេរភាពសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានកើតមានឡើងពីកំណើនទាំងបរិមាណ និង ភាពស្មុគស្មាញនៃទីផ្សារមូលធនអន្តរជាតិ ។ សកលភាវូបនីយកម្មហិរញ្ញវត្ថុ គឺជាការវិវត្តន៏មួយដែលត្រូវបាន ទទួលនូវការស្វាគមន៏ ។ វាបានផ្តល់នូវកាលានុវត្តភាពជាច្រើន ក្នុងការបង្កើតឱ្យមានលំហូរនៃមូលធនឯកជន ដើម្បីទ្រទ្រង់ការវិនិយោគ និង កំណើន នៅក្នុងបណ្តាប្រទេស ទាំងឡាយណាដែលមូលធនទាំងនោះ អាចនឹងត្រូវបានប្រើប្រាស់ប្រកបទៅដោយផលិតភាពខ្ពស់បំផុត ។ ជាគោលការណ៏ ការធ្វើសមាហរណកម្មទីផ្សារមូលធនអនុញ្ញាត ឱ្យបណ្តាប្រទេសទាំងអស់ធ្វើការកែតំរូវទៅនឹង សំពាធពីខាងក្រៅ ដោយមិនចាំបាច់ពឹងផ្អែកទៅលើជំនួយផ្លូវការនោះឡើយ ។

ប៉ុន្តែលំហូរនៃមូលធនក៏អាចជាប្រភពនៃការប្រែប្រួលឆាប់រហ័សដែរ បើយើងពិនិត្យមើលទៅលើបទពិសោធន៏ ជាពិសេសនៅក្នុងបណ្តាប្រទេសដែលមានទីផ្សារទើបនឹងងើបឡើង ។ "ពូជថ្មី" នៃវិបត្តិហិរញ្ញវត្ថុ កកើតឡើងពីការហូរចេញឆាប់រហ័សនៃមូលធនដែលមានលក្ខណៈពិបាក ក្នុងការគ្រប់គ្រងជាងអតុល្យភាពនៃគណនេយ្យចរន្តដែលជាប្រពៃណី មូលនិធិរូបិយវត្ថុអន្តរជាតិបានធ្វើការដោះស្រាយតាមរយៈសកម្មភាពផ្តល់កម្ចីរបស់ខ្លួន ។ ការទប់ស្កាត់លំហូរចេញនៃមូលធនទាមទារឱ្យមានវិធានការដើម្បីធ្វើការស្ថាបនាឡើងវិញ នូវទំនុកទុកចិត្តរបស់វិនិយោគិនដែលក្នុងករណីខ្លះរួមមានជំនួយខាងផ្នែកហិរញ្ញវត្ថុ ពីសំណាក់ស្ថាប័នអន្តរជាតិ ។

សកលភាវូបនីយកម្មហិរញ្ញវត្ថុ ក៏បានបង្កើតឱ្យមានគ្រោះថ្នាក់នៃការរីករាលដាល（Contagion）ដោយបង្កើតឡើងនូវច្រកថ្មីៗ បន្ថែមលើទំនាក់ទំនងពាណិជ្ជកម្មដែលធ្លាប់មានពីបុរាណមក ហើយតាមរយៈច្រកទាំងនោះរាល់បញ្ហារបស់ប្រទេសមួយអាចធ្វើឱ្យមានការប៉ះពាល់ដល់ប្រទេសដ៏ទៃទៀត និង អាចរីករាលដាលតាមរយៈប្រព័ន្ធសេដ្ឋកិច្ចសកលលោកទៀតផង ។

និន្នាការបច្ចុប្បន្នបានបង្ហាញឱ្យឃើញថា សកលភាវូបនីយកម្មសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងបន្តកើនឡើងថែមទៀត និង ទីផ្សារដែលទើបតែងើបឡើងថ្មីៗអាចក្លាយជាភាគមួយដែលរីកធំឡើងៗក្នុងសេដ្ឋកិច្ចពិភពលោក ។ ទីផ្សារដែលទើបតែងើបឡើងថ្មី ហើយធំៗដូចជា ឥណ្ឌា និង ចិន គឺពិតជាមានសារៈសំខាន់ជាប្រព័ន្ធជាពិសេស ។ ហើយចិរភាពនៃប្រជាពលរដ្ឋក្នុងប្រទេសឧស្សាហកម្ម នឹងមានការប្រែប្រួលតុល្យភាពរវាងការសន្សំ និង ការវិនិយោគជាអន្តរជាតិ អាចជំរុញឱ្យមានលំហូរនៃមូលធន ឆ្លងដែនច្រើនជាងមុន ។

ដើម្បីធ្វើការតាមដានឱ្យបានជាប់លាប់លើការវិវត្តន៏ទាំងនេះ មូលនិធិរូបិយវត្ថុអន្តរជាតិបាននិងកំពុងពង្រឹងការវិភាគ និង ការផ្តល់យោបល់របស់ខ្លួនតាមរយៈយន្តការត្រួតពិនិត្យឃ្លាំមើលដ៏តឹងរឹងនិងម៉ត់ចត់បំផុត ការពិនិត្យពិច័យលំអិតលើបញ្ហាអត្រាប្តូរប្រាក់ និង ការវិភាគដ៏ប្រសើរឡើងលើវិស័យហិរញ្ញវត្ថុ និរន្តភាពនៃបំណុល និង ការរីករាលដាលក្នុងតំបន់ និង សកលលោក ។ ដើម្បីពង្រឹងការងារទីផ្សារហិរញ្ញវត្ថុ និង ទីផ្សារមូលធន មូលនិធិរូបិយវត្ថុអន្តរជាតិបានអនុវត្តនូវវិធានការមួយចំនួន（សូមមើលប្រអប់ទំព័រទី ១៨）រួមមានការច្របាច់បញ្ចូលរាល់សកម្មភាពទាំងអស់របស់ខ្លួនទៅក្នុងផ្នែកទាំងនេះ ឱ្យស្ថិតនៅក្រោមនាយកដ្ឋានថ្មីមួយ ដែលនឹងក្លាយជាមជ្ឈមណ្ឌលជំនាញដ៏ឧដុង្គឧត្តមសំរាប់រាល់ទិដ្ឋភាពការងារទាំងអស់របស់ មូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុងវិស័យរូបិយវត្ថុ ហិរញ្ញវត្ថុ និង ទីផ្សារមូលធន ។ ការបង្កើនការយកចិត្តទុកដាក់លើការងារក្នុងវិស័យហិរញ្ញវត្ថុ និង ការធ្វើសមាហរណកម្មជាមួយការវិភាគម៉ាក្រូសេដ្ឋកិច្ចរបស់មូលនិធិរូបិយវត្ថុអន្តរជាតិគឺជាសសរគ្រឹះនៃយុទ្ធសាស្រ្តសំរាប់រយៈពេលមធ្យមរបស់នាយកគ្រប់គ្រង（សូមមើល ទំព័រទី ៧）។

### ប្រភេទនៃការត្រួតពិនិត្យតាមដាន

***ថ្នាក់ប្រទេស:*** ជាធម្មតាមូលនិធិរូបិយវត្ថុអន្តរជាតិធ្វើការពិគ្រោះយោបល់ម្តងក្នុងមួយឆ្នាំជាមួយប្រទេសជាសមាជិកនីមួយៗ អំពីគោលនយោបាយសេដ្ឋកិច្ចរបស់ប្រទេសទាំងនោះ។ ការពិគ្រោះយោបល់នេះត្រូវបានហៅថា "ការពិគ្រោះយោបល់មាត្រាទី៤" (Article IV consultations) ដែលជាតំរូវការក្រោមមាត្រាទី៤នៃមាត្រានានានៃកិច្ចព្រមព្រៀងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ការពិគ្រោះយោបល់ផ្តោតទៅលើគោលនយោបាយអត្រាប្តូរប្រាក់ សារពើពន្ធ និង រូបិយវត្ថុរបស់ប្រទេសជាសមាជិក ការវិវត្តន៏ផ្នែកជញ្ជីងទូទាត់ និង បំណុលបរទេស ឥទ្ធិពលរបស់គោលនយោបាយរបស់ប្រទេសនីមួយៗលើគណនីក្រៅប្រទេស ភាពប៉ះពាល់ក្នុងតំបន់ និង លើសកលលោកនៃគោលនយោបាយទាំងនេះ និង សញ្ញាណនៃភាពគ្រោះថ្នាក់ជាសក្តានុពល ។

នៅពេលដែលទីផ្សារហិរញ្ញវត្ថុជុំវិញពិភពលោក មានកំរិតសមាហរណកម្មខ្ពស់ឡើង ការឃ្លាំមើលរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ កាន់តែផ្តោតការយកចិត្តទុកដាក់ខ្លាំងឡើងលើគណនីមូលធន បញ្ហាក្នុងវិស័យហិរញ្ញវត្ថុ និង ធនាគារ ។ រាល់បញ្ហាស្ថាប័នដូចជា ឯករាជ្យភាពរបស់ធនាគារកណ្តាល ការធ្វើនិយ័តកម្មវិស័យហិរញ្ញវត្ថុ អភិបាលកិច្ចសាជីវកម្ម តម្លាភាព គោលនយោបាយ និង គណនេយ្យភាព ត្រូវបានក្លាយជាកម្ម

វត្ថុសំខាន់សំរាប់ការឃ្លាំមើលរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុនៅក្នុងបណ្តាប្រទេសដែលមានទីផ្សារ ទើបងើបឡើង និង ក្នុងបរិបទដែលប្រទេសជាសមាជិកធ្វើការផ្លាស់ប្តូរ ពីសេដ្ឋកិច្ចផែនការទៅសេដ្ឋកិច្ចទីផ្សារ ។

***ថ្នាក់តំបន់.*** ដើម្បីបំពេញបន្ថែមលើការពិគ្រោះយោបល់ជាមួយប្រទេសជាសមាជិក មូលនិធិរូបិយវត្ថុអន្តរជាតិ ក៏បានធ្វើការពិនិត្យលើគោលនយោបាយដែលត្រូវប្រកាន់យកក្រោមកិច្ចព្រមព្រៀងថ្នាក់តំបន់ ដូចជា នៅក្នុងសហភាពសេដ្ឋកិច្ច និង រូបិយវត្ថុអាហ្វ្រិកកណ្តាល សហភាពរូបិយប័ណ្ណការ៉ាបៀនខាងកើត តំបន់អឺរ៉ុប ព្រមទាំងសហភាពសេដ្ឋកិច្ច និង រូបិយវត្ថុអាហ្វ្រិចខាងលិច ។ ក្រៅពីនេះ មូលនិធិរូបិយវត្ថុអន្តរជាតិ កំពុងផ្តោតការយកចិត្តទុកដាក់បន្ថែមទៀត លើបញ្ហាដែលជាប្រយោជន៍រួមរបស់បណ្តាប្រទេសនៅក្នុងតំបន់មួយចំនួន (ដូចជាអាមេរិកកណ្តាល មជ្ឈឹមបូពា៌ ប្រទេសនានាជាកោះក្នុងមហាសមុទ្រប៉ាស៊ីហ្វិក និង អនុតំបន់អាហ្វ្រិក-សាហារ៉ា) ។ ការពិភាក្សាលើរបាយការណ៍របស់បុគ្គលិកមូលនិធិរូបិយវត្ថុអន្តរជាតិ អំពីប្រធានបទទាំងនេះ មិនត្រឹមតែអនុញ្ញាតអោយមានការពិចារណា លើគោលនយោបាយកំណត់នៅថ្នាក់តំបន់ប៉ុណ្ណោះទេ វាថែមទាំងផ្តល់ឱ្យមាននូវការវិភាគប្រៀបធៀបអំពីការអភិវឌ្ឍន៍ និង គោលនយោបាយទូទាំងតំបន់ ព្រមទាំងការវិភាគលើការរីកសាយភាយ ឬ ការចម្លងវិបត្តិក្នុងតំបន់ ។ ក្នុងកំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយមូលនិធិរូបិយវត្ថុអន្តរជាតិ ក៏បានចាប់ផ្តើមបោះពុម្ពផ្សាយផងដែរនូវលទ្ធផលសំខាន់ៗរបស់ខ្លួន អំពីការត្រួតពិនិត្យឃ្លាំមើលនៅក្នុងរបាយការណ៍ប្រចាំឆមាសស្តីអំពីទស្សនៈវិស័យសេដ្ឋកិច្ចក្នុងតំបន់ ។

***ថ្នាក់សកលលោក.*** ដើម្បីបំពេញបន្ថែមលើការត្រួតពិនិត្យឃ្លាំមើលថ្នាក់ប្រទេស និង ថ្នាក់តំបន់ មូលនិធិរូបិយវត្ថុអន្តរជាតិ តាមដានរាល់ស្ថានភាពរបស់សេដ្ឋកិច្ចសកលលោក គោលនយោបាយសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗនៅក្នុងបរិបទសកលលោក និង ការអភិវឌ្ឍន៍នានាក្នុងទីផ្សារមូលធនអន្តរជាតិ ។ នៅក្នុងការងារត្រួតពិនិត្យឃ្លាំមើលនេះ មូលនិធិរូបិយវត្ថុអន្តរជាតិ បានធ្វើការវាយតំលៃផងដែរ អំពីផលប៉ះពាល់សំខាន់ៗនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានលក្ខណៈជាសកលរាប់បញ្ចូលទាំងផ្នែកខ្លះៗ ដូចជា ទីផ្សារប្រេង និង ពាណិជ្ជកម្ម ។ របកគំហើញដ៏សំខាន់ៗបំផុតរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ត្រូវបានបោះពុម្ពផ្សាយពីរដងក្នុងមួយឆ្នាំ នៅក្នុងទស្សនៈវិស័យសេដ្ឋកិច្ចពិភពលោក (World Economic Outlook) និង របាយការណ៍ស្ថេរភាពនៃហិរញ្ញវត្ថុសកលលោក (Global Financial Stability Report) ដែលរក្សាទុកជាឯកសារសំរាប់ការពិភាក្សារបស់គណៈកម្មការរូបិយវត្ថុអន្តរជាតិ និង ហិរញ្ញវត្ថុ (IMFC) ។

ទស្សនៈវិស័យសេដ្ឋកិច្ចពិភពលោកនាខែ មេសា ឆ្នាំ ២០០៦ បានស្វាគមន៍នូវការរីកចំរើនខ្លាំង នៃសេដ្ឋកិច្ចសកលលោក ដោយបានកត់សំគាល់ថា ការរីកចំរើននោះកើតមានឡើងហួសពីការរំពឹងទុក និង មានមូលដ្ឋានទូលំទូលាយ ។ របាយការណ៍ស្តីអំពីស្ថេរភាពហិរញ្ញវត្ថុសកលលោក នាខែ មេសា ឆ្នាំ ២០០៦ បានគូសបញ្ជាក់ពីការកើនឡើងនៃភាពធន់ទ្រាំនៃប្រព័ន្ធហិរញ្ញវត្ថុសកលលោក ហើយក៏បានគូសបញ្ជាក់ផងដែរថា ការកើនឡើងនូវអតុល្យភាពជញ្ជីងទូទាត់ធំជាងមុនក្នុងសកលលោក បានបង្កើតជាហានិភ័យដូចគ្នានឹងបំណុលខ្ពស់នោះដែរជាពិសេសនៅក្នុងវិស័យគេហកិច្ច ឬ គ្រួសារ (Household Sector) ។

បន្ថែមលើការត្រួតពិនិត្យប្រចាំឆមាសនេះ ក្រុមប្រឹក្សាប្រតិបត្តិបានធ្វើកិច្ចពិភាក្សាក្រៅផ្លូវការជារឿយៗ អំពីការអភិវឌ្ឍន៍សេដ្ឋកិច្ចពិភពលោក និង ទីផ្សារ ។ ថ្នាក់គ្រប់គ្រងក៏ដូចជាមន្ត្រីថ្នាក់ខ្ពស់នានារបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ក៏បានចូលរួមផងដែរក្នុងកិច្ចពិភាក្សាទាំងឡាយស្តីអំពីទស្សនៈវិស័យសេដ្ឋកិច្ច និង គោលនយោបាយក្នុងចំណោមរដ្ឋមន្ត្រីហិរញ្ញវត្ថុ ទេសាភិបាលធនាគារកណ្តាល និង អ្នកតំណាងរបស់ពួកគេ ព្រមទាំងមន្ត្រីដ៏ទៃទៀតដែលមានលក្ខណៈជាក្រុម និង ក្នុងវេទិកាដែលមានទ្រង់ទ្រាយផ្សេងៗគ្នា ដូចជាបណ្តាប្រទេសឧស្សាហ៍កម្មធំៗទាំងប្រាំបី (G8) បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ទាំង ២៤ (G24) និង វេទិកាស្ថេរភាពហិរញ្ញវត្ថុ ។

**ចំណាត់ការមុន**

ការដាស់តឿនជាមុនអំពីការជិតកើតមានវិបត្តិណាមួយ គឺមិនទាន់គ្រប់គ្រាន់ទេក្នុងការទប់ស្កាត់នូវវិបត្តិណាមួយនោះ ចំណាត់ការទប់ស្កាត់ទាន់ពេលវេលាជាមុន ជាការចាំបាច់ ។ ជាងនេះទៅទៀត ទន្ទឹមនឹងការកើនឡើងនៃសមាហរណកម្មសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហើយហានិភ័យ និង ការរីករាលដាលនៃវិបត្តិទាំងឡាយ ការត្រួតពិនិត្យឃ្លាំមើល មិនត្រឹមតែត្រូវផ្តោតលើបណ្តាប្រទេសងាយទទួលរងនូវវិបត្តិនោះទេ ប៉ុន្តែត្រូវផ្តោតលើប្រព័ន្ធទាំងមូលផងដែរ ។ មូលនិធិរូបិយវត្ថុអន្តរជាតិ ដែលជាសំលេងឥតលំអៀងរបស់សហគមន៍អន្តរជាតិ មានតួរនាទីមួយយ៉ាងសំខាន់ សំរាប់ធ្វើការគូសបញ្ជាក់អំពីបញ្ហាប្រឈមមុខរបស់សេដ្ឋកិច្ចដែលពិភពលោកត្រូវដោះស្រាយ ។ ដោយសារបានការទទួលស្គាល់នូវតួរនាទីដ៏សំខាន់គ្មានពីរនេះ មូលនិធិរូបិយវត្ថុអន្តរជាតិ ត្រូវបានគេអំពាវនាវនៅក្នុងកិច្ចប្រជុំគណៈកម្មការរូបិយវត្ថុអន្តរជាតិ និង ហិរញ្ញវត្ថុ (IMFC) ក្នុងរដូវ ផ្ការីកឆ្នាំ ២០០៦ កន្លងទៅនេះឱ្យធ្វើចំណាត់ការថ្មីៗរួមទាំងការរៀបចំកិច្ចពិគ្រោះយោបល់ពហុភាគីដើម្បីលើកទឹកចិត្តដល់សកម្មភាពទាំងឡាយ ដែលកែតំរូវបញ្ហាអតុល្យភាពជញ្ជីងទូទាត់សកលលោក ។ នាយកគ្រប់គ្រងមូលនិធិរូបិយវត្ថុ

## លើកកំពស់ភាពរឹងមាំនៃប្រព័ន្ធហិរញ្ញវត្ថុ

ច្រកសំខាន់ៗរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ សំរាប់ការលើកកំពស់ភាពរឹងមាំនៃប្រព័ន្ធហិរញ្ញវត្ថុ នៅក្នុងប្រទេសជាសមាជិក គឺការតាមដានឃ្លាំមើលជាប្រចាំក្នុងលក្ខណៈទ្វេរភាគី និង ពហុភាគី ការរៀបចំគំរោងផ្តល់ប្រាក់កម្ចីរបស់ប្រទេសនីមួយៗ និង ជំនួយបច្ចេកទេស។ សៀវភៅវាយតំលៃវិស័យហិរញ្ញវត្ថុ (Financial Sector Assessment Handbook) ដែលបោះពុម្ពផ្សាយដោយមូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោកនៅក្នុងខែ កញ្ញា ឆ្នាំ ២០០៥ បានផ្តល់ពតិមានលើបញ្ហាសំខាន់ៗ និង ការអនុវត្តន៍ល្អៗ ក្នុងការវាយតំលៃប្រព័ន្ធហិរញ្ញវត្ថុ និង ការរៀបចំគោលនយោបាយសំរាប់ដោះស្រាយបញ្ហា។

មូលនិធិរូបិយវត្ថុអន្តរជាតិបានពង្រឹងដំណើរការតាមដានឃ្លាំមើល ដោយធ្វើការគ្រប់គ្រងបានស៊ីជំរៅលើបញ្ហាប្រព័ន្ធហិរញ្ញវត្ថុ ដល់ការស្វែងរកចំណុចខ្លាំង និង ចំណុចខ្សោយលើប្រព័ន្ធហិរញ្ញវត្ថុអោយបានប្រសើរជាង មុន ហើយបន្ថយភាពញឹកញាប់ និង បង្រួមប្រពលភាពនៃបញ្ហានានារបស់ប្រព័ន្ធហិរញ្ញវត្ថុ ដែលអាចកើតមានឡើង។

***កម្មវិធីដែលផ្តល់ការគាំទ្រដោយមូលនិធិរូបិយវត្ថុអន្តរជាតិ*** រួមមានវិធានការសំរាប់ធ្វើការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុរបស់ប្រទេសជាសមាជិក។ ជាការបន្ថែមលើការផ្តល់ជំនួយបច្ចេកទេស មូលនិធិរូបិយវត្ថុអន្តរជាតិ ជួយដល់ប្រទេសជាសមាជិកក្នុងការកំណត់ និង វិភាគបញ្ហានានានៃប្រព័ន្ធហិរញ្ញវត្ថុ ការរៀបចំយុទ្ធសាស្ត្រនានា សំរាប់ធ្វើកំណែទំរង់តាមប្រព័ន្ធ និង ការរៀបចំប្រព័ន្ធធនាគារឡើងវិញ និង ធានាអោយបានថា យុទ្ធសាស្រ្តទាំងនេះ មានដំណើរការស្របជាមួយ និង ត្រូវបានគាំទ្រដោយគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយ រចនាសម្ព័ន្ធផ្សេងៗទៀតផងដែរ។

***ជំនួយបច្ចេកទេស*** ដែលផ្តល់ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ ជួយប្រទេសជាសមាជិកក្នុងការអនុវត្តន៍ វិធានការសំខាន់ៗនានា ដែលអាចជួយពង្រឹងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុរបស់ពួកគេ ។ ជំនួយនេះ រាប់បញ្ចូលទាំង អនុសាសន៍ និង ការបណ្តុះបណ្តាលដើម្បីធ្វើអោយប្រសើរឡើងនូវការគ្រប់គ្រងផ្នែករូបិយវត្ថុ និង សារពើពន្ធ ការអភិវឌ្ឍន៍ទីផ្សារមូលធន និង ការប្តូររូបិយប័ណ្ណ ការតាក់តែងប្រព័ន្ធទូទាត់ប្រាក់ និង ការរៀបចំធានារ៉ាប់រង លើប្រាក់បញ្ញើ ការអភិវឌ្ឍន៍ក្របខណ្ឌច្បាប់សំរាប់ធនាគារ ក៏ដូចជាបទបញ្ញត្តិប្រុងប្រយ័ត្ន និង សមត្ថភាពនៃការគ្រប់គ្រង និង យុទ្ធសាស្រ្តសំរាប់រៀបចំប្រព័ន្ធធនាគារឡើងវិញ។

អន្តរជាតិ  បានប្រាប់ឱ្យដឹងថាមូលនិធិរូបិយវត្ថុអន្តរជាតិនឹងផ្តល់ជាក្របខ័ណ្ឌមួយសំរាប់រដ្ឋាភិបាលទាំងឡាយចូលរួមក្នុងដំណើរការពិគ្រោះយោបល់យ៉ាងសកម្មមួយ  អំពីផលវិបាកនៃការធ្វើសកម្មភាព និង ផលវិបាកនៃការមិនធ្វើសកម្មភាព ។

មេរៀនពីវិបត្តិនានាក្នុងទស្សវត្សឆ្នាំ ៩០ បានជំរុញឱ្យមូលនិធិរូបិយវត្ថុអន្តរជាតិធ្វើចំណាត់ការជាជំហ៊ាន១ដើម្បីផ្តោត  ការឃ្លាំមើលរបស់ខ្លួនទៅលើការទប់ស្កាត់នូវវិបត្តិទាំងនោះ ។ វិធានការទាំងនេះរួមមានការគាំទ្រក្នុងការឃ្លាំមើលថ្នាក់តំបន់ និង ថ្នាក់សកលលោក និង ការផ្តល់ជាដំបូន្មានដល់សមាជិករបស់ខ្លួនឱ្យបញ្ចូល "ធាតុស្រូបវិបត្តិ" ទៅក្នុងគោលនយោបាយ របស់ពួកគេដូចជា ការប្រើប្រាស់គោលនយោបាយសារពើពន្ធរឹតបន្តឹងក្នុងពេលវេលាល្អ  និង  ផ្តល់លទ្ធភាពបន្ធូរបន្ថយគោលនយោបាយថវិកាក្នុងគ្រាលំបាក  ការរក្សាកំរិតទុនបំរុងគ្រប់គ្រាន់  ប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និង មានមូលដ្ឋានទូលាយ  អត្រាប្តូរប្រាក់ទន់ភ្លន់ និង ប្រព័ន្ធសុវត្ថិភាពសង្គមមានប្រសិទ្ធភាពប្រសើរឡើង  ។  មូលនិធិរូបិយវត្ថុអន្តរជាតិ  ក៏បានបង្កើតនូវគំនិតផ្តួចផ្តើមសំខាន់១មួយចំនួនដូចខាងក្រោម ដើម្បីស្វែងរកដំណោះស្រាយជួយប្រទេសជាសមាជិកក្នុងការកាត់បន្ថយលទ្ធភាពធ្លាក់ទៅក្នុងវិបត្តិ:

• នៅក្នុងឆ្នាំ ១៩៩៩ ជាផ្នែកមួយនៃការឆ្លើយតបទៅនឹងវិបត្តិនៅអាស៊ី មូលនិធិរូបិយវត្ថុអន្តរជាតិ  និង  ធនាគារពិភពលោកបានបង្កើតនូវកម្មវិធីវាយតំលៃវិស័យហិរញ្ញវត្ថុ ( Financial Sector Assessment Program - FSAP ) ដែលផ្តល់ នូវការវាយតំលៃគ្រប់ជ្រុងជ្រោយទៅលើវិស័យហិរញ្ញវត្ថុនានារបស់បណ្តាប្រទេសជាសមាជិក  ។ របាយការណ៍នៃកម្មវិធីនេះ  បានជួយឱ្យប្រទេសជាសមាជិកធ្វើការកំនត់នូវចំណុចខ្លាំងហានិភ័យ និង ភាពងាយរងគ្រោះទាំងឡាយនៃប្រព័ន្ធហិរញ្ញវត្ថុរបស់គេ និង បង្កើតជាគោលនយោបាយដ៏ត្រឹមត្រូវ  ដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងនោះ  ។  មូលនិធិរូបិយវត្ថុអន្តរជាតិបានធ្វើការវាយតំលៃផងដែរ   ទៅលើមជ្ឈមណ្ឌលហិរញ្ញវត្ថុនានាដែលនៅក្រៅស្រុក  ដែលជាអ្នកទទួលខុសត្រូវលើផ្នែកដ៏ធំមួយនៃលំហូរហិរញ្ញវត្ថុនៅក្នុងពិភពលោក   ដែលជាកត្តាដ៏សំខាន់ក្នុងការនាំមកនូវស្ថេរភាពដល់ប្រព័ន្ធហិរញ្ញវត្ថុពិភពលោកទាំងមូល ។ បន្ថែមពីលើនេះទៀត មូលនិធិរូបិយវត្ថុអន្តរជាតិចូលរួមជាមួយនឹងកិច្ចខិតខំប្រឹងប្រែងជាអន្តរជាតិ  ក្នុងការប្រយុទ្ធប្រឆាំងការលាងលុយកខ្វក់  និង ហិរញ្ញប្បទានភាវរកម្ម ។

•  មូលនិធិរូបិយវត្ថុអន្តរជាតិក៏បានបង្កើត  និង  ជួយជំរុញយ៉ាងសកម្មផងដែរនូវបទដ្ឋាន និង ក្រមនៃការអនុវត្តន៏ល្អ១ ក្នុងការបង្កើតគោលនយោបាយសេដ្ឋកិច្ច ។ ទាក់ទងទៅនឹងបទដ្ឋានទិន្នន័យ ស្ថាប័ននេះបានបង្កើតនូវគំនិតផ្តួចផ្តើមមួយចំនួន ដើម្បីជំរុញឱ្យមាននូវស្ថិតិនៃប្រទេសជាសមាជិកអាចទុកចិត្តបាន ទាន់ពេលវេលា និង គ្រប់ជ្រុងជ្រោយ បើកចំហដល់សាធារណៈជន ជួយសមាជិកទីផ្សារទាំងអស់សំរាប់ធ្វើការសំរេចចិត្តដ៏ត្រឹមត្រូវលើការវិនិយោគ និង ដើម្បីកាត់បន្ថយនូវភាពងាយទទួលរងគ្រោះថ្នាក់ដែលអាចនាំដល់វិបត្តិ ។

• មូលនិធិរូបិយវត្ថុអន្តរជាតិ បានធ្វើឱ្យមានភាពប្រសើរឡើងនូវក្របខ័ណ្ឌក្នុងការវិភាគរបស់ខ្លួន   ដើម្បីកំនត់នូវភាពងាយរងគ្រោះដោយវិបត្តិផ្សេង១របស់ប្រទេសជាសមាជិក រួមទាំងតាមរយៈការវាយតំលៃលើភាពផុយស្រួយនៃតារាងតុល្យការ ចិរភាពនៃបំណុល និង ការគ្រប់គ្រងសាច់ប្រាក់ ព្រមទាំងត្រួតពិនិត្យទៅលើភាពត្រឹមត្រូវនៃសូចនាករហិរញ្ញវត្ថុទាំងឡាយ ។ ការវិភាគទាំងនេះមានគោលដៅពង្រឹងការផ្តល់យោបល់ផ្នែកគោលនយោបាយរបស់មូលនិធិរូបិយវត្ថុអន្តរជាតិជូនដល់ប្រទេសជាសមាជិកដើម្បីធ្វើឱ្យសេដ្ឋកិច្ចរឹងមាំមិនងាយទទួលរងនូវការវាយប្រហារ  ព្រមទាំងជួយប្រទេសទាំងនោះឱ្យចេះធ្វើការសំរេចចិត្តថាតើពួកគេអាចទូទាត់បំណុលក្រៅប្រទេស និងបំណុលសាធារណៈបានដោយមិនចាំបាច់ធ្វើការកែតំរូវធំដុំលើតុល្យភាព ចំណូល និង ចំណាយ ។

• មូលនិធិរូបិយវត្ថុអន្តរជាតិពង្រីកកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការលើកតំកើងអភិបាលកិច្ចល្អដែលជាកត្តាដ៏សំ ខាន់ក្នុងការនាំមកនូវលទ្ធផលសេដ្ឋកិច្ចដ៏រឹងមាំ ។ ផ្នែកសំខាន់១ដែលត្រូវផ្តោតលើនោះ  រួមមានការធ្វើឱ្យប្រសើរឡើងនូវ  ប្រសិទ្ធភាព  និង គណនេយ្យភាពក្នុងវិស័យសាធារណៈនិងប្រព័ន្ធហិរញ្ញវត្ថុនានា ។

• មូលនិធិរូបិយវត្ថុអន្តរជាតិបានបង្កើនចំណាប់អារម្មណ៏របស់ខ្លួន ទៅលើភាពងាយរងគ្រោះដែលទាក់ទងនិងវិស័យ  ពាណិជ្ជកម្ម  ដែលនៅតែជាបញ្ហាដល់ធ្ងន់ធ្ងរសំរាប់ប្រទេសក្រីក្របំផុតជាមួយនឹងកម្មវិធីគាំទ្រពីសំណាក់មូលនិធិរូបិយវត្ថុអន្តរជាតិ  ។  យន្តការសមាហរណកម្មពាណិជ្ជកម្មរបស់មូលនិធិរូបិយវត្ថុអន្តរជាតិមួយ ( Trade Integration Mechanism - TIM )  ធ្វើឱ្យធនធានអាចរំពឹងទុកមុនថាមានសំរាប់ប្រទេសជាសមាជិកនានាក្រោមកម្មវិធីឥណទានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ដើម្បីជួយដល់ប្រទេសកំពុងអភិវឌ្ឍក្នុងការដោះស្រាយនូវផលប៉ះពាល់រយៈពេលខ្លី  ទៅលើជញ្ជីងទូទាត់ដោយសារការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មពហុភាគី ។

• ដើម្បីផ្តល់ការគាំទ្រដល់បណ្តាប្រទេសដែលមានកំរិតចំណូលទាបហើយមិនចង់ ឬ មិនត្រូវការជំនួយហិរញ្ញវត្ថុពីមូលនិធិរូបិយវត្ថុអន្តរជាតិ កាលខែ តុលា ឆ្នាំ ២០០៥ មូលនិធិរូបិយវត្ថុអន្តរជាតិបានបង្កើត  "ឧបករណ៏គាំទ្រគោលនយោបាយ"  (Policy Support Instrument ) មួយឡើង ។ ឧបករណ៏ PSI នេះ ជួយប្រទេសទាំងនោះឱ្យចេះបង្កើតនូវកម្មវិធីសេដ្ឋកិច្ចដ៏មានប្រសិទ្ធភាព  និង  អនុញ្ញាតឱ្យពួកគេបង្ហាញអំពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការប្រកាន់យកនូវគោលនយោបាយត្រឹមត្រូវសំរាបគោលបំណងក្នុងស្រុក ឬ សំរាប់ជាសារចំពោះឥណទាយក និង អ្នកផ្តល់ជំនួយអន្តរជាតិ ។

•  ឧបករណ៏ថ្មីមួយទៀតកំពុងស្ថិតក្នុងការពិចារណា  ដើម្បីជួយមូលនិធិរូបិយវត្ថុអន្តរជាតិក្នុងការឆ្លើយតបនឹងបញ្ហាប្រឈម និង តំរូវការថ្មី១របស់ប្រទេសជាសមាជិកដែលមានទីផ្សារទើបលេចឡើងគឺ  យន្តការផ្តល់ឥណទានដែលមានកំរិតហិរញ្ញប្បទានខ្ពស់ជូនដល់បណ្តាប្រទេស ដែលមានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរឹងមាំបំណុលមានចីរភាព និង ប្រព័ន្ធរបាយការណ៏មានតម្លាភាព ប៉ុន្តែនៅជាប្រទេសងាយទទួលនូវវិបត្តិនៅឡើយ ។

**តម្លាភាពនៅក្នុងមូលនិធិរូបិយវត្ថុអន្តរជាតិ**

មូលនិធិរូបិយវត្ថុអន្តរជាតិបានផ្តោតការយកចិត្តទុកដាក់ផងដែរ  លើការធ្វើឱ្យប្រសើរឡើងនូវគណនេយ្យភាពរបស់ខ្លួន  តាមរយៈការបង្កើតការិយាល័យវាយតំលៃឯករាជ្យមួយ (សូមមើលទំព័រ ៣២) និង តាមរយៈការបង្កើនតម្លាភាពនៃប្រតិបត្តិការ និង ការសំរេចចិត្តរបស់ខ្លួននាមួយទសវត្សរ៏កន្លងមកនេះ  ។  នៅពេលដែលរក្សានូវតួនាទីរបស់ខ្លួនជាទីប្រឹក្សាសំងាត់សំរាប់ប្រទេសជាសមាជិក  មូលនិធិរូបិយវត្ថុអន្តរជាតិក្លាយជាស្ថាប័នមួយដែលមានលក្ខណៈបើកចំហ និង ទទួលខុសត្រូវខ្ពស់ ហើយជាប្រភពពតិមានដ៏ធំមួយសំរាប់សាធារណៈជនទូទៅ និង សំរាប់សមាជិកទីផ្សារមូលធនទាំងអស់ ។

ឥឡូវនេះ  មូលនិធិរូបិយវត្ថុអន្តរជាតិ  បោះពុម្ពផ្សាយនូវរាល់ឯកសារគោលនយោបាយស្ទើរតែទាំងអស់ដែលត្រូវបានរៀបរៀងឡើង  សំរាប់ក្រុមប្រឹក្សាប្រតិបត្តិ  និង ផ្សព្វផ្សាយពតិមានស្តីពីប្រតិបត្តិការណ៏  និង  ហិរញ្ញវត្ថុនៅលើគេហទំព័ររបស់ខ្លួន។ មូលនិធិរូបិយវត្ថុអន្តរជាតិ  ក៏បានផ្តល់ពតិមានកាន់តែច្រើនឡើងអំពីការត្រួតពិនិត្យលើគោលនយោបាយរបស់ប្រទេសជាសមាជិក  និង  អំពីកម្មវិធីគាំទ្រផ្សេង១របស់មូលនិធិរូបិយវត្ថុអន្តរជាតិ  ។ ទោះបីជាការចេញផ្សាយនូវរាល់ឯកសារទាក់ទងទៅនឹងប្រទេសជាសមាជិកទាំងអស់ទាមទារការយល់ព្រមពីប្រទេសជាសមាជិកនិមួយ១ តែក្នុងករណីភាគច្រើនយើងបានសន្មត់ថាមានការយល់ព្រម  ហើយឯកសារទាំងនោះ  និង  របាយការណ៏មួយចំនួនធំរបស់បុគ្គលិក ត្រូវបានបោះពុម្ពផ្សាយ ។ ■




Mauricio Lima/AFP/Getty Images

# ផ្តល់ជំនួយ នៅពេលមានបញ្ហា កើតឡើង

ទ បីទោះបីមូលនិធិរូបិយវត្ថុអន្តរជាតិ មានយន្តការត្រួតពិនិត្យតាមដានល្អ ហើយរដ្ឋាភិបាលអនុវត្តគោលនយោបាយសេដ្ឋកិច្ចបានត្រឹមត្រូវក្តី ក៏មិនប្រាកដថាវិបត្តិនឹងមិនកើតមានឡើងនោះទេ ។ ជាការពិត សេដ្ឋកិច្ចទីផ្សារយ៉ាងសកម្មមួយ រមែងតែងតែប្រឈមនឹងវិបត្តិម្តងម្កាល ។ ពេលនោះ មូលនិធិរូបិយវត្ថុអន្តរជាតិមានតួនាទីជួយបញ្ជៀសផលប៉ះពាល់នៃវិបត្តិនោះ និង បំព្រួញរយៈពេលនៃវិបត្តិអោយខ្លី តាមរយៈការផ្តល់យោបល់ផ្នែកគោលនយោបាយ និង ការគាំទ្រផ្នែកហិរញ្ញវត្ថុ ។ ការទប់ស្កាត់វិបត្តិជួនកាលតម្រូវអោយមានការសន្យាផ្តល់នូវធនធានច្រើនសន្ធឹកសន្ធាប់ពី សំណាក់មូលនិធិរូបិយវត្ថុអន្តរជាតិ ។ក្នុងករណីភាគច្រើនការវិនិយោគនេះបានផ្តល់នូវផ្លែផ្កា ។ឧទាហរណ៍ ប្រាក់កម្ចី របស់មូលនិធិរូបិយវត្ថុអន្តរជាតិចំនួន ២១ ពាន់លានដុល្លា ផ្តល់ជូនប្រទេសកូរ៉េ នៅខែ ធ្នូ ឆ្នាំ ១៩៩៧ មានទំហំធំធេងណាស់ ទោះក្នុងនិយាមណាក្តី ប៉ុន្តែជំនួយនោះបានស្តារនូវស្ថិរភាពហិរញ្ញវត្ថុឡើងវិញភ្លាមៗ នៅឆ្នាំ ១៩៩៨ ហើយនាំអោយមានកំណើនខ្លាំងនៅឆ្នាំបន្ទាប់ ។ ហើយកូរ៉េបានសងបំណុលជូនមូលនិធិរូបិយវត្ថុអន្តរជាតិមុនពេលកំណត់ ។ នេះគឺជាករណីនៃការគាំទ្រក្នុងទ្រង់ទ្រាយធំដែលមានលក្ខណៈសមស្រប និង ទទួលបានជោគជ័យ ។ មូលនិធិរូបិយវត្ថុអន្តរជាតិ បានដើរតួនាទីស្រដៀងគ្នានេះនៅក្នុងប្រទេសប្រេស៊ីលក្នុងឆ្នាំ ១៩៩៨ និង នៅប្រទេសទួរគី ក្នុងឆ្នាំ ២០០១ ។

ពាណិជ្ជករនានា នៅលើវេទិកានៃទីផ្សារទំនិញ (ដែលប្រគល់អោយក្នុងអនាគត និង ផលិតផល (វត្ថុធាតុដើម) នៅទីក្រុងសាវ ប៉ូឡូ ប្រទេសប្រេស៊ីល

## ហេតុអ្វីវិបត្តិសេដ្ឋកិច្ចកើតមានឡើង?

សំណាងអាក្រក់ គោលនយោបាយមិនល្អ ឬ ការគួបផ្សំនៃបញ្ហាទាំងពីរនេះបញ្ចូលគ្នាអាចបង្កើតអោយមានវិបត្តិជញ្ជីងទូទាត់ នៅក្នុងប្រទេសមួយ ពោលគឺជាស្ថានភាពមួយដែលប្រទេសនោះ មិនអាចស្វែងរកហិរញ្ញប្បទាន បានគ្រប់គ្រាន់នៅក្នុងលក្ខខណ្ឌ ដែលអាចទទួលយកបានដើម្បីទូទាត់អន្តរជាតិសុទ្ធ（Net international payments）។ ក្នុងករណីអាក្រក់បំផុត ការលំបាកនេះ អាចវិវត្តឈានទៅរកវិបត្តិ ។ រូបិយប័ណ្ណរបស់ប្រទេសនោះ អាចនឹងធ្លាក់ថ្លៃ ដល់អត្រាមួយ ដែលធ្វើអោយបាត់បង់នូវជំនឿទុកចិត្តលើតម្លៃរបស់រូបិយប័ណ្ណនោះ ហើយនាំអោយមានផលវិបាករំខាន និង បន្ថយបង្អាក់ដំណើរការសេដ្ឋកិច្ចក្នុងស្រុក ហើយបញ្ហានោះ នឹងរីករាលដាលដល់ប្រទេសដទៃទៀត ។

មូលហេតុនៃបញ្ហាទាំងនេះមានលក្ខណៈខុសៗគ្នា និង ស្មុគស្មាញ ។ ប៉ុន្តែ កត្តាសំខាន់ៗ រួមមានប្រព័ន្ធហិរញ្ញវត្ថុ ក្នុងស្រុកទន់ខ្សោយ ឱនភាពសារពើពន្ធធំ និងជាប្រចាំ បំណុលក្រៅប្រទេសមានកំរិតខ្ពស់ អត្រាប្តូរប្រាក់កំណត់ក្នុងកម្រិតមួយមិនសមស្រប គ្រោះធម្មជាតិ និង ជម្លោះប្រដាប់អាវុធ ។

កត្តាខ្លះក្នុងចំណោមកត្តាទាំងនេះ អាចប៉ះពាល់ផ្ទាល់ដល់គណនីពាណិជ្ជកម្មរបស់ប្រទេស ដោយកាត់បន្ថយការនាំចេញ ឬ បង្កើនការនាំចូល ។ កត្តាខ្លះទៀត អាចកាត់បន្ថយហិរញ្ញប្បទានសំរាប់ចម្លងការអន្តរជាតិ (International transactions) ឧទាហរណ៏ តាមរយៈមូលហេតុអ្នកវិនិយោគបាត់បង់ភាពជឿជាក់លើការវិនិយោគរបស់ពួកគេ នៅក្នុងប្រទេសនោះ នាំឱ្យផ្ញើលលក់ទ្រព្យសម្បត្តិច្រើនលើសលប់ និង ការហូរចេញភ្លាមៗនៃមូលធនក្រៅស្រុក ឬ "លំហូរចេញនៃមូលធន" ។

## ការផ្តល់ប្រាក់កម្ចីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិអាចជួយយ៉ាងដូចម្តេច

ការផ្តល់ប្រាក់កម្ចីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ មានគោលដៅផ្តល់នូវ "ដង្ហើម" ដល់ប្រទេសមានវិបត្តិនានា នៅពេលដែលប្រទេសទាំងនោះ អនុវត្តគោលនយោបាយសម្របសម្រួល និង កំណែទម្រង់ ផ្តោតលើការដោះស្រាយ បញ្ហាជញ្ជីងទូទាត់ និង ស្តារស្ថានភាពប្រទេសឡើងវិញ សំរាប់កំណើនសេដ្ឋកិច្ចរឹងមាំ ។ គោលនយោបាយទាំងនោះមានលក្ខណៈខុសៗគ្នា ទៅតាមកាលៈទេសៈរបស់ប្រទេសនីមួយៗ ជាពិសេស អាស្រ័យលើមូលហេតុ និង ឫសគល់នៃបញ្ហា ។ ឧបមាថា ប្រទេសមួយប្រឈមនឹងការធ្លាក់ចុះថ្លៃភ្លាមៗលើមុខទំនិញនាំចេញគន្លឹះមួយអាចត្រូវការជំនួយហិរញ្ញវត្ថុរហូតដល់ថ្លៃទំនិញនោះងើបឡើងវិញ ដើម្បីជួយសំរួលដល់ការលំបាកនៃការផ្លាស់ប្តូរភ្លាមៗ និងការកែតម្រូវយ៉ាងឆាប់រហ័ស ។ ប្រទេសរងគ្រោះពីការហូរចេញមូលធន គឺចាំបាច់ត្រូវដោះស្រាយនូវរាល់បញ្ហាដែលនាំទៅរកការបាត់បង់នូវជំនឿទុកចិត្ត របស់វិនិយោគិន ដូចជា អត្រាការប្រាក់ទាបពេក អត្រាប្តូរប្រាក់ខ្ពស់ ឱនភាពថវិការដ្ឋធំ បំណុលកើនឡើងឆាប់រហ័ស ឬ ប្រព័ន្ធធនាគារក្នុងស្រុកគ្មានប្រសិទ្ធភាព និង គ្រប់គ្រងមិនបានល្អ ។

ពីមុន ប្រទេសសមាជិកមួយ ទោះប្រឈមនឹងវិបត្តិ ឬ ក៏អត់ក្តី អាចទទួលប្រាក់កម្ចីបាន អាជ្ញាធររបស់ប្រទេសនោះ និង មូលនិធិរូបិយវត្ថុអន្តរជាតិ ត្រូវព្រមព្រៀងលើកម្មវិធីគោលនយោបាយសេដ្ឋកិច្ចមួយសមស្រប (សូមមើល "ការផ្តល់ប្រាក់កម្ចី និង លក្ខខណ្ឌ" ទំព័រទី ២២) ។ ដំណើរការកែសំរួលអាចមានការលំបាកច្រើន នៅក្នុង ករណីអវត្តមានហិរញ្ញប្បទានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។ ឧទាហរណ៏ ប្រសិនបើអ្នកវិនិយោគមិនចង់ទិញប័ណ្ណរដ្ឋាភិបាល (Government bond) ប្រទេសនោះ រដ្ឋាភិបាលនោះ គ្មានជំរើសណាផ្សេងក្រៅពីកាត់បន្ថយការ ប្រើប្រាស់ហិរញ្ញប្បទាន ដោយៈ ទី១.កាត់បន្ថយចំណាយ ឬ បង្កើនចំណូល ឬ ទី២. បោះពុម្ពក្រដាសប្រាក់ដើម្បីធ្វើហិរញ្ញប្បទានឱនភាពរបស់ខ្លួន ។ "ការរឹតបន្តឹងខ្សែក្រវ៉ាត់ "ដូចក្នុងករណីទី១ មានលក្ខណៈតឹងតែងខ្លាំង បើគ្មានកម្ចី ពីមូលនិធិរូបិយវត្ថុអន្តរជាតិ ។ ហើយក្នុងករណីទី ២ លទ្ធផលអាចជា "អតិផរណា" ដែលបង្ករការឈឺចាប់ដល់អ្នកក្រីក្រច្រើនបំផុត ។ ហិរញ្ញប្បទានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិអាចជួយសម្រាលការលំបាកក្នុងការអនុវត្តកំណែតម្រូវ បន្តិចម្តងៗ និងមានការពិចារណាដោយប្រយ័ត្នប្រយែង ។

## ដំណោះស្រាយវិបត្តិបំណុលក្រៅប្រទេស

បញ្ហាលំបាកផ្នែកជញ្ជីងទូទាត់ខ្លះ កើតឡើងដោយសារប្រទេសជាប់បំណុល( ដែលមិនអាចទ្រាំទ្របាន) ច្រើនពេក មានន័យថា បំណុលទាំងនោះមិនអាចធ្វើសេវា (សង) បាន ទោះក្រោមកន្សោមគោលនយោបាយដែលអាចអនុវត្តបានយ៉ាងណាក្តី ។ នៅក្នុងកាលៈទេសៈនេះ គេត្រូវស្វែងរកផ្លូវមួយសំរាប់ប្រទេសនោះ និង ឥណទាយក ដើម្បីកែប្រែរចនាសម្ព័ន្ធបំណុលឡើងវិញ ។ ប្រការនេះ រួមមានការបន្ធូរបន្ថយលក្ខខណ្ឌសងបំណុលដូចជា ការពន្យាពេលកំណត់នៃការសងបំណុល ឬ ការព្រមព្រៀងកាត់បន្ថយតម្លៃកំណត់នៃបំណុល ។

ដោយសហការជាមួយធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិបាន និង កំពុងធ្វើការកាត់បន្ថយបន្ទុក បំណុលរបស់ប្រទេសក្រីក្រដែលជំពាក់បំណុលធ្ងន់ធ្ងរ ឱ្យមកនៅក្នុងកំរិតមួយអាចទទួលសងបាន ក្រោមគំនិតផ្តួចផ្តើម លើកស្ទួយប្រទេសក្រីក្រជំពាក់បំណុលធ្ងន់ធ្ងរ (HIPC) និង គំនិតផ្តួចផ្តើមជំនួយលប់បំណុលពហុភាគី (MDRI) (មើលទំព័រ ២៩) ហើយបានបន្តជំរុញយន្តការដោះស្រាយវិបត្តិបំណុលរៀបរយរវាងប្រទេសនានា និងឥណទាយកឯកជន របស់ប្រទេសទាំងនោះ ។ មូលនិធិរូបិយវត្ថុអន្តរជាតិបានប្រកាន់យកតួនាទីដ៏សកម្មក្នុងការជួយជំរុញស្ថាប័នចេញផ្សាយមូលប័ត្រឯករាជ្យ ឱ្យទទួលយកកឋាខ័ណ្ឌស្តីពីចំណាត់ការរួម (Collective action clause - CACs) ដែលប្រការនេះនឹងទប់ស្កាត់ឥណទាយកតូចតាចភាគតិចក្នុងការរារាំងដល់កិច្ចព្រមព្រៀងកែទម្រង់រចនាសម្ព័ន្ធ ដែលក្នុងនោះ ឥណទាយកភាគច្រើនអនុម័តយល់ព្រមនៅក្នុងបញ្ហាសញ្ញាប័ណ្ណអន្តរជាតិលើគ្រប់ទីផ្សារ ។ ជាចំណែកមួយនៃលទ្ធផល កើតចេញពីកិច្ចប្រឹងប្រែងនេះ ការប្រើប្រាស់កឋាខ័ណ្ឌ CACs បានក្លាយជានិយាម ទីផ្សារនៅក្នុងការចេញសញ្ញាប័ណ្ណអន្តរជាតិក្រោមច្បាប់ទីក្រុងញ៉ូវយ៉ក ។ ហេតុដូច្នេះហើយ បរិមាណនៃការចេញផ្សាយមូលប័ត្រជាមួយកឋាខ័ណ្ឌ CACs ពី បណ្តាប្រទេសទីផ្សារថ្មីមានការកើនឡើងច្រើនចាប់តាំងពីឆ្នាំ ២០០៤ ។

នៅក្នុងការវិវត្តន៍នៅក្រៅមូលនិធិរូបិយវត្ថុអន្តរជាតិ គេពិនិត្យឃើញមានវឌ្ឍនភាពនៅក្នុងដំណើរការត្រួតពិនិត្យដើម្បីធានាគោលការណ៍លំហូរមូលធនមានចីរភាព និងការរៀបចំរចនាសម្ព័ន្ធបំណុលឡើងវិញសមស្របក្នុងទីផ្សារថ្មី គឺជាគំនិតផ្តួចផ្តើមដឹកនាំដោយវិស័យឯកជនដែលកំណត់ស្តង់ដារនៃការសន្យា និង ការទទួលខុសត្រូវសំរាប់ ឥណទាយិក ឬ អ្នកជំពាក់បំណុលដែលមានអធិបតេយ្យភាព និង ឥណទាយក ឬ អ្នកឱ្យខ្ចីប្រាក់ឯកជននៅក្នុងការការពារ និង ដំណោះស្រាយវិបត្តិហិរញ្ញវត្ថុរបស់ពួកគេ ។ ■




Dinka Spirovka/Bloomberg News/Landov

# ការត្រលប់មករក ភាពប្រក្រតី

មូលនិធិរូបិយវត្ថុអន្តរជាតិផ្តល់ជំនួយ ហិរញ្ញវត្ថុដល់ប្រទេសជាសមាជិក ដែលមានបញ្ហាខាងផ្នែកជញ្ជីងទូទាត់ ដើម្បីគាំទ្រដល់គោលនយោបាយកែលំអ និង កំណែទំរង់ រួមទាំងជំនួយសម្បទានសំរាប់ប្រទេសដែលមានប្រាក់ចំណូលទាបផងដែរ ។ ការធ្វើហិរញ្ញប្បទាន គឺធ្វើឡើងដើម្បីគាំទ្រដល់ជញ្ជីងទូទាត់ទូទៅ ជាជាងការផ្តល់ ឥណទានសំរាប់គោលបំណងពិសេស ឬ គំរោងផ្សេងៗ ដែលផ្តល់ហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍នានា ។ រាល់ជំនួយហិរញ្ញវត្ថុទាំងអស់របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ត្រូវបានទទួលការអនុម័តយល់ព្រមពីក្រុមប្រឹក្សាប្រតិបត្តិ (Executive Board) ។

បរិមាណទឹកប្រាក់កម្ចីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិមានការប្រែប្រួលគួរអោយកត់សំគាល់ ដែលការកើនឡើងខ្ពស់បំផុតគឺនៅដើមទសវត្សរ៍ឆ្នាំ ២000 ជាការឆ្លើយតបទៅនឹងការអាចទទួលបាន ក្នុងករណីពិសេស ពីមូលនិធិរូបិយវត្ថុអន្តរជាតិនូវធនធានដោយប្រទេសមានសេដ្ឋកិច្ចទីផ្សារធំៗ និង ទើបតែងើបឡើង ហើយកំពុងប្រឈមមុខ ជាមួយវិបត្តិគណនីមូលធន ។ ឥណទាន ដែលបានអោយខ្ចីសរុបរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ បានធ្លាក់ចុះយ៉ាងឆាប់រហ័សចាប់តាំងពីពេលនោះមក ដោយសារបរិដ្ឋានសកលល្អប្រសើរ បានអនុញ្ញាតិអោយប្រទេសដែលប្រើប្រាស់ នូវធនធានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិច្រើន អាចសងបំណុលទៅអោយមូលនិធិរូបិយវត្ថុអន្តរជាតិវិញ ។

ក្នុងប៉ុន្មានឆ្នាំកន្លងទៅនេះ មូលនិធិរូបិយវត្ថុអន្តរជាតិបានបង្កើតឧបករណ៏ប្រាក់កម្ចីជាច្រើន ឬ ហៅថា "កម្មវិធីឥណទាន" ដែលត្រូវបានគេរៀបចំឡើង ដើម្បីសំរបសំរួលទៅតាមកាលៈទេសៈពិសេសៗនៃប្រទេសជាសមាជិកភាព ដែលមានលក្ខណៈខុសៗគ្នា ។ប្រាក់កម្ចីអសម្បទានត្រូវបានគេផ្តល់អោយតាមរយៈកម្មវិធីឥណទានចំនួន ៤: កម្មវិធីឥណទានបំរុង ( Stand-by Arrangement-SBAs) កម្មវិធីឥណទានរយៈពេលវែង (Extended Fund Facility) កម្មវិធីឥណទានបំរុងសំរាប់បំពេញបន្ថែម

អ្នកដើរនៅក្រុងសូហ្វីយ៉ា ប្រទេសប៊ុលហ្គារី ។ កំណែទំរង់រចនាសម្ព័ន្ធនានានៅប្រទេសប៊ុលហ្គារី ឆ្ពោះទៅរកការកែលំអបរិយាកាសធ្វើជំនួញ ។

(Supplemental Reserve Facility) និង កម្មវិធីឥណទាន សំរាប់ធ្វើហិរញ្ញប្បទានសង ការខូចខាត (Compensatory Financing Facility) (សូមមើលតារាងទំព័រ ២៥)។ ប្រទេសនានា ដែលមានប្រាក់ចំណូលទាបអាចខ្ចីប្រាក់ ក្នុងអត្រាការប្រាក់សម្បទាន តាមរយៈកម្មវិធីឥណទានសំរាប់ ការកាត់បន្ថយភាពក្រីក្រ និង កំណើន (Poverty Reduction and Growth Facility-PRGF) ហើយប្រសិនបើជួបនូវវិបត្តិលើសពីលទ្ធភាពដែលអាចគ្រប់គ្រងបាន ត្រូវអនុវត្តតាមរយៈកម្មវិធីឥណទាន ទប់ស្កាត់វិបត្តិពីក្រៅ (External Shocks Facility-ESF) ។ កម្មវិធីឥណទានទប់ស្កាត់ វិបត្តិពីក្រៅនេះ ត្រូវបានគេរៀបចំឡើង សំរាប់ប្រទេសដែលមិនមានការគាំទ្រដោយកម្មវិធីឥណទាន សំរាប់ការកាត់បន្ថយភាពក្រីក្រនិងកំណើន(PRGF) ឬឧបករណ៍គាំទ្រគោលនយោបាយ (PSI) (សូមមើលទំព័រ ១៩)។ ឧបករណ៍គាំទ្រគោលនយោបាយដែលមានភាពប្រក្រតី (on-track PSI) អាចផ្តល់មូលដ្ឋានសំរាប់ការទទួលយក បានយ៉ាងឆាប់រហ័សនូវហិរញ្ញប្បទាន ពីកម្មវិធីឥណទានទប់ស្កាត់វិបត្តិពីក្រៅ (ESF) ប្រសិនបើមានវិបត្តិកើតមានឡើងទោះបីជាសិទ្ធិនោះ មិនមានជាស្វ័យប្រវត្តិក៏ដោយ ។ ប្រទេសជាសមាជិកដែលទើបតែឆ្លងផុតពីគ្រោះធម្មជាតិ និង សង្គ្រាមអាចធ្វើសំណើសុំជំនួយបន្ទាន់ពីមូលនិធិរូបិយវត្ថុអន្តរជាតិ និង អាចធ្វើទៅបានតាមអត្រាសម្បទានសំរាប់ប្រទេសដែលមានប្រាក់ចំណូលទាប។

នៅពេលដែលប្រទេសជាសមាជិកមិនមានតំរូវការជាបន្ទាន់ ដើម្បីដោះស្រាយបញ្ហាជញ្ជីងទូទាត់នោះទេ ប្រទេសនោះអាចចាត់ទុកកម្មវិធីឥណទានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិនេះ ជាការត្រៀមលក្ខណៈសំរាប់ពេលមានវិបត្តិដែលជាការផ្តល់សិទ្ធិភ្ជាប់នឹងលក្ខខណ្ឌលើការអនុវត្តនីគោលនយោបាយដ៏ជាក់លាក់នានា ក្នុងការដកប្រាក់ប្រសិនបើមានតំរូវការកើតឡើង។

នៅក្នុងឆ្នាំកន្លងទៅថ្មីៗនេះ ចំនួនឥណទានច្រើនបំផុតនៃប្រាក់កម្ចីត្រូវបានគេផ្តល់អោយតាមរយៈកម្មវិធី ឥណទានសំរាប់ការកាត់បន្ថយភាពក្រីក្រ និង កំណើន (PRGF) តែទោះជាយ៉ាងណាក៏ដោយចំនួនមូលនិធិដ៏ច្រើនបំផុតនេះ ត្រូវបានគេផ្តល់អោយតាមរយៈកម្មវិធីឥណទានបំរុង (SBA)។ នៅក្នុងបរិបទយុទ្ធសាស្ត្ររយៈពេលមធ្យមរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (សូមមើលទំព័រ ៧) ដែលអនុម័តដោយគណៈកម្មការរូបិយវត្ថុអន្តរជាតិ និង ហិរញ្ញវត្ថុ (IMFC) នៃក្រុមប្រឹក្សាភិបាល (Board of Governors) នៅក្នុងអង្គប្រជុំនិទាឃរដូវ ឆ្នាំ ២០០៦ គេបានធ្វើការពិចារណាបន្ថែមចំពោះលើឧបករណ៍ថ្មីមួយ ដើម្បីផ្តល់លទ្ធភាពខ្ពស់ក្នុងការទទួលហិរញ្ញប្បទាន ជាពិសេសនៅគ្រាមានអាសន្ន សំរាប់ប្រទេសដែលមានសេដ្ឋកិច្ចផ្អែកលើទីផ្សារដែលទើបតែងើបឡើង និង មានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរឹងមាំ បំណុលមាននិរន្តរភាព និង របាយការណ៍មានតម្លាភាព ប៉ុន្តែនៅមានភាពងាយរងគ្រោះដោយវិបត្តិនានា ។

ឥណទានអសម្បទានអាចមានការប្រែប្រួលទៅតាមអត្រាការប្រាក់ទីផ្សារ របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ដែលគេទទួលស្គាល់ថាជា "អត្រាមូលដ្ឋានក្នុងការកំណត់ការប្រាក់"។ អត្រាការប្រាក់មូលដ្ឋាននេះ ធ្វើឡើងដោយផ្អែកលើអត្រាការប្រាក់នៃសិទ្ធិដកប្រាក់ពិសេស (Special Drawing Right-SDR) ដែលត្រូវគេធ្វើការកែប្រែជារៀងរាល់សប្តាហ៍ទៅតាមអត្រាការប្រាក់រយៈពេលខ្លីៗ នៃទីផ្សាររូបិយវត្ថុអន្តរជាតិធំៗ ។ ប្រាក់កម្ចីធំៗត្រូវបង់កំរៃការប្រាក់ ឬ "កំរៃបន្ថែម"។

ចំនួនទឹកប្រាក់ដែលប្រទេសនីមួយៗអាចខ្ចីបាន មានការប្រែប្រួលទៅតាមប្រភេទនៃប្រាក់កម្ចី និង ត្រូវបានគណនាជាការគុណជាមួយនឹងកូតារបស់មូលនិធិរូបិយវត្ថុអន្តរជាតិសំរាប់ប្រទេសនីមួយៗ។ ដើម្បីធ្វើហិរញ្ញប្បទាន ដល់តំរូវការជញ្ជីងទូទាត់ក្នុងករណីពិសេស មូលនិធិរូបិយវត្ថុអន្តរជាតិក៏អាចផ្តល់ប្រាក់កម្ចីក្នុងចំនួនលើសពីការកំណត់ ។ មូលនិធិរូបិយវត្ថុអន្តរជាតិជំរុញអោយប្រទេសនានាធ្វើការសងប្រាក់វិញអោយបានឆាប់រហ័ស។ ទោះជា មូលនិធិរូបិយវត្ថុអន្តរជាតិមានតារាងពេលវេលាសំរាប់ធ្វើការសងប្រាក់ ប្រទេសជាសមាជិកទាំងអស់ត្រូវបានគេ សង្ឃឹមថា អាចធ្វើការសងប្រាក់វិញបានលឿនជាងពេលដែលបានកំណត់ ក្នុងតារាងពេលវេលាតាមដែលអាចធ្វើបាន។

**និន្នាការបែកខ្ញែកគ្នានៃឥណទានដែលមិនទាន់សង**

ឥណទានមិនទាន់សងនៃកំចីមិនសម្បទានរបស់ IMF ថយចុះ

(ពាន់លាន SDRs)




...នៅពេលដែល បង្កើននូវកំចីសម្បទានសំរាប់ប្រទេសដែលមានចំណូលតិចក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីនេះ




**កំណត់សំគាល់:** ទិន្នន័យរហូតដល់ចុងនៃឆ្នាំហិរញ្ញវត្ថុ (ថ្ងៃ ៣០ ខែមេសា) ។ ការថយចុះនៃឆ្នាំហិរញ្ញវត្ថុ ២០០៦ បណ្តាលមកពីការផ្តល់នៃជំនួយលុបបំណុលជាពហុភាគី នៅថ្ងៃទី ៦ មករា និង ២៨ មេសា ។

[១] កម្មវិធីឥណទានកាត់បន្ថយភាពក្រីក្រ និងកំណើន

**ទិន្នន័យ:** នាយកដ្ឋានហិរញ្ញវត្ថុរបស់ IMF

**លក្ខខណ្ឌក្នុងការផ្តល់ប្រាក់កម្ចីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ**

នៅពេលមានប្រទេសណាមួយខ្ចីប្រាក់ពីមូលនិធិរូបិយវត្ថុអន្តរជាតិ រដ្ឋាភិបាលរបស់ប្រទេសនោះត្រូវសន្យាពង្រឹងគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់ខ្លួននេះជាតំរូវការមួយដែលគេហៅថា "លក្ខខណ្ឌ"។ "លក្ខខណ្ឌ" ផ្តល់ជាការធានាដល់មូលនិធិរូបិយវត្ថុអន្តរជាតិថា ប្រទេសខ្ចីប្រាក់នឹងប្រើប្រាស់ប្រាក់កម្ចីដើម្បីដោះស្រាយបញ្ហាលំបាកផ្នែកសេដ្ឋកិច្ច និង មានលទ្ធភាពធ្វើការសងប្រាក់វិញបានទាន់ពេលវេលាដើម្បីអោយមូលនិធិនេះអាចយកទៅផ្តល់ជូនប្រទេសផ្សេងទៀតដែលត្រូវការ។

នៅក្នុងឆ្នាំថ្មីៗកន្លងទៅនេះ មូលនិធិរូបិយវត្ថុអន្តរជាតិ បានធ្វើការសំរួលលក្ខខណ្ឌ



David Butow/Redux/Redux Pictures

នៅជាយក្រុងកាប៊ុល ប្រទេសអាប់កានីស្ថាន ការខំប្រឹងប្រែងក្នុងការកសាងឡើងវិញ កំពុងដំណើរការ

ទាំងឡាយដែលបានភ្ជាប់ទៅនឹងការធ្វើហិរញ្ញប្បទានរបស់ខ្លួន ។ ក្រុមប្រឹក្សាភិបាល មូលនិធិរូបិយវត្ថុអន្តរជាតិ បានអនុម័តលើគោលការណ៍ ណែនាំថ្មីនៅក្នុងខែ កញ្ញា ឆ្នាំ ២០០២ ដោយសង្កត់ធ្ងន់ពីតំរូវការទៅលើលក្ខខណ្ឌគោលដៅម៉ាក្រូសេដ្ឋកិច្ចនានា និង ឧបករណ៍រៀបចំគោលនយោបាយសំខាន់ៗ និង ដើម្បីធ្វើការជំរុញភាពជាម្ចាស់លើកម្មវិធីគោលនយោបាយរបស់ ប្រទេសនីមួយៗ អោយបានខ្លាំងជាងមុន ។ ការពិនិត្យឡើងវិញថ្មីៗនេះ បានបង្ហាញអោយឃើញថា លក្ខខណ្ឌ មានលក្ខណៈផ្តោតជាងមុន ហើយ មានតែកម្មវិធីមួយចំនួនតូចប៉ុណ្ណោះដែលត្រូវបានបញ្ឈប់មុនពេលកំណត់ ។នយោបាយ ដែលបានទទួលយកដោយអ្នកប្រើប្រាស់ធនធានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ មិន គ្រាន់តែធ្វើការដោះស្រាយបញ្ហាជញ្ជីងទូទាត់បន្ទាន់នោះទេ ប៉ុន្តែថែមទាំងជួយរៀបចំ មូលដ្ឋានសំរាប់ការរីកចំរើន ផ្នែកសេដ្ឋកិច្ចអោយមាននិរន្តរភាពនៅក្នុងរយៈពេលវែង ដោយធ្វើអោយបានសំរេចនូវស្ថេរភាពសេដ្ឋកិច្ច ដែលមានភាពទូលំទូលាយជាងមុន ឧទាហរណ៍ដូចជា វិធានការដើម្បីទប់ស្កាត់ការរីករាលដាលនៃអតិផរណា ការកាត់ បន្ថយបំណុលសាធារណៈ ឬ ការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុ ។ គោលនយោបាយទាំងនោះ ក៏អាចដោះស្រាយបញ្ហា ឧបសគ្គនៃរចនាសម្ព័ន្ធចំពោះកំណើនល្អប្រសើរ ដូចជាតំលៃ និង សេរីភាវូបនីយកម្មពាណិជ្ជកម្ម ឬ ការធ្វើអោយអភិបាលកិច្ចប្រសើរឡើង ។

ជារួម គោលនយោបាយទាំងនេះក្លាយជា"កម្មវិធីគោលនយោបាយ"របស់ប្រទេស ដែលត្រូវបានចែងនៅ ក្នុងលិខិតបញ្ជាក់គោលបំណង ឬ អនុស្សារណៈនៃគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលភ្ជាប់មកជាមួយ នឹងសំណើរបស់ប្រទេសក្នុងការស្នើសុំហិរញ្ញប្បទាន ពីមូលនិធិរូបិយវត្ថុអន្តរជាតិ ។ គោលដៅពិសេសរបស់កម្មវិធី និង គោលនយោបាយដែលត្រូវបានអនុម័ត្តអាស្រ័យលើស្ថានភាពរបស់ប្រទេសនីមួយៗ ។ ទោះជាយ៉ាងណាក្តី គោលដៅសំខាន់បំផុតនៅក្នុងគ្រប់ករណីទាំងអស់គឺដើម្បីស្តារ និង រក្សាភាពទ្រាំទ្របាននៃជញ្ជីងទូទាត់ និង ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ដើម្បីធ្វើដំណើរឈានទៅរកការរីកចំរើនដែលប្រកបដោយនិរន្តរភាព និង គុណភាពខ្ពស់ ។

## តើការវាយតំលៃលើការប្រតិបត្តិកតព្វកិច្ចប្រព្រឹត្តិតាមដោយរបៀបណា?

ប្រាក់កម្ចីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ភាគច្រើនមានលក្ខណៈជាការបើកផ្តល់តាមដំណាក់ៗ ។ ការធ្វើបែបនេះអនុញ្ញាត្តិអោយមូលនិធិរូបិយវត្ថុអន្តរជាតិមានពេលវេលាធ្វើការត្រួតពិនិត្យមើលថា តើប្រទេសនេះកំពុងតែបន្តអនុវត្តធ្វើតាមការប្តេជ្ញាចិត្តរបស់ខ្លួនមុនពេលបើកផ្តល់នូវមូលនិធិនៃដំណាក់កាលបន្តទៀត ។ ការតាមដានកម្មវិធីផ្អែកលើឧបករណ៍ជាច្រើនប្រភេទផ្សេងៗគ្នា :

• **សកម្មភាពបឋមនានា** (Prior Actions): ជាវិធានការនានាដែលប្រទេសមួយបានយល់ព្រមទទួល មុនពេលក្រុមប្រឹក្សាប្រតិបត្តិរបស់ មូលនិធិរូបិយវត្ថុអន្តរជាតិផ្តល់ការយល់ព្រមផ្តល់ប្រាក់កម្ចី ឬ បញ្ចប់ ការពិនិត្យឡើងវិញលើកម្មវិធី (សូមមើលនៅខាងក្រោម) ។ វិធានការទាំងនេះ គឺដើម្បីធានាអោយបានថា កម្មវិធីមានគ្រឹះចាំបាច់ក្នុងការអនុវត្តន៏អោយបានជោគជ័យ ឬ ក៏អាចកែលំអទិសឡើងវិញ បន្ទាប់ពីមានការងាកចេញពីគោលនយោបាយដែលបានព្រមព្រៀងគ្នា ។ ជាឧទាហរណ៏សកម្មភាពបឋមរួមមាន ការកែលំអអត្រាប្តូរប្រាក់ អោយទៅដល់កំរិតមាននិរន្តរភាព ការលុបបំបាត់ចោលការកំណត់ថ្លៃ ឬ ការអនុម័តជាផ្លូវការលើថវិការដ្ឋាភិបាលដែលមានលក្ខណៈសមស្រប ជាមួយនឹងកម្មវិធីក្របខ័ណ្ឌសារពើពន្ធ ។

• **លក្ខណៈវិនិច្ឆ័យលទ្ធផលការងារ** (Performance Criteria) ជាលក្ខខណ្ឌជាក់លាក់នានាដែលត្រូវតែបំពេញអោយបានសម្រេច មុនពេលដែលចំនួនឥណទានដែលបានព្រមព្រៀងគ្នាត្រូវបានផ្តល់អោយ ។ មានលក្ខណៈវិនិច្ឆ័យលទ្ធផលការងារពីរប្រភេទ: លក្ខណៈវិនិច្ឆ័យបែបបរិមាណ (Quantitative Criteria) និង លក្ខណៈវិនិច្ឆ័យរចនាសម្ព័ន្ធ (Structure Criteria) ។ ***លក្ខណៈវិនិច្ឆ័យបែបបរិមាណ*** ជាធម្មតាសំដៅលើអញ្ញត្តិគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដូចជា ធនធានបំរុងអន្តរជាតិ រូបិយវត្ថុ និង ឥណទានសរុប តុល្យការសារពើពន្ធ ឬ ការខ្ចីប្រាក់ពីបរទេស ។ ឧទាហរណ៍ ដូចជា កម្មវិធីមួយអាចគិតរួមទាំង កំរិតអប្បបរមានៃធនធានបំរុងអន្តរជាតិសុទ្ធ កំរិតអតិបរិមានៃទ្រព្យសកម្មសុទ្ធក្នុងស្រុករបស់ធនាគារកណ្តាល ឬ កំរិតអតិបរិមានៃការខ្ចីប្រាក់របស់រដ្ឋាភិបាល ។ ***លក្ខណៈវិនិច្ឆ័យរចនាសម្ព័ន្ធ*** ត្រូវបានគេប្រើប្រាស់សំរាប់វិធានការរចនាសម្ព័ន្ធ ដែលមានសារៈសំខាន់ដល់ភាពជោគជ័យនៃកម្មវិធីសេដ្ឋកិច្ច ។ លក្ខណៈវិនិច្ឆ័យទាំងនេះ មានភាពខុសគ្នាពីកម្មវិធីមួយទៅកម្មវិធីមួយទៀត ប៉ុន្តែជាឧទាហរណ៏អាចរួមបញ្ចូល ទាំងវិធានការជាក់លាក់មួយចំនួន ដើម្បីពង្រឹងប្រតិបត្តិការផ្នែកហិរញ្ញវត្ថុ កំណែទំរង់ប្រព័ន្ធសន្តិសុខ សង្គម ឬ ការរៀបចំរចនាសម្ព័ន្ធវិស័យសំខាន់ៗ ឡើងវិញ ឧទាហរណ៏ ដូចជាថាមពលជាដើម ។

• លក្ខណៈវិនិច្ឆ័យបែបបរិមាណ អាចត្រូវបានគេធ្វើការបំពេញបន្ថែមដោយ**ការចង្អុលបង្ហាញទិសដៅ** (Indicative Targets) ។ ទិសដៅទាំងនេះជាញឹកញយត្រូវបានគេរៀបចំឡើងបន្ទាប់ពីការអនុវត្តន៏កម្មវិធី អស់រយៈពេលជាច្រើនខែ ហើយបន្ទាប់មកកែប្រែអោយទៅជាលក្ខណៈវិនិច្ឆ័យលទ្ធផលការងារ ដោយមានការកែតំរូវយ៉ាងត្រឹមត្រូវ នៅពេលដែលនិន្នាការសេដ្ឋកិច្ចមានភាពរឹងមាំល្អជាងមុន ។

• **លក្ខខណ្ឌវិនិច្ឆ័យរចនាសម្ព័ន្ធ** ត្រូវបានគេប្រើប្រាស់សំរាប់វិធានការណា ដែលយើងមិនអាចត្រួតពិនិត្យតាមដានអោយបានល្អិតល្អន់គ្រប់គ្រាន់ដើម្បីក្លាយជាលក្ខណៈវិនិច្ឆ័យលទ្ធផលការងារ ឬ សំរាប់ដំណាក់កាលខ្លីៗក្នុងដំណើរការកំណែទំរង់សំខាន់ៗ ។ ការធ្វើខុសនឹងលក្ខខណ្ឌវិនិច្ឆ័យទាំងនេះ មិនធ្វើអោយមានភាពរអាក់រអួលក្នុងការផ្តល់ហិរញ្ញប្បទានដោយមូលនិធិរូបិយវត្ថុអន្តរជាតិឡើយ ។

• ឧបករណ៏ពិនិត្យតាមដានដ៏សំខាន់មួយទៀតគឺ **កម្មវិធីត្រួតពិនិត្យឡើងវិញ** (Program Review) ដែលដើរតួជាឱកាស សំរាប់ការធ្វើការវាយតំលៃដ៏ទូលំទូលាយដោយក្រុមប្រឹក្សាប្រតិបត្តិ លើវឌ្ឍនភាពឈានទៅរកការសំរេចគោលដៅនានានៃកម្មវិធី ។ ការពិនិត្យឡើងវិញនេះ ត្រូវបានគេប្រើប្រាស់សំរាប់ធ្វើកិច្ចពិភាក្សាពីគោលនយោបាយ និង ណែនាំសំរាប់ការផ្លាស់ប្តូរដែលចាំបាច់នៅក្នុងពេលដែលមានការអភិវឌ្ឍន៏ថ្មីៗទៀត ។ ក្នុងករណីខ្លះ ប្រទេសមួយអាចធ្វើសំណើសុំធ្វើការលើកលែងចំពោះការប្រព្រឹត្តខុសពីលក្ខណៈវិនិច្ឆ័យលទ្ធផលការងារ ឧទាហរណ៏ ដូចជា នៅពេលដែលអាជ្ញាធរបានចាត់វិធានការធ្វើការកែតំរូវពីកំហុសនោះ រួចរាល់ហើយនោះ ។ ■

## មូលនិធិរូបិយវត្ថុអន្តរជាតិផ្តល់ឥណទានយ៉ាងដូចម្តេច : លក្ខខណ្ឌមួយចំនួននៃកម្មវិធីឥណទានហិរញ្ញវត្ថុនានា

### កម្មវិធីឥណទានបំរុង និង កម្មវិធីឥណទានរយៈពេលវែង

- **កម្មវិធីឥណទានបំរុង (Stand-by Arrangement)** (បង្កើតឡើងនៅឆ្នាំ ១៩៥២):
  ប្រើប្រាស់សំរាប់ដោះស្រាយការលំបាក ផ្នែកជញ្ជីងទូទាត់សំរាប់រយៈពេលខ្លី ឥណទានបំរុងនេះគឺសំរាប់រយៈពេលពី ១២ ទៅ ១៨ ខែ ដោយមានរយៈពេលវែងបំផុត ស្របច្បាប់គឺ ៣ ឆ្នាំ។
  **កំរិតទទួលប្រាក់កម្ចី:** ប្រចាំឆ្នាំ: ទទួលបាន ១០០ ភាគរយនៃកូតា, ការបូកបន្ថែម: ៣០០ ភាគរយ នៃកូតា ប្រើប្រាស់ប្រភពធនធានទាំងអស់ពីមូលនិធិរូបិយវត្ថុអន្តរជាតិនៅក្នុងគណនីធនធានទូទៅ។
  **បក្កភាព** (Maturities): (កាលកំនត់ត្រូវសង)/(កាលកំនត់ត្រូវសងជាកាតព្វកិច្ច: (២¼ – ៤ ឆ្នាំ) / (៣¼ – ៥ឆ្នាំ)។
  **ការគិតថ្លៃ** (Charges): អត្រាគិតថ្លៃជាមូលដ្ឋាន + ថ្លៃបន្ថែមដែលគិតពីលើកំរិតមូលដ្ឋាន ១០០ ចំនុចមូលដ្ឋាន (ស្មើ១ ភាគរយ) ចំពោះបរិមាណលើសពី ២០០ ភាគរយ នៃកូតា និង កំរិត ២០០ ចំនុចមូលដ្ឋាន (ស្មើ ២ ភាគរយ) ចំពោះ ៣០០ ភាគរយនៃកូតា។
  **លក្ខខណ្ឌ:** ប្រទេសជាសមាជិកត្រូវអនុម័តគោលនយោបាយដែលផ្តល់នូវទំនុកចិត្តថាបញ្ហាជញ្ជីងទូទាត់ នឹង ត្រូវបានដោះស្រាយក្នុងអំឡុងពេលសមហេតុសមផលមួយ។
  **ការទទួលបានប្រាក់កម្ចីបន្ថែម:** លើសពី ២៥ ភាគរយនៃកូតា គឺត្រូវអនុលោមទៅតាមលក្ខខណ្ឌតឹងតែងជាងនេះ (ដែលគេស្គាល់ថាជាលក្ខខណ្ឌនៃឥណទានកំរិតខ្ពស់ជាង)។
  **ដំណាក់កាលនិងការត្រួតពិនិត្យ:** ការបើកផ្តល់ប្រចាំត្រីមាសដោយពឹងផ្អែកទៅលើការពិនិត្យអង្កេតលក្ខណៈវិនិច្ឆ័យនៃលទ្ធផល និង លក្ខខណ្ឌផ្សេងៗទៀត។
- **កម្មវិធីឥណទានរយៈពេលវែង (Extended Fund Facility)** (បង្កើតឡើងឆ្នាំ ១៩៧៤):
  ប្រើប្រាស់សំរាប់ការផ្តល់ជំនួយ សំរាប់រយៈពេលវែង សំរាប់ការគាំទ្រដល់កំណែទំរង់រចនាសម្ព័ន្ធ ដើម្បីដោះស្រាយបញ្ហាជញ្ជីងទូទាត់ពាណិជ្ជកម្មក្នុង រយៈពេលវែង។
  **កំរិតទទួលប្រាក់កម្ចី:** ប្រចាំឆ្នាំ: ១០០ ភាគរយនៃ កូតា, ការបូកបន្ថែម: ៣០០ ភាគរយនៃកូតា សំរាប់ ការប្រើប្រាស់ប្រភពធនធានទាំងអស់ ពីមូលនិធិរូបិយវត្ថុអន្តរជាតិនៅក្នុងគណនីធនធានទូទៅ ។
  **បក្កភាព:** (កាលកំនត់ត្រូវសង)/(កាលកំនត់ត្រូវសងជាកាតព្វកិច្ច) ស្មើនឹង (៤½ – ៧ ឆ្នាំ) / (៤½ – ១០ឆ្នាំ)។
  **ការគិតថ្លៃ:** អត្រាគិតថ្លៃជាមូលដ្ឋាន + ថ្លៃបន្ថែមដែលគិតពីលើកំរិតមូលដ្ឋាន ១០០ ចំនុចមូលដ្ឋាន (ស្មើ ១ ភាគរយ) ចំពោះ បរិមាណលើសពី ២០០ភាគរយ នៃកូតា និង កំរិត ២០០ ចំនុចមូលដ្ឋាន (ស្មើ ២ ភាគរយ) ចំពោះ ៣០០ ភាគរយនៃកូតា។
  **លក្ខខណ្ឌ:** ប្រទេសជាសមាជិកត្រូវអនុម័តកម្មវិធីសំរាប់រយៈពេល ៣ ឆ្នាំ ជាមួយនឹងរបៀបវារៈរចនាសម្ព័ន្ធ និងដោយមានការផ្តល់នូវរបាយការណ៍លំអិត ប្រចាំឆ្នាំនៃគោលនយោបាយសំរាប់រយៈពេល ១២ ខែបន្ទាប់។
  **ដំណាក់កាល និងការត្រួតពិនិត្យ:** ការបើកផ្តល់ ប្រចាំត្រីមាស រឺ ឆមាសដោយពឹងផ្អែកទៅលើការពិនិត្យអង្កេតលក្ខណៈវិនិច្ឆ័យនៃលទ្ធផល និង លក្ខខណ្ឌផ្សេងៗទៀត។

### ឥណទានពិសេស (SPECIAL LOANS)

- **កម្មវិធីឥណទានទុនបំរុងបំពេញបន្ថែម (Supplemental Reserve Facility)** (បង្កើតឡើងឆ្នាំ ១៩៩៧):
  សំរាប់ផ្តល់ការជួយគាំទ្ររយៈពេលខ្លី ចំពោះប្រទេសជាសមាជិក ដែលមានបញ្ហាជញ្ជីងទូទាត់ដោយសារភាពរអាក់រអួល និង ការបាត់បង់នូវទំនុកចិត្តនៃទីផ្សារដែលកើតឡើងភ្លាមៗ ។ ឥណទានមានសំរាប់តែបំពេញបន្ថែមទៅលើកម្មវិធីឥណទានធម្មតាមួយ។
  **កំរិតទទួលប្រាក់កម្ចីធម្មតា:** គ្មាន; កម្មវិធីនេះមានសំរាប់តែការទទួលបាននូវប្រាក់កម្ចី ក្នុងករណីដែល ឥណទានធម្មតាត្រូវកើនលើសកំរិតកំណត់ប្រចាំឆ្នាំ រឺ កំរិតបន្ថែម។
  **បក្កភាព:** (កាលកំនត់ត្រូវសង)/(កាលកំនត់ត្រូវសងជាកតព្វកិច្ច) ស្មើនឹង (២ – ២½ ឆ្នាំ) / (២½ – ៣ឆ្នាំ)។
  **ការគិតថ្លៃ:** អត្រាគិតថ្លៃមូលដ្ឋាន + ៣០០ ចំនុចមូលដ្ឋាន (ស្មើ ៣ ភាគរយ) រហូតដល់កំរិតអតិបរិមា ៥០០ ចំនុចមូលដ្ឋាន (ស្មើ ៥ ភាគរយ) បន្ទាប់ពីរយៈពេល ២½ឆ្នាំ។
  **លក្ខខណ្ឌ:** កម្មវិធីត្រូវស្ថិតក្រោមយន្តការប្រទាក់ក្រឡាជាមួយនឹងគោលនយោបាយពង្រឹងការបាត់បង់ទំនុកចិត្តនៃទីផ្សារ។
  **ដំណាក់កាល និង ការត្រួតពិនិត្យ:** ឥណទានមានសំរាប់រយៈពេលមួយឆ្នាំ និងអាចទទួលបាននូវប្រាក់កម្ចី ដោយការបើកផ្តល់ចំនួនពីរដង រឺ ច្រើនជាងនេះ។
- **កម្មវិធីឥណទានសំរាប់ហិរញ្ញប្បទានសងការខូចខាត (Compensatory Financing Facility)** (បង្កើតឡើងឆ្នាំ ១៩៦៣)
  សំរាប់បំពេញការធ្លាក់ចុះនៃចំណូលពីការនាំចេញ និង សេវាកម្មរបស់ប្រទេសជាសមាជិក រឺក៏ការកើនឡើងនូវថ្លៃនាំចូលគ្រាប់ធញ្ញជាតិជាបណ្តោះអាសន្ន ដែលបណ្តាលមកពីព្រឹត្តិការណ៍ដែលហួសពីសមត្ថភាព គ្រប់គ្រងរបស់ប្រទេសជាសមាជិក។
  **កំរិតទទួលប្រាក់កម្ចី:** ជាអតិបរមាគឺ ៤៥ ភាគរយនៃកូតាសំរាប់ករណីនីមួយៗ ការធ្លាក់ចុះនៃការនាំចេញ និង ការឡើងថ្លៃខ្លាំងរបស់តម្លៃគ្រាប់ធញ្ញជាតិដែលនាំចូល និង កំរិតកំនត់ដែលបូកបញ្ចូលគ្នា គឺ ៥៥ ភាគរយ នៃកូតា។
  **បក្កភាព:** (កាលកំនត់ត្រូវសង)/(កាលកំនត់ត្រូវសងជាកតព្វកិច្ច) ស្មើនឹង (២¼ – ៤ ឆ្នាំ) / (៣¼ – ៥ឆ្នាំ)។
  **ការគិតថ្លៃ:** អត្រាគិតថ្លៃជាមូលដ្ឋាន ហើយមិនជាប់ទាក់ទងទៅនឹងការគិតបន្ថែមលើតំលៃធម្មតាទេ។
  **លក្ខខណ្ឌ:** ជាទូទៅអាចទទួលបានសំរាប់តែប្រទេសជាសមាជិកដែលកំពុងអនុវត្តកម្មវិធីឥណទានទុនបំរុងរួច រឺ ក៏នៅពេលដែលស្ថានភាពជញ្ជីងទូទាត់នៃប្រទេសនោះ មានការអនុវត្តន៏ជាទូទៅបានល្អជាទីពេញចិត្ត ដោយមិនគិតពីការធ្លាក់ចុះនៃការនាំចេញ និង ភាពលើសនៃការនាំចូល។
  **ដំណាក់កាល និងការត្រួតពិនិត្យ:** បើកផ្តល់អោយសំរាប់រយៈពេលអប្បបរមា ៦ ខែ និង អនុលោមទៅ តាមខចែងនៃការរៀបចំតាមដំណាក់កាលនីមួយៗ នៃកម្មវិធីឥណទាន ។
- **ជំនួយសង្រ្គោះបន្ទាន់ (Emergency Assistance)**
  **គ្រោះធម្មជាតិ** (បង្កើតឡើងឆ្នាំ ១៩៦២):
  សំរាប់ផ្តល់ជំនួយទាន់ពេលវេលាក្នុងរយៈពេលមធ្យម ទៅអោយប្រទេសជាសមាជិកដែលមានបញ្ហា ជញ្ជីងទូទាត់ដោយសារគ្រោះធម្មជាតិ ។
  **ក្រោយជំលោះ** (បង្កើតឡើងឆ្នាំ ១៩៩៥):
  សំរាប់ផ្តល់ជំនួយទាន់ពេលវេលាក្នុងរយៈពេលមធ្យម ទៅអោយប្រទេសដែលមានបញ្ហាជញ្ជីងទូទាត់ ដោយសារផលវិបាកកើតចេញពីភាពចលាចលនៃសង្រ្គាមស៊ីវិល រឺជំលោះប្រដាប់អាវុធឆ្លងកាត់ព្រំដែន។
  **កំរិតទទួលបានប្រាក់កម្ចី:** ២៥ ភាគរយនៃកូតា ទោះបីជាប្រាក់កម្ចីអាចច្រើនជាងនេះក្នុងករណីដោយឡែកណាមួយ។
  **បក្កភាព:** (កាលកំនត់ត្រូវសង)/(កាលកំនត់ត្រូវសងជាកតព្វកិច្ច): (មិនមានការទូទាត់សងឆាប់រហ័សទេ) / (៣¼ – ៥ឆ្នាំ)។
  **ការគិតថ្លៃ:** អត្រាគិតថ្លៃជាមូលដ្ឋាន មិនជាប់ទាក់ទងទៅនឹងការគិតបន្ថែមលើតំលៃធម្មតា និងមានលទ្ធភាពក្នុងការធ្វើឧបត្ថម្ភធន សំរាប់ការប្រាក់ចំពោះប្រទេសជាសមាជិកដែល មានចំណូលទាបក្នុងករណីមានធនធាន។
  **លក្ខខណ្ឌ:** ត្រូវបង្ហាញនូវកិច្ចខិតខំប្រឹងប្រែងសមហេតុសមផល ក្នុងការជំនះនូវបញ្ហាជញ្ជីងទូទាត់និង ផ្តោតទៅលើការកសាងសមត្ថភាពផ្នែកស្ថាប័ន និង រដ្ឋបាល ដើម្បីត្រួសត្រាយផ្លូវឆ្ពោះទៅដល់ការរៀបចំឥណទាន កំរិតខ្ពស់ជាងនេះ រឺក៏ការរៀបចំឥណទានក្រោមរូបភាពកម្មវិធីឥណទានសំរាប់ការកាត់បន្ថយភាពក្រីក្រ និង កំណើន ។ លក្ខខណ្ឌនានាសំរាប់ឥណទានសង្រ្គោះបន្ទាន់ក្រោយជំលោះ ក៏រួមបញ្ចូលផងដែរនូវការគាំទ្ររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ដែលជាផ្នែកមួយនៃកិច្ចខិតខំរួមគ្នារបស់អន្តរជាតិ ក្នុងគោលបំណងដើម្បីដោះស្រាយនូវផលអាក្រក់ដែលកើតឡើងដោយសារជំលោះ
  **ដំណាក់កាល និង ការត្រួតពិនិត្យ:** ជាទូទៅមិនមានទេ។

### ប្រាក់កម្ចីសំរាប់ប្រទេសជាសមាជិក ដែលមានចំណូលទាប (Loans for Low-income members)

- **កម្មវិធីឥណទានសំរាប់ការកាត់បន្ថយភាពក្រីក្រ និង កំណើន** (បង្កើតឡើងឆ្នាំ ១៩៩៩):
  សំរាប់ផ្តល់ជំនួយរយៈពេលវែងសំរាប់ប្រទេសដែលដែលមានបញ្ហាជញ្ជីងទូទាត់ជារចនាសម្ពន្ធ័ និង ស្មុគស្មាញ ដោយសំដៅលើវឌ្ឍនភាពជាមួយនឹងការកាត់បន្ថយភាពក្រីក្រ ដោយចិរភាព។
  **កំរិតប្រាក់កម្ចីទទួលបាន:** ១៤០ ភាគរយនៃកូតា ហើយក្នុងករណីដោយឡែកអាចទទួលបានរហូតដល់ ១៨៥ ភាគរយ។
  **បក្កភាព:** (កាលកំនត់ត្រូវសង)/(កាលកំនត់ត្រូវសងជាកាតព្វកិច្ច): (មិនមានការទូទាត់សងឆាប់រហ័សទេ) / (៥½ – ១០ឆ្នាំ)។
  **ការគិតថ្លៃ:** អត្រាការប្រាក់សម្បទាន, ក្នុងអត្រា ០,៥ នៃ ១ ភាគរយក្នុងមួយឆ្នាំ។ មិនមានយកកំរៃបន្ថែម លើតំលៃធម្មតាទេ។
  **លក្ខខណ្ឌ :** ផ្អែកទៅលើឯកសារយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រដែលបានរៀបចំដោយប្រទេសជាសមាជិកក្នុងដំណើរការចូលរួមចំណែក និង ធ្វើសមាហរ័ណកម្មគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច រចនាសម្ពន្ធ័ និង ការកាត់បន្ថយភាពក្រីក្រ។
  **ដំណាក់កាល និង ការត្រួតពិនិត្យ:** បើកផ្តល់អោយមួយឆមាស (រឺពេលខ្លះក្នុងមួយត្រីមាសម្តង) ដោយអាស្រ័យលើការពិនិត្យលក្ខណៈវិនិច្ឆ័យនៃការអនុវត្តន៏ និងការត្រួតពិនិត្យបញ្ចប់។
- **កម្មវិធីឥណទានសំរាប់ទប់ស្កាត់វិបត្តិពីខាងក្រៅ (Exogenous Shocks Facility-ESF)** (បង្កើតឡើងឆ្នាំ ២០០៥):
  ឥណទាននេះត្រូវបានអនុម័តយល់ព្រម ប៉ុន្តែមិនទាន់ផ្តល់មូលនិធិពេញលេញទេ។ ឥណទាននេះនឹងផ្តល់ការគាំទ្រផ្នែកគោលនយោបាយ និង ជំនួយហិរញ្ញវត្ថុ ជូនដល់ប្រទេសជាសមាជិកមានចំណូល ទាបដែលកំពុងប្រឈមនឹងវិបត្តិពីខាងក្រៅដូចជា ការប្រែប្រួលថ្លៃផលិតផល គ្រោះធម្មជាតិ និង ភាពរអាក់រអួល ក្នុងសកម្មភាពពាណិជ្ជកម្ម បណ្តាលមកពីព្រឹត្តការណ៏កើតមាននៅក្នុងប្រទេសជិតខាង។ ឥណទាននេះ សំរាប់ផ្តល់ជូនប្រទេសដែលមានសិទ្ធិទទួលយកនូវឥណទានសំរាប់ការកាត់បន្ថយភាពក្រីក្រ និងកំណើន ប៉ុន្តែមិនទាន់ចាប់ ផ្តើមអនុវត្តកម្មវិធីនេះនៅឡើយ ។ កម្មវិធីឥណទាននេះអាចមានរយៈពេលពីមួយឆ្នាំទៅពីរឆ្នាំ។
  **កំរិតទទួលប្រាក់កម្ចី:** ២៥ ភាគរយនៃកូតា កំរិតទទួលប្រាក់កម្ចីបន្ថែមគឺ ៥០ ភាគរយនៃកូតា។
  **បក្កភាព:** (កាលកំនត់ត្រូវសង)/(កាលកំនត់ត្រូវសងជាកតព្វកិច្ច): (មិនមានការទូទាត់សងឆាប់រហ័សទេ)/(៥½ – ១០ឆ្នាំ)។
  **ការគិតថ្លៃ:** ក្នុងអត្រា ០,៥ នៃ ១ ភាគរយក្នុងមួយឆ្នាំ។ មិនគិតកំរៃបន្ថែមលើតំលៃធម្មតាទេ។
  **លក្ខខណ្ឌ:** រៀបចំអោយបានរួចរាល់នូវយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រ និង កម្មវិធីសេដ្ឋកិច្ចលំអិត ។
  **ដំណាក់កាល និង ការត្រួតពិនិត្យ:** បើកផ្តល់មួយឆមាស រឺ មួយត្រីមាសម្តង ដោយអាស្រ័យលើការពិនិត្យលក្ខណៈវិនិច្ឆ័យនៃការអនុវត្តន៏ និង ការពិនិត្យបញ្ចប់។

## ជំនួយបច្ចេកទេស និង ការបណ្ដុះបណ្ដាល

# ការផ្ទេរចំណេះធ្វើ (Know-how)

មូលនិធិរូបិយវត្ថុអន្តរជាតិ ផ្ដល់សេវាប្រឹក្សា និង ការបណ្ដុះបណ្ដាល ដើម្បីជួយពង្រឹងការតាក់តែង និង ការអនុវត្តន៏គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយវិស័យហិរញ្ញវត្ថុនៅក្នុងបណ្ដាប្រទេសជាសមាជិក និង ជួយលើកស្ទួយសមត្ថភាពស្ថាប័នរបស់រដ្ឋាភិបាលប្រទេសទាំងនោះ ។ ការតាក់តែងនិងអនុវត្តគោលនយោបាយសេដ្ឋកិច្ចបានត្រឹមត្រូវតម្រូវឱ្យមានចំណេះធ្វើ និង ស្ថាប័នរដ្ឋាភិបាលមានប្រសិទ្ធិភាព ។ ជាពិសេសបណ្ដាប្រទេសកំពុងអភិវឌ្ឍន៏ជាច្រើនត្រូវការជំនួយដើម្បីបង្កើនជំនាញក្នុងការគ្រប់គ្រងសេដ្ឋកិច្ច ព្រមទាំងការផ្ដល់ប្រឹក្សាលើការរៀបចំគោលនយោបាយកំណែទំរង់ និង ការរៀបចំស្ថាប័នដែលត្រឹមត្រូវ និង អ្វីដែលដំណើរការល្អនៅតាមកន្លែងដ៏ទៃផ្សេងៗទៀត ។ ស្ថាប័នមូលនិធិរូបិយវត្ថុអន្តរជាតិ ផ្ដល់អាទិភាពលើការផ្ដល់ជំនួយដែលបំពេញនិងបង្កើននូវសកម្មភាពសំខាន់ៗ របស់ខ្លួនផ្សេងទៀត ពាក់ព័ន្ធនឹងការត្រួតពិនិត្យតាមដានស្ថេរភាពសេដ្ឋកិច្ច និង ការផ្ដល់ប្រាក់កម្ចី ។

តាមរយៈបេសកម្មរបស់បុគ្គលិកដែលបញ្ជូនពីទីស្នាក់ការកណ្ដាល ការផ្ដល់អ្នកឯកទេសរយៈពេលខ្លី ទីប្រឹក្សានៅនឹងកន្លែងនានា មជ្ឈមណ្ឌលជំនួយបច្ចេកទេសតំបន់ ក៏ដូចការបណ្ដុះបណ្ដាលជំនាញនៅនឹងកន្លែង ការបណ្ដុះបណ្ដាលនៅថ្នាក់ តំបន់ ឬ នៅទីស្នាក់ការកណ្ដាលរបស់ខ្លួន មូលនិធិរូបិយវត្ថុអន្តរជាតិ បានផ្ដល់ជំនួយបច្ចេកទេសតាមវិស័យ ស្នូលសំខាន់ៗ នៃសមត្ថកិច្ចជំនាញរបស់ខ្លួន (សូមមើលគំនូសបំព្រួញ) ។ វិស័យទាំងនេះរួមមាន ការតាក់តែង និង ការគ្រប់គ្រងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយរូបិយវត្ថុ ធនាគារកណ្ដាល ប្រព័ន្ធហិរញ្ញវត្ថុ ទីផ្សារ និង គោលនយោបាយអត្រាប្ដូរប្រាក់ ការគ្រប់គ្រងនយោបាយសារពើពន្ធ និង ហិរញ្ញវត្ថុសាធារណៈព្រមទាំងស្ថិតិម៉ាក្រូសេដ្ឋកិច្ច ស្ថិតិជញ្ជីងទូទាត់ ស្ថិតិសារពើពន្ធ និង ស្ថិតិហិរញ្ញវត្ថុ ។ ជំនួយទាំងនេះសុទ្ធតែផ្ដល់ជាប្រយោជន៏ដល់ប្រទេសជាសមាជិករបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ដោយមិនបាច់បង់ថ្លៃ លើកលែងតែប្រទេសដែលមានលទ្ធភាពទូទាត់សងវិញតែប៉ុណ្ណោះ ។ ជំនួយបច្ចេកទេសរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ប្រហែលជា ១/៣ ត្រូវបានផ្ដល់ដោយហិរញ្ញប្បទានពីខាងក្រៅ ។

នៅដើមទសវត្សរ៏រហូតដល់ពាក់កណ្ដាលទសវត្សរ៏ឆ្នាំ១៩៩០ ខណៈដែលមូលនិធិរូបិយវត្ថុអន្តរជាតិ បានពង្រីកសមាជិកភាពដោយបញ្ចូលបណ្ដាប្រទេសក្នុងអន្តរកាលដែលផ្លាស់ប្ដូរពីសេដ្ឋកិច្ចផែនការមកជាសេដ្ឋកិច្ចទីផ្សារ ជំនួយបច្ចេក ទេសរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ មានការរីកលូតលាស់យ៉ាងឆាប់រហ័ស ។ ថ្មីៗនេះការខិតខំប្រឹងប្រែងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុងការពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុទូទាំងពិភពលោក ក្នុងគោលបំណងកាត់បន្ថយនូវហានិភ័យនៃ វិបត្តិសេដ្ឋកិច្ចនានាក៏ដូចជាការកែលំអការគ្រប់គ្រង និង ការស្វែងរកដំណោះស្រាយវិបត្តិដែលកើតមាន បង្កើតអោយមាន តម្រូវការជំនួយបច្ចេកទេសថ្មីៗថែមទៀតពីសំណាក់បណ្ដាប្រទេស ដែលកំពុងតែស្វែងរកការប្រកាន់យកនិយាម និង ក្រមអន្តរជាតិសំរាប់ការគ្រប់គ្រងហិរញ្ញវត្ថុសារពើពន្ធ និង ស្ថិតិ ។ ភាគច្រើននៃជំនួយបច្ចេកទេសទាំងនេះធ្វើទៅតាមអនុសាសន៏ដែលជាលទ្ធផលនៃកម្មវិធី និង របាយការណ៏វាយតំលៃវិស័យហិរញ្ញវត្ថុ ដោយផ្ដោតទៅលើការអង្កេតនិយាម និង ក្រមទាំងឡាយ (Standards and Codes) ។ កិច្ចការរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ពាក់ព័ន្ធទៅនឹងមជ្ឈមណ្ឌលហិរញ្ញវត្ថុក្រៅប្រទេស និង ការប្រយុទ្ធប្រឆាំងនឹងការលាងលុយកខ្វក់ និង ការផ្ដល់ហិរញ្ញប្បទានបំរើឱ្យភេរវកម្មក៏ទាមទារផងដែរ ឱ្យមានជំនួយបច្ចេកទេសបន្ថែមទៀត ។

លើសពីនេះទៅទៀត ស្ថាប័នមូលនិធិរូបិយវត្ថុអន្តរជាតិ បានបង្កើនការខិតខំប្រឹងប្រែងបន្ថែមដោយធ្វើការសំរបសំរួលជាមួយអ្នកផ្ដល់ជំនួយបច្ចេកទេសទ្វេរភាគី និង ពហុភាគីដទៃទៀត ដើម្បីផ្ដល់ការប្រឹក្សាអំពីគោលនយោបាយឱ្យបាន ភ្លាមៗព្រមជាមួយគ្នានឹងការផ្ដល់ជំនួយប្រតិបត្តិការដល់បណ្ដាប្រទេស ដែលទើបតែងើបចេញពីជម្លោះប្រដាប់អាវុធ ។ ជាមួយគ្នានេះដែរ ក៏នៅមានតំរូវការជាបន្ទាន់ពីបណ្ដាប្រទេសដែលមានប្រាក់ចំណូលទាប សំណូមពរឱ្យជួយធ្វើការវិភាគអំពីលទ្ធភាពទ្រទ្រង់ចិរភាពបំណុល និង ជួយគ្រប់គ្រងកម្មវិធីកាត់បន្ថយបំណុលព្រមជាមួយនឹងការជួយធ្វើការតាក់តែង និង អនុវត្តកម្មវិធីទាំងឡាយដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់ ។ ដោយមានតម្រូវការកើនឡើងជាលំដាប់ មូលនិធិរូបិយវត្ថុអន្តរជាតិ បាននឹងកំពុងរៀបចំផ្ដល់ជំនួយបច្ចេកទេស និង វគ្គបណ្ដុះបណ្ដាលរបស់ខ្លួននៅថ្នាក់តំបន់ ។ ស្ថាប័នមូលនិធិរូបិយវត្ថុអន្តរជាតិ ជាមួយនឹងបណ្ដាអ្នកផ្ដល់ជំនួយដ៏ទៃទៀត បានដំណើរការមជ្ឈមណ្ឌលផ្ដល់ជំនួយបច្ចេកទេសក៏រិតតំបន់ចំនួនប្រាំដែលពីរ

### ការបែងចែកជំនាញបច្ចេកទេស

នាយកដ្ឋានផ្សេងៗនៅក្នុងមូលនិធិរូបិយវត្ថុ អន្តរជាតិផ្ដល់ជំនួយក្នុងជំនាញសេដ្ឋកិច្ចនានា ដែលប្លែកៗ (ឆ្នាំហិរញ្ញវត្ថុ ២០០៦)




**កំណត់សំគាល់:** គិតជាភាគរយនៃប្រភពធនធានទាំងមូលក្នុងប្រសិទ្ធភាពបុគ្គល-ឆ្នាំ (person-years)

**ទិន្នន័យ:** ការិយាល័យរបស់ IMF នៃការគ្រប់គ្រងជំនួយបច្ចេកទេស

មានទីតាំងនៅក្នុងតំបន់អាហ្វ្រិក មួយនៅក្នុងតំបន់ការ៉ាប៊ៀន មួយនៅតំបន់មជ្ឈឹមបូព៌ា និង មួយទៀត នៅតំបន់ប៉ាស៊ីហ្វិក ។

ការពិនិត្យឡើងវិញនូវរបាយការណ៍ថ្មីៗរបស់ការិយាល័យវាយតំលៃឯករាជ្យ ស្តីពីកម្មវិធីផ្តល់ជំនួយបច្ចេកទេស របស់មូលនិធិរូបិយវត្ថុអន្តរជាតិ គណៈកម្មការប្រតិបត្តិបានគូសបញ្ជាក់ថាជំនួយបច្ចេកទេស បានដើរតួនាទីយ៉ាងសំខាន់ឆ្លើយតបទៅនឹងតម្រូវការចម្រុះនៃបណ្តាប្រទេសជាសមាជិក ជាពិសេស សំរាប់ការតាក់តែង និងអនុវត្តគោលនយោបាយក៏ដូចជា ការកសាងសមត្ថភាព ។ គណៈកម្មការប្រតិបត្តិបានរកឃើញថា កត្តាសំខាន់ៗក្នុងការផ្តល់នូវជំនួយបច្ចេកទេសប្រកបដោយ ប្រសិទ្ធិភាពគឺសមត្ថភាពឆ្លើយតបឱ្យបានរហ័សដោយតម្រែតម្រង់ប្រឹក្សាសេចក្តី ទៅតាមស្ថានភាពជាក់ស្តែងរបស់ប្រទេសជាសមាជិកជាមួយនឹងការវិភាគដែលមានគុណភាពខ្ពស់ ។ យោងទៅតាមអនុសាសន៍របស់របាយការណ៍នេះ មូលនិធិរូបិយវត្ថុអន្តរជាតិ កំពុងតែកែលំអការកំណត់អាទិភាពជំនួយបច្ចេកទេស ដើម្បីធានាឱ្យបាននូវការចូលរួមពីអាជ្ញាធរប្រទេសនៅក្នុងដំណាក់កាលរៀបចំ និងត្រួតពិនិត្យតាមដានព្រមទាំងការត្រួតពិនិត្យលទ្ធផលឱ្យកាន់តែប្រសើរ ។

## ការបណ្តុះបណ្តាល

ស្ថាប័នមូលនិធិរូបិយវត្ថុអន្តរជាតិ ផ្តោតជាសំខាន់លើការកសាងជំនាញនៅក្នុងបណ្តាប្រទេសជាសមាជិក តាមរយៈការបណ្តុះបណ្តាល ។ វិទ្យាស្ថានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ជាអ្នកទទួលបណ្តុះបណ្តាលភាគច្រើននៃវគ្គបណ្តុះបណ្តាល ដែលផ្តល់ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ ។ វិទ្យាស្ថាននេះបណ្តុះបណ្តាលមន្ត្រីជាច្រើនពីបណ្តាប្រទេសជាសមាជិកតាមរយៈកម្មវិធីសិក្សា និង សិក្ខាសាលាលើវិស័យសំខាន់ៗសំរាប់ការគ្រប់គ្រងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយវិស័យហិរញ្ញវត្ថុសារពើពន្ធ និង វិស័យក្រៅស្រុក ។ ការបណ្តុះបណ្តាលនេះធ្វើឡើងដោយបុគ្គលិករបស់វិទ្យាស្ថាន និងនាយកដ្ឋាន ផ្សេងទៀតរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ហើយជួនកាលទទួលការគាំទ្រពីជំនាញការ និង សាស្ត្រាចារ្យពីខាងក្រៅ ។ ការដាក់ពាក្យសុំចូលរៀនរបស់មន្ត្រីនានាដែលមកពីប្រទេសកំពុងអភិវឌ្ឍន៍ និង ប្រទេសក្នុងអន្តរកាលត្រូវបានផ្តល់អាទិភាពខ្ពស់ ។

បន្ថែមលើការបណ្តុះបណ្តាលធ្វើឡើងនៅទីស្នាក់ការកណ្តាលនោះ មូលនិធិរូបិយវត្ថុអន្តរជាតិ បានបើកវគ្គសិក្សា និង សិក្ខាសាលានៅតាមវិទ្យាស្ថាននានា និងកម្មវិធីនានានៅតាមតំបន់ ។ បច្ចុប្បន្ននេះ មានមជ្ឈមណ្ឌលថ្នាក់តំបន់ចំនួនបួនៈ មជ្ឈមណ្ឌលបណ្តុះបណ្តាលរួមថ្នាក់តំបន់សំរាប់អាមេរិកឡាទីននៅប្រទេសប្រេស៊ីល វិទ្យាស្ថានរួមអាហ្វ្រិកនៅប្រទេសទុយនេស៊ី វិទ្យាស្ថានបណ្តុះបណ្តាលថ្នាក់តំបន់របស់មូលនិធិរូបិយវត្ថុអន្តរជាតិសិង្ហបូរី នៅប្រទេសសិង្ហបូរី និង វិទ្យាស្ថានរួមទីក្រុងវីយែននៅប្រទេសអូទ្រីស ។ លើសពីនេះទៀត មូលនិធិរូបិយវត្ថុអន្តរជាតិ បានរៀបចំដាក់បញ្ចូលនូវកម្មវិធីបណ្តុះបណ្តាល ដោយរួមសហការជាមួយប្រទេសចិន និង មូលនិធិរូបិយវត្ថុអារ៉ាប់ ( Arab Monetary Fund )ផងដែរ ។

នៅក្នុងឆ្នាំសារពើពន្ធឆ្នាំ ២០០៦ វិទ្យាស្ថានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ដោយមានការជួយជ្រោមជ្រែងពី នាយកដ្ឋានដទៃទៀតរបស់មូលនិធិរូបិយវត្ថុអន្តរជាតិបានបើកវគ្គសិក្សាចំនួន ១៤៣ ហើយមានមន្ត្រីចូលរួមជិត ៤៦០០ នាក់ ។ ភាគច្រើននៃវគ្គសិក្សាទាំងនេះ ត្រូវបានធ្វើឡើងនៅតាមវិទ្យាស្ថានបណ្តុះបណ្តាលថ្នាក់តំបន់ទាំងអស់ ។ ការបណ្តុះបណ្តាលធ្វើឡើងនៅទីស្នាក់ការកណ្តាលក្នុងទីក្រុងវ៉ាស៊ីនតោន រួមមានវគ្គសិក្សារយៈពេលវែងដែលនៅតែដើរតួនាទីយ៉ាង សំខាន់ហើយមានបរិមាណប្រហែលជាមួយភាគបីនៃពេលវេលារួមគិតជាសប្តាហ៍របស់អ្នកចូលរួម ។ ក្រៅពីនោះវគ្គសិក្សាបានធ្វើឡើងតាមទីតាំងនៅក្រៅប្រទេស ដែលមិនមែនជាបណ្តាញថ្នាក់តំបន់របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ដោយភាគច្រើនជាសហប្រតិបត្តិការរវាងវិទ្យាស្ថានមូលនិធិរូបិយវត្ថុអន្តរជាតិ ជាមួយនឹងកម្មវិធីបណ្តុះបណ្តាលថ្នាក់ជាតិ និង ថ្នាក់តំបន់ ហើយថែមទាំងមានការបណ្តុះបណ្តាលពីចម្ងាយផងដែរ ។ ■



Gregg Newton for IMF

ការបណ្តុះបណ្តាលនៅវិទ្យាស្ថានមូលនិធិរូបិយវត្ថុអន្តរជាតិ នៅក្រុងប្រាស៊ីល្យេ ប្រទេសប្រេស៊ីល

### កំណែទម្រង់ប្រព័ន្ធទូទាត់តំបន់នៅអាហ្វ្រិក

ជាផ្នែកមួយនៃយុទ្ធសាស្ត្រកំណែទំរង់វិស័យហិរញ្ញវត្ថុរបស់ខ្លួន ប្រទេសបូស្វាន់ណា ហ្គាណា ណាមីប៊ី សេរ៉ាឡេអូន និង ស្វាហ្ស៊ីឡែន កំពុងតែធ្វើទំនើបភាវូបនីយកម្មលើប្រព័ន្ធទូទាត់ប្រាក់ និង សងប្រាក់របស់ខ្លួន ។ ដោយមានការផ្តល់មូលនិធិពីរាជរដ្ឋាភិបាលជប៉ុន នាយកដ្ឋានរូបិយវត្ថុ និង ប្រព័ន្ធហិរញ្ញវត្ថុរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ បានបង្កើតការិយាល័យទីប្រឹក្សាផ្នែកប្រព័ន្ធទូទាត់ប្រាក់ថ្នាក់តំបន់មួយនៅប្រទេសបូស្វាន់ណា ដើម្បីជួយដល់បណ្តាប្រទេសទាំងនោះក្នុងការធ្វើទំនើបភាវូបនីយកម្មដំណើការនេះ ។ ទីប្រឹក្សារបស់មូលនិធិរូបិយវត្ថុអន្តរជាតិ កំពុងធ្វើការជាមួយអាជ្ញាធរនៅក្នុងប្រទេសទាំងនោះក្នុងគោលបំណងៈ

- បង្កើតច្បាប់ ដើម្បីគាំទ្រដល់ប្រព័ន្ធទូទាត់ចំណាយថ្មីនេះ ។
- អនុវត្តនូវប្រព័ន្ធជំរះមូលប្បទានប័ត្រតាមប្រព័ន្ធអេឡិចត្រូនិក ការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក និង ប្រព័ន្ធសងប្រាក់ដុលតាមពេលជាក់ស្តែង (Real Time Gross Settlement- RTGS) ព្រមទាំងមានយន្តការ និង ប្រព័ន្ធផ្ទេរប្រាក់ដ៏ទៃទៀតៗតាមប្រព័ន្ធអេឡិចត្រូនិក ។
- បង្កើតជានិយាម វិធានបទបញ្ញត្តិ និង នីតិវិធីដែលទាក់ទងទៅនឹងសេវាកម្មប្រព័ន្ធទូទាត់ផ្សេងៗទៀត ។

ចំណុចសំខាន់នៃគំរោងនេះ គឺផ្តោតទៅលើការឈានទៅរកចំណុចរួមគ្នាជាមួយនឹងគំនិតផ្តួចផ្តើមទាំងឡាយ នៅក្នុងវិស័យហិរញ្ញវត្ថុដែលមាននៅក្នុងសហគមន៍អភិវឌ្ឍអាហ្វ្រិកខាងត្បូង និង តំបន់រូបិយវត្ថុអាហ្វ្រិកខាងលិច ។ គោលបំណងរួម គឺដើម្បីធ្វើសមាហរណកម្មប្រព័ន្ធទូទាត់ថ្នាក់ជាតិនីមួយៗ ដើម្បីបង្កើតបានជាប្រព័ន្ធឆ្លងប្រទេសដ៏រឹងប៉ឹងមួយ ។ វឌ្ឍនភាពមានច្រើនត្រូវបានធ្វើឡើង ដើម្បីឈានសម្រេចគោលបំណងនេះ ។ ឧទាហរណ៍ជាក់ស្តែង នៅក្នុងប្រទេសបូស្វាន់ណា និង ស្វាហ្ស៊ីឡែន គេកំពុងអនុវត្តទៅតាមប្រព័ន្ធថ្មី RTGS នានាដែលជាលទ្ធផលនៃគំរោងនេះ ។



Christa Lachenmaier/laif/Aurora & Quanta Productions, Inc.

# ការតស៊ូដើម្បីជីវភាព ប្រសើរឡើង

សេដ្ឋកិច្ចពិភពលោក មានការរីកចំរើនឥតឈប់ឈរចាប់តាំងពីសង្គ្រាមលោកលើកទី២ ដោយបាននាំមកនូវភាពសំបូររុងរឿងយ៉ាងទូលំទូលាយ និង លើកស្ទួយជីវភាពរបស់ប្រជាជនច្រើនលាននាក់ឱ្យរួចចាកផុតពីភាពក្រីក្រជាពិសេសក្នុងតំបន់អាស៊ី ។ ទោះបីយ៉ាងនេះក្តី ក៏បញ្ហាប្រឈមនៅមានសភាពតឹងតែងនៅឡើយ ។ នៅក្នុងតំបន់អាហ្វ្រិក ជាពិសេសវឌ្ឍនភាពក្នុងការកាត់បន្ថយភាពក្រីក្រនៅមានកំរិតក្នុងរយៈកាលច្រើនទសវត្សរ៍កន្លងមកនេះ និង ប្រទេសមួយចំនួនខ្លះទៀត បានឈានថយក្រោយ ។ បើពិនិត្យមើលទៅមុខ រយៈពេល ២៥ឆ្នាំទៀត ចំនួនប្រជាជនក្នុងពិភពលោកត្រូវបាន់ស្មានថានឹងកើនឡើងប្រហែលពីរពាន់លាននាក់ ហើយភាគច្រើននៃកំនើននេះ កើតមាននៅក្នុងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ ។ ភាគច្រើននៃប្រជាជនទាំងនេះនឹងត្រូវធ្លាក់ទៅក្នុងភាពក្រីក្រ ប្រសិនបើគ្មានការខិតខំប្រឹងប្រែងរួមណាមួយពីសំណាក់ប្រទេសក្រីក្រខ្លួនឯង និង ពីសំណាក់សហគមន៍អន្តរជាតិ ។

## ការសំរបសំរួលជំនួយអភិវឌ្ឍន៍

មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងបណ្តាប្រទេសមានកំរិតប្រាក់ចំណូលទាប ក្នុងនោះគោលដៅស្នូលនៃកិច្ចការរបស់ខ្លួនគឺដើម្បីលើកស្ទួយដល់ស្ថិរភាព និង កំណើនសេដ្ឋកិច្ចដែលនាំឱ្យសម្រេចបាននូវការកាត់បន្ថយភាពក្រីក្របានស៊ីជម្រៅ និង យូរអង្វែង ។ សំរាប់ការងារនេះ មូលនិធិរូបិយវត្ថុអន្តរជាតិ បានធ្វើការយ៉ាងជិតស្និតជាមួយធនាគារពិភពលោកដែលជាទីភ្នាក់ងារអន្តរជាតិឈានមុខគេក្នុងការកាត់បន្ថយភាពក្រីក្រ ។ ដោយធ្វើការរួមគ្នាបែបនេះ ពួកគេកំពុងតែជួយប្រទេសជាច្រើនឱ្យមានការរីកចំរើនឆ្ពោះទៅ សម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្ស (MDGs) (សូមមើលប្រអប់ នៅទំព័របន្ទាប់) តាមរយៈការផ្តល់ប្រឹក្សាគោលនយោបាយ ជំនួយបច្ចេកទេស ការផ្តល់ប្រាក់កម្ចី ការលប់បំណុល និង ការគាំទ្រ ដល់សេរីភាវូបនីយកម្មផ្នែកពាណិជ្ជកម្ម ។

សម្ពាធក្នុងការសំរេចគោលដៅអភិវឌ្ឍន៍សហសវត្សត្រឹមឆ្នាំ ២០១៥ បានជំរុញកិច្ចខិតខំប្រឹងប្រែងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ បន្ថែមទៀតឱ្យផ្តោតលើការជួយប្រទេសទាំងឡាយ ក្នុងការបង្កើននូវកិច្ចខំប្រឹងប្រែងផ្នែកគោលនយោបាយ ក៏ដូចជាការគាំទ្រផ្នែកហិរញ្ញវត្ថុពីខាងក្រៅ ក្នុងន័យដើម្បីរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ។ ក្នុងបរិបទនេះ មូលនិធិរូបិយវត្ថុ

ស្រីម្នាក់ជាមួយកូនប្រុសរបស់នាង នៅស៊ុមបេ ប្រទេសអង់ហ្គូឡា

អន្តរជាតិ បានជំរុញឱ្យប្រទេសនីមួយៗបង្កើត និង វិភាគជំរើសក្របខ័ណ្ឌផ្សេងៗ ដើម្បីសំរេចបាននូវ គោលដៅអភិវឌ្ឍន៍ សហសវត្ស ហើយធ្វើឱ្យគោលនយោបាយទាំងនេះគាំទ្រដល់យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ខ្លួន។ មូលនិធិរូបិយវត្ថុអន្តរជាតិបានផ្តល់ប្រឹក្សាដល់ប្រទេសមានប្រាក់ចំណូលទាបអំពីរបៀបគ្រប់គ្រងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនៃការហូរចូលជំនួយ។ ប្រការនេះមានសារៈ សំខាន់ដោយសារក្នុងឆ្នាំ ២00៥ ប្រទេសអ្នកផ្តល់ជំនួយសំខាន់ៗបានបង្ហាញឱ្យដឹងថា ពួកគេនឹងបង្កើនបរិមាណជំនួយក្រៅប្រទេស ទៅឱ្យប្រទេសកំពុងអភិវឌ្ឍន៍នៅក្នុងទសវត្សរ៍បន្ទាប់ ។ ជាមួយនឹងភាគីអ្នកផ្តល់ជំនួយវិញ មូលនិធិរូបិយវត្ថុអន្តរជាតិ កំពុងធ្វើការជាមួយដៃគូអភិវឌ្ឍន៍ពហុភាគី ដើម្បីជំរុញឱ្យមានភាពអាចប៉ាន់ប្រមាណ បាននៃលំហូរជំនួយ និង សំរេចបាននូវភាពចុះសម្រុងប្រសើរឡើងក្នុងផ្នែករដ្ឋបាល និង ក្នុងគោលនយោបាយក្នុងចំណោមដៃគូអភិវឌ្ឍន៍ ។

ចាប់តាំងពីឆ្នាំ ១៩៩៩ គំនិតផ្តួចផ្តើមចំនួនបីត្រូវបានប្រើប្រាស់ជាសំខាន់ដើម្បីលើកស្ទួយការគាំទ្រផ្នែកហិរញ្ញវត្ថុ របស់មូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោក ចំពោះប្រទេសមានប្រាក់ចំណូលទាបៈ

- ឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (PRSPs) រៀបចំដោយប្រទេសទទួលប្រាក់កម្ចីនីមួយៗដោយដាក់ ចេញនូវយុទ្ធសាស្ត្រគោលនយោបាយផ្ទាល់ខ្លួន ដើម្បីជាមូលដ្ឋាន សំរាប់ការផ្តល់ប្រាក់កម្ចីសម្បទានដោយមូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោក ។
- គំនិតផ្តួចផ្តើមសំរាប់ប្រទេសជំពាក់បំណុលធ្ងន់ធ្ងរ (HIPC) ដែលបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៦ និង បានពង្រីងបន្ថែមនៅឆ្នាំ ១៩៩៩ ដោយម្ចាស់ឥណទានជួយផ្តល់ជំនួយលប់បំណុលនៅក្នុងលក្ខណៈសំរបសំរួលក្នុងគោលដៅ ដើម្បីរក្សានូវនិរន្តរភាពបំណុល ។
- គំនិតផ្តួចផ្តើមជំនួយលប់បំណុលពហុភាគី (MDRI) ដែលក្នុងនោះមូលនិធិរូបិយវត្ថុអន្តរជាតិ សមាគមអភិវឌ្ឍន៍អន្តរជាតិ (IDA) របស់ធនាគារពិភពលោក និង មូលនិធិអភិវឌ្ឍន៍អាហ្វ្រិក បានប្រកាសលុបចោល បំណុលទាំងស្រុង (១00%) នៃសន្និធិបំណុលរបស់ខ្លួន ចំពោះប្រទេសមួយចំនួនដើម្បីជួយប្រទេសទាំងនោះឱ្យសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្ស ។

ឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (PRSPs) ជាយុទ្ធសាស្ត្រជាតិមានលក្ខណៈ គ្រប់ជ្រុងជ្រោយដើម្បីកាត់បន្ថយភាពក្រីក្រ ។ យុទ្ធសាស្ត្រនេះ សំដៅផ្តល់ការផ្សារភ្ជាប់សំខាន់រវាងបណ្តាប្រទេសមានកំរិតប្រាក់ចំណូលទាប ដៃគូអ្នកផ្តល់ជំនួយ និង គោលនយោបាយអភិវឌ្ឍន៍ចាំបាច់ដើម្បីឈានទៅសំរេចគោលដៅអភិវឌ្ឍន៍សហសវត្ស ។ ឯកសារ PRSPs ផ្តល់ជាមូលដ្ឋានប្រតិបត្តិការសំរាប់មូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោកសំរាប់ការផ្តល់ប្រាក់កម្ចី សម្បទាន និង ជំនួយលប់បំណុលក្រោមគំនិតផ្តួចផ្តើមសំរាប់ប្រទេសជំពាក់បំណុលធ្ងន់ធ្ងរ HIPC ។ ក្នុងករណីមូលនិធិរូបិយវត្ថុអន្តរជាតិ ប្រាក់កម្ចីត្រូវបានផ្តល់តាមរយៈកម្មវិធីឥណទានសំរាប់ការកាត់បន្ថយភាពក្រីក្រ និង កំណើន (PRGF) របស់ខ្លួន ។

ប្រទេសមានកំរិតប្រាក់ចំណូលទាប រៀបចំយុទ្ធសាស្ត្ររបស់ខ្លួនដោយមានការចូលរួមពីសំណាក់ស្ថាប័នពាក់ព័ន្ធក្នុងស្រុក និងដៃគូអភិវឌ្ឍន៍ពីខាងក្រៅ ។ ដោយធ្វើបច្ចុប្បន្នកម្មជានុប្បវត្តិ (យ៉ាងហោចណាស់៥ឆ្នាំម្តង) ដោយមានរបាយការណ៍អំពីវឌ្ឍនភាពប្រចាំឆ្នាំ PRSPs ដែលពិពណ៌នាអំពីគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច រចនាសម្ព័ន្ធគ្រប់គ្រង និង គោលនយោបាយ សង្គមកិច្ចដែលប្រទេសមួយមានផែនការសំរេច និង អំពីរបៀបហិរញ្ញប្បទានផែនការនោះ ។ នៅពេលប្រទេសមួយបានរៀបចំឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររួចហើយ ប្រទេសនេះមានលក្ខណៈសម្បត្តិនឹងទទួលប្រាក់កម្ចីពីមូលនិធិសទ្ធា PRGF និង ជំនួយលប់បំណុលសំរាប់ប្រទេសជំពាក់បំណុលធ្ងន់ធ្ងរ HIPC ។

ការពង្រីងគំនិតផ្តួចផ្តើម HIPC ដែលបានកែលំអក្នុងឆ្នាំ ១៩៩៩ បានផ្តល់នូវលទ្ធភាពដល់ការលប់បំណុលបានលឿន ស៊ីជម្រៅ និង កាន់តែទូលំទូលាយសំរាប់ប្រទេសមានកំរិតប្រាក់ចំណូលទាប ហើយពង្រឹងចំណងទាក់ទងរវាងជំនួយលប់បំណុល និង ការកាត់បន្ថយភាពក្រីក្រ ជាពិសេសតាមរយៈគោលនយោបាយសង្គម ។ ការបន្តកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសដើម្បី រក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និង ការកំណែទំរង់ រចនាសម្ព័ន្ធ និងគោលនយោបាយសង្គមរួមទាំងការបង្កើនការចំណាយទៅលើកម្មវិធីផ្នែកសង្គម (ដូចជា សេវាសុខាភិបាល និង អប់រំមូលដ្ឋាន) គឺជាចំណុចសំខាន់នៃការពង្រីងគំនិតផ្តួចផ្តើម HIPC ។

មកទល់ពេលនេះ ប្រទេសចំនួន ២៩ បានឈានដល់ចំណុចសេចក្តីសំរេចនៅក្រោមគំនិតផ្តួចផ្តើមពង្រីង HIPC ហើយសេវាបំណុលតំលៃមានតែនាម (Nominal debt service) ចំនួន ៥៩ពាន់លានដុល្លា ត្រូវបានសន្យាផ្តល់អោយប្រទេសទាំងនេះដោយសហគមន៍អន្តរជាតិ ។ ជំនួយឋិតក្រោមគំនិតផ្តួចផ្តើម HIPC រំពឹងថានឹងជួយកាត់បន្ថយបំណុលប្រទេសទាំងនេះ ប្រមាណពីរភាគបីនៃតំលៃបច្ចុប្បន្នសុទ្ធ (Net present value) ។ ប្រទេសដែលមានបំណុលធ្ងន់ធ្ងរចំនួន ១៩ ក៏បានឈានចូលដល់ចំណុច បញ្ចប់របស់គេ នៅពេលដែលការលប់បំណុលត្រូវបានផ្តល់អោយ ហើយមិនអាចទាមទារវិញបាន ដោយប្រទេសឥណទាយកទាំងឡាយ ។ ចំណែកឯប្រទេសចំនួន ១១ទៀតត្រូវបានគេធ្វើអត្តសញ្ញាណថាមានលក្ខណៈសម្បត្តិ គ្រប់គ្រាន់ស្របតាមគំនិតផ្តួចផ្តើម

## គោលដៅអភិវឌ្ឍន៍សហស្សវត្ស

ថ្នាក់ដឹកនាំនៃបណ្តាប្រទេសចំនួន ១៨៩ បានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ប្រចាំសហសវត្សកាលពីខែ កញ្ញា ឆ្នាំ ២000 ដោយអនុម័តលើគោលដៅអភិវឌ្ឍន៍សហស្សវត្ស (MDGs) ដែលជាគោលដៅចំនួន ៨ រួមបញ្ចូលទិសដៅច្បាស់លាស់សំរាប់ការកាត់បន្ថយភាពក្រីក្រ ប្រយុទ្ធដោះស្រាយនូវប្រភពផ្សេងៗនៃទុរគតភាពរបស់មនុស្ស និង លើកកំពស់ កិច្ចអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ។ គោលដៅអភិវឌ្ឍន៍សហស្សវត្ស MDGs ទាំង៨ ដែលគេស្វះស្វែងសម្រេច ឱ្យបានត្រឹមឆ្នាំ ២0១៥ រួមមានៈ

១. កាត់បន្ថយឱ្យបានពាក់កណ្តាលនូវភាពក្រីក្រ និង ភាពអត់ឃ្លានធៀបនឹងឆ្នាំ ១៩៩0 ។
២. សំរេចឱ្យបាននូវការអប់រំជាសកលនៅបឋមសិក្សា ។
៣. លើកកំពស់សមភាពយេនឌ័រ ។
៤. កាត់បន្ថយអត្រាមរណៈរបស់កុមារ ។
៥. បង្កើនការគាំពារសុខភាពមាតា ។
៦. ប្រយុទ្ធប្រឆាំងនឹង HIV/AIDS ជម្ងឺគ្រុនចាញ់ និង ជម្ងឺដង្កាត់ផ្សេងៗទៀត ។
៧. ធានានូវនិរន្តរភាពផ្នែកបរិស្ថាន ។
៨. បង្កើតនូវភាពជាដៃគូជាសកលដើម្បីកិច្ចអភិវឌ្ឍន៍ ។

កិច្ចប្រជុំដើម្បីធ្វើការតាមដានរបស់មេដឹកនាំលើពិភពលោកនៅក្នុងទីក្រុងម៉ោនធឺរី (Monterrey) ប្រទេសម៉ិចស៊ិច (Mexico) កាលពីខែ មិនា ឆ្នាំ ២00២ បានបង្កើតឱ្យមានការចែករំលែកនូវចំណេះដឹងទៅវិញទៅមកលើយុទ្ធសាស្ត្រល្អៗ ដែលចាំបាច់ ដើម្បីសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្ស ។ ការព្រមព្រៀងមតិនៅក្នុងកិច្ចប្រជុំម៉ោនធឺរី (Monterrey) បានបង្កើតឱ្យមាន កិច្ចព្រមព្រៀងថ្មីរវាងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និង ប្រទេសអភិវឌ្ឍន៍ដែលសង្កត់ធ្ងន់ទៅលើការទទួលខុសត្រូវទៅវិញទៅមករបស់ខ្លួន នៅក្នុងការស្វែងរកការសម្រេចគោលដៅអភិវឌ្ឍន៍ ។ គេបានអំពាវនាវឱ្យបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ឱ្យធ្វើការបង្កើនគុណភាពគោលនយោបាយ និង អភិបាលកិច្ចរបស់ខ្លួន និង អំពាវនាវឱ្យប្រទេសអភិវឌ្ឍន៍ឱ្យបង្កើននូវការគាំទ្ររបស់ខ្លួន ជាពិសេសដោយផ្តល់នូវជំនួយជាបន្ថែមទៀត និង ឱ្យកាន់តែប្រសើរឡើង និង បើកសិទ្ធិឱ្យប្រទេសកំពុងអភិវឌ្ឍន៍ចូលទៅកាន់ទីផ្សាររបស់ខ្លួន ។



Jürogen Effner/dpa/Landov

និសិ្សតទាំងឡាយនៅឯភូមិរបស់កុមារ SOS នៃក្រុងលូសាកា។ នៅដើមឆ្នាំ២០០៦ ប្រទេសហ្សាមប្បៀ បានទទួលលប់បំណុលចំនួន ៥៨១ លានដុល្លា ក្រោមគំនិតផ្តួចផ្តើមជំនួយលប់បំណុលជាពហុភាគី។

សំរាប់លក្ខណៈវិនិច្ឆ័យលើចំណូល និង ភាពជាប់បំណុល ដោយប្រើទិន្នន័យនៅចុងឆ្នាំ ២០០៤ ហើយអាចរំពឹងថា នឹង ត្រូវបានពិចារណាសំរាប់ជំនួយគំនិតផ្តួចផ្តើម HIPC ។

គំនិតផ្តួចផ្តើម MDRI បំពេញបន្ថែមលើជំនួយដែលផ្តល់នៅក្រោមគំនិតផ្តួចផ្តើម HIPC ។ ហើយគំនិតផ្តួចផ្តើមនេះ បានចូលជាធរមាននៅមូលនិធិរូបិយវត្ថុអន្តរជាតិ ចាប់តាំងពីថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០០៦ ។ ប្រទេសដែលមានសិទ្ធិទទួលជំនួយ MDRI ពីមូលនិធិរូបិយវត្ថុអន្តរជាតិ រួមមានប្រទេស HIPCs ទាំងអស់ដែលបានបំពេញលក្ខខណ្ឌបញ្ចប់នៃគំនិតផ្តួចផ្តើមនេះ (ពោលគឺប្រទេសទាំងនោះ បានឈានដល់ចំណុចមួយដែលពួកគេអាចទទួលជំនួយ HIPC បានពេញលេញ) និងប្រទេសមិនមែន HIPC ដែលមានកំរិតប្រាក់ចំណូលសំរាប់មនុស្សម្នាក់ៗនៅត្រឹម ឬ នៅក្រោម ៣៨០ ដុល្លា ។

មកទល់ពេលនេះ ជំនួយលប់បំណុលដែលមានទឹកប្រាក់ចំនួន ៣.៧ ពាន់លានដុល្លា ត្រូវបានផ្តល់ទៅឱ្យប្រទេសចំនួន ២១ ក្នុងនោះ ប្រទេសក្រោយពីបំពេញលក្ខខណ្ឌ HIPC មានចំនួន ១៩ ប្រទេស (បេណាំង បូលីវីយ៉ា ប៊ួគីណាហ្វាសូ កាមេរ៉ូន អេត្យូពី ហ្គាណា ហ្គុយ៉ាណា ហុងឌុយរ៉ាស ម៉ាដាហ្គាស្កា ម៉ាលី ម៉ូរីតានីយ៉ា ម៉ូហ្សាំប៊ិក នីការ៉ាហ្គ័រ នីហ្សេ រ៉្វាន់ដា សេណេហ្គាល់ តាន់ហ្សានីយ៉ា យូហ្គាន់ដា និង ហ្សំាមប៊ី) និង ប្រទេសមិនមែនHIPCs ពីរ (**កម្ពុជា**និងតាយីគីស្តង់)។ ប្រទេសជាច្រើនទៀតអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សំរាប់ទទួលជំនួយលប់បំណុល MDRI ពីមូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុង ឆ្នាំ២០០៦។ បណ្តាប្រទេសដូចជា ម៉ាឡាវី (Malawi) សៅ តូមេ (Sao Tomé) ព្រិនសីព (Principe) និង សេរ៉ាលីអូន (Sierra Leone) ត្រូវបានគេរំពឹងថានឹងឈានដល់ការបំពេញលក្ខខណ្ឌបញ្ចប់នៃ HIPC ហើយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សំរាប់ទទួល MDRI នៅក្នុងឆ្នាំ ២០០៦ ។

ក្នុងខណៈដែលគំនិតផ្តួចផ្តើម HIPC មានគោលបំណងធានានិរន្តរភាពបំណុលសំរាប់ប្រទេសក្រីក្រជាប់បំណុលធ្ងន់ធ្ងរ គំនិតផ្តួចផ្តើម MDRI បានឈានលើសពីនេះដោយលុបចោលទាំងស្រុងនូវបំណុលស្របច្បាប់ (ដែលបានបើកផ្តល់ត្រឹម ចុងឆ្នាំ ២០០៤ ហើយនៅមិនទាន់សងក្នុងពេលដែលប្រទេសនេះ មានសិទ្ធិទទួលជំនួយលប់បំណុល MDRI) ដើម្បីរំដោះ ធនធានបន្ថែមសំរាប់ជួយប្រទេសទាំងនេះឱ្យឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្ស ។ មិនដូចជាគំនិតផ្តួចផ្តើម HIPC ដែលត្រូវមានសកម្មភាពសំរបសំរួលពីគ្រប់ម្ចាស់ឥណទាន MDRI ពុំបានស្នើការលើកលែងបំណុលពីសំណាក់ម្ចាស់ ឥណទានទ្វេភាគី ឬ ឯកជន ឬ ស្ថាប័នពហុភាគីណាមួយក្រៅពី IMF, IDA និង AfDF ឡើយ ។ ហើយគំរូ បែបបទនៃការអនុវត្តន៏ នៃគំនិតផ្តួចផ្តើមលប់ចោលបំណុលក៏មានលក្ខណៈខុសគ្នាផងដែរ ពីស្ថាប័នមួយទៅស្ថាប័នមួយទៀត។

សំរាប់ប្រទេសនានា ដើម្បីទទួលបានអត្ថប្រយោជន៏ពេញលេញពីការលើកលែងបំណុល ជាសំខាន់គេត្រូវជួយប្រទេសទាំងនោះ កុំឱ្យខ្ចីប្រាក់ហួសប្រមាណក្នុងពេលអនាគត ។ ប្រទេសទាំងនោះត្រូវថ្លឹងថ្លែងរវាងតម្រូវការរបស់ខ្លួនក្នុងការបង្កើនចំណាយសាធារណៈ ដើម្បីសំរេចគោលដៅអភិវឌ្ឍន៏សហស្សវត្ស និងហានិភ័យនៃលទ្ធភាពជំពាក់បំណុលធ្ងន់ធ្ងរជាថ្មីម្តងទៀត។ ក្របខ័ណ្ឌធានាចីរភាពបំណុល សំរាប់ប្រទេស មានកំរិតប្រាក់ចំណូលទាបដែលបានរៀបចំឡើងរួមគ្នាដោយមូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោកនៅក្នុងឆ្នាំ ២០០៤ អាចជួយដល់ម្ចាស់បំណុល និងកូនបំណុលក្នុងការវាយតំលៃហានិភ័យ នៃបំណុលគ្មាននិរន្តរភាពចេះតែកើនឡើង ។ ក្របខ័ណ្ឌធានាចិរភាពបំណុលតាមដាននិន្នាការសូចនាករបំណុលសំខាន់ៗ ក្នុងបរិមាណបំណុល ជាកំណត់និមួយៗ (ដោយផ្សារភ្ជាប់នឹងគុណភាពគោលនយោបាយ និង ស្ថាប័នក្នុងប្រទេសជាប់បំណុលទាំងនោះ) ព្រមទាំងឥរិយាបថរបស់គេចំពោះមុខវិបត្តិ។ ក្របខ័ណ្ឌធានាចីរភាពបំណុលបានក្លាយជាឧបករណ៏ដ៏សំខាន់មួយ សំរាប់ជាមគ្គុទេសក្នុងការផ្តល់សេវាប្រឹក្សារបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ផ្នែកគោលនយោបាយជូនប្រទេសក្រីក្រ ដែលមានកំរិតប្រាក់ចំណូលទាប ។

## ជំហានត្រូវអនុវត្តបន្ត

ទោះបីជាប្រទេសទាំងឡាយដែលទទួល ឬ ធ្លាប់ទទួលកម្មវិធីឥណទាន PRGF បានបង្ហាញឱ្យឃើញពីការរីកចំរើនគួរឱ្យសំគាល់ក្នុងការអនុវត្តន៏ម៉ាក្រូសេដ្ឋកិច្ចក្តី ក៏ប្រទេសក្រីក្រដែលមានកំរិតប្រាក់ចំណូលទាបភាគច្រើនស្ថិតនៅឆ្ងាយពីការរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់គ្រប់គ្រាន់ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៏សហសវត្សថ្មី ឱ្យបានត្រឹមឆ្នាំ ២០១៥ នៅឡើយ។ មូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោក នៅក្នុងរបាយការណ៏តាមដានសេដ្ឋកិច្ចសកលលោកប្រចាំឆ្នាំលើកទី ៣ របស់ខ្លួនដែលតាមដានពីវឌ្ឍនភាពរបស់ប្រទេសទាំងអស់បានបង្ហាញឱ្យឃើញថា ការរីកចំរើនរបស់ប្រទេសនីមួយៗមិនមានភាពស្មើគ្នាទេ ។ ចំណុចដែលល្អគឺថារបាយការណ៏បានរកឃើញភស្តុតាងពីការធ្លាក់ចុះនូវអត្រាមរណៈកុមារក្នុងប្រទេស កំពុងអភិវឌ្ឍន៏ចំនួន ៩ ក្នុងចំណោម ១០ ប្រទេសដែលស្ថិតក្នុងការអង្កេតនិងរកឃើញការថយចុះជាលើកដំបូងនៃអត្រាឆ្លងមេរោគអេដស៏ក្នុងប្រទេសដែលរងគ្រោះខ្លាំងពីជម្ងឺនេះដូចជា ប្រទេសហៃទី អ៊ូហ្គាន់ដារ និង ហ្ស៊ីមបាវេ ។ អត្រាចុះឈ្មោះ ចូលរៀនថ្នាក់បឋមសិក្សាក៏ត្រូវបានកត់សម្គាល់ថាបានកើនឡើងយ៉ាងឆាប់រហ័ស។ ទោះជាយ៉ាងនេះក្តី មានប្រទេសជាច្រើន ជាពិសេសនៅក្នុងទ្វីបអាហ្វ្រិក និង អាមេរិកឡាទីន មិនទាន់សម្រេចបាននូវភាពជឿនលឿនជាដុំកំភួនក្នុងកាត់បន្ថយភាពក្រីក្រ ហើយប្រទេសក្នុងតំបន់អាស៊ី ខាងត្បូងពុំទាន់មានវឌ្ឍនភាពគ្រប់គ្រាន់នៅឡើយលើសូចនាករអភិវឌ្ឍន៏មនុស្ស ។ របាយការណ៏បោះពុម្ពផ្សាយក្នុងឆ្នាំ ២០០៦ បានសង្កត់ធ្ងន់ថាកំណើនសេដ្ឋកិច្ចជំនួយច្រើនជាងមុន និង ប្រកបដោយគុណភាពល្អជាងមុន កំណែទំរង់ពាណិជ្ជកម្ម និង អភិបាលកិច្ចល្អ គឺជាកត្តាសារវ័ន្តដើម្បីសំរេចគោលដៅអភិវឌ្ឍន៏សហសវត្ស ។

ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន មូលនិធិរូបិយវត្ថុអន្តរជាតិ បានបន្តសង្កត់ធ្ងន់លើភាពគ្រប់គ្រាន់នៃឧបករណ៏ទាំងឡាយរបស់ខ្លួន សំរាប់ធ្វើការពាក់ព័ន្ធជាមួយនឹងប្រទេសក្រីក្រមានកំរិតប្រាក់ចំណូលទាប។ ទោះបីជា PRGF នៅជាតែឧបករណ៏សំខាន់

សំរាប់ជួយប្រទេសជាសមាជិក សំរាប់ប្រទេសក្រីក្រមានកំរិតចំណូលទាបក៏ដោយ សំរាប់ប្រទេសមួយចំនួន ដែលមានវឌ្ឍនភាពច្រើនគួរឱ្យកត់សម្គាល់ក្នុងការរក្សាស្ថេរភាពសេដ្ឋកិច្ច និង លែងត្រូវការជំនួយហិរញ្ញវត្ថុទៀត មូលនិធិរូបិយវត្ថុអន្តរជាតិបានដាក់ចេញនូវឧបករណ៍គាំទ្រគោលនយោបាយ (Policy Support Instrument-PSI) ថ្មីមួយកាលពីខែ តុលា ឆ្នាំ ២០០៥ ។ PSI អនុញ្ញាត្តិឱ្យមូលនិធិរូបិយវត្ថុអន្តរជាតិគាំទ្រប្រទេសទាំងនោះក្នុងការរៀបចំកម្មវិធីសេដ្ឋកិច្ចឱ្យមានប្រសិទ្ធិភាពខ្ពស់ ។ នៅពេលដែលទទួលការអនុម័តយល់ព្រមពីគណៈកម្មការប្រតិបត្តិ របស់មូលនិធិរូបិយវត្ថុអន្តរជាតិរួចហើយ កម្មវិធីទាំងនោះនឹងផ្តល់សារដល់ប្រទេសម្ចាស់ជំនួយ ធនាគារអភិវឌ្ឍន៍ពហុភាគី និង ទីផ្សារអំពីការគាំទ្ររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ចំពោះគោលនយោបាយរបស់ប្រទេសជាសមាជិក ។ ការគាំទ្រផ្នែកគោល នយោបាយ និង ការផ្តល់សារអំពីការអនុវត្តន៍ និងទស្សនៈវិស័យរបស់ប្រទេសអាចប្រើប្រាស់ជាពតិមានសំរាប់ការសំរេចចិត្តរបស់អ្នកខាងក្រៅហើយ ជាឧទាហរណ៍អាចមានឥទ្ធិពលដល់លំហូរនៃជំនួយពីក្រៅប្រទេស រួមទាំងជំនួយលប់បំណុល និង ជំនួយដទៃទៀតផងដែរ ។

កាលពីខែ ធ្នូ ឆ្នាំ ២០០៥ មូលនិធិរូបិយវត្ថុអន្តរជាតិ បានដាក់ឱ្យប្រើប្រាស់កម្មវិធីឥណទានសំរាប់គ្រប់គ្រងវិបត្តិពី ខាងក្រៅ (Exogenous Shocks Facility-ESF) ដើម្បីផ្តល់ការគាំទ្រផ្នែកគោលនយោបាយ និង ជំនួយសម្បទានផ្នែក ហិរញ្ញវត្ថុដល់បណ្តាប្រទេសក្រីក្រមានកំរិតប្រាក់ចំណូលទាប ដែលកំពុងប្រឈមនឹងវិបត្តិដែលមិនអាចគ្រប់គ្រងបាន (មើលនៅលើទំព័រ ២៣) ។ ចំពោះបណ្តាប្រទេសក្រីក្រមានកំរិតប្រាក់ចំណូលទាបដែលប្រឈមមុខនឹងបញ្ហាលំបាកផ្នែកជញ្ជីងពាណិជ្ជកម្ម ដោយសារតែគ្រោះធម្មជាតិ ឬ កំណែទំរង់ពាណិជ្ជកម្មពហុភាគី ឬ ទើបនឹងងើបពីជម្លោះ មូលនិធិរូបិយវត្ថុអន្តរជាតិ បានរៀបចំយន្តការផ្តល់ការទ្រទ្រង់ឥណទានក្នុងលក្ខខណ្ឌសម្បទាននៅក្រោមការ "ឧបត្ថម្ភជំនួយសង្គ្រោះបន្ទាន់ពីគ្រោះធម្មជាតិ" និងយន្តការសមាហរណកម្មពាណិជ្ជកម្ម (TIM) និង ជំនួយសង្គ្រោះបន្ទាន់សំរាប់ប្រទេសងើបចេញពីជម្លោះ ។

នៅក្នុងយុទ្ធសាស្ត្ររយៈពេលមធ្យមរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (សូមមើលទំព័រ ៧) ដែលទទួលបានការយល់ព្រម ពីប្រទេសជាសមាជិកកាលពីកិច្ចប្រជុំនាទិទាយរដូវឆ្នាំ ២០០៦ ស្ថាប័ននេះនឹងខិតខំសំរិតសំរាំងតួនាទីរបស់ខ្លួនបន្ថែមទៀត នៅក្នុងបណ្តាប្រទេសក្រីក្រមានកំរិតប្រាក់ចំណូលទាប ។ ទី១. ស្ថាប័ននេះនឹងត្រូវផ្តោតលើបញ្ហាសំខាន់សំរាប់ប្រទេសនីមួយៗ ដើម្បីសំរេចបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ការបែងចែកការងាររបស់ខ្លួនជាមួយធនាគារពិភពលោក និង ផ្តល់លក្ខខណ្ឌ ទន់ភ្លន់សំរាប់កម្មវិធីឥណទានរបស់ខ្លួន ។ ទី២. មូលនិធិរូបិយវត្ថុអន្តរជាតិ នឹងវាយតំលៃថាតើលំហូរជំនួយគ្រោងទុកសមស្រប ទៅនឹងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និង ចំណាយប៉ាន់ស្មានដើម្បីសំរេចគោលដៅអភិវឌ្ឍន៍របស់ប្រទេសនីមួយៗ ឬ យ៉ាងណា ព្រមទាំងធ្វើអ្វីៗច្រើនថែមទៀត ជាមួយប្រទេសអ្នកផ្តល់ជំនួយ ។ ទី៣. មូលនិធិរូបិយវត្ថុអន្តរជាតិ នឹងធានាថាប្រទេសដែលទទួលផលពីជំនួយលប់បំណុលនឹងមិនបង្កើនបំណុលឱ្យជាប់ជំពាក់ច្រើនលើសលប់ជាថ្មីម្តងទៀតឡើយ ។

**បញ្ហាពាណិជ្ជកម្ម និង *ការចរចាពាណិជ្ជកម្ម* Doha Round**

ពាណិជ្ជកម្មមានសក្តានុពលសំខាន់ជាងជំនួយ ក្នុងការជួយប្រទេសកំពុងអភិវឌ្ឍន៍ឱ្យមានការរីកចំរើន ហើយមូលនិធិរូបិយវត្ថុអន្តរជាតិ បន្តសង្កត់ធ្ងន់ទៅលើសារៈសំខាន់ជាសកលនៃការចរចាពាណិជ្ជកម្មទីក្រុងដូហា (ដែលបានចាប់ផ្តើមកាលពី ឆ្នាំ ២០០១) ។ បើគ្មានកិច្ចព្រមព្រៀងដូហា កំណើនសេដ្ឋកិច្ចទូទាំងពិភពលោកនឹងមានល្បឿនយឺតជាង ហើយសេដ្ឋកិច្ចពិភពលោកពិបាកធន់ទ្រាំនឹងវិបត្តិសេដ្ឋកិច្ច ។ នៅក្នុងបរិបទនៃការសំរេចគោលដៅអភិវឌ្ឍន៍សហសវត្ស មូលនិធិរូបិយវត្ថុអន្តរជាតិ ចង់ឃើញនូវលទ្ធផលដ៏ជោគជ័យប្រកបដោយមហិច្ឆតាមួយពីកិច្ចចរចាទីក្រុងដូហា ។ ការប្រឹងប្រែងក្នុងការកាត់បន្ថយភាពក្រីក្រ និង ត្រៀមទទួលផលពីកិច្ចព្រមព្រៀងនេះដែលនឹងធ្វើឱ្យប្រត្យក្សនូវកិច្ចសន្យាអភិវឌ្ឍន៍របស់ខ្លួនជាពិសេសនៅក្នុងការកំណែទំរង់គោលនយោបាយពាណិជ្ជកម្មកសិផល ក្នុងបណ្តាប្រទេសអ្នកមានប្រាក់ចំណូលខ្ពស់ ។ ក្នុងកំឡុងកិច្ចប្រជុំនាទិទាយរដូវ ឆ្នាំ២០០៦ របស់ខ្លួន មូលនិធិរូបិយវត្ថុអន្តរជាតិ បានអំពាវនាវដល់ប្រទេសជាសមាជិកទាំងអស់ឱ្យជួយសំរេចកិច្ចព្រមព្រៀងមួយ ដែលអនុញ្ញាតឱ្យប្រទេសក្រីក្រ អាចទាញយកប្រយោជន៍ពីកាលានុវត្តភាពនៃសមាហរណកម្មពិភពលោកតាមរយៈ សេរីភាវូបនីយកម្មពាណិជ្ជកម្មប្រកបដោយមហិច្ឆតា ។ មូលនិធិរូបិយវត្ថុអន្តរជាតិបានអំពាវនាវឱ្យបញ្ចប់ការចរចាដូហានៅចុង ឆ្នាំ ២០០៦ ។

មូលនិធិរូបិយវត្ថុអន្តរជាតិ បាននិងកំពុងចូលរួមចំណែកគាំទ្រដល់ការបើកចំហរប្រព័ន្ធពាណិជ្ជកម្មអន្តរជាតិ ។ នៅក្នុងឆ្នាំសារពើពន្ធ ២០០៥ មូលនិធិរូបិយវត្ថុអន្តរជាតិ បានបើកឱ្យប្រើប្រាស់យន្តការសមាហរណកម្មពាណិជ្ជកម្ម (TIM) ដើម្បីជួយប្រទេសទាំងឡាយក្នុងការដោះស្រាយនូវឱនភាពជញ្ជីងពាណិជ្ជកម្ម ដែលកើតចេញពីការអនុវត្តន៍ នៃកិច្ចព្រមព្រៀងដូហា និង ជាទូទៅកើតពីការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម ដោយគ្មានការរើសអើងរបស់ប្រទេសនានា ។ យន្តការ (TIM) នេះ បានអនុញ្ញាតឱ្យសមាជិកទាំងឡាយរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ អាចស្នើសុំនូវជំនួយហិរញ្ញវត្ថុក្រោមកម្មវិធីឥណទានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិដែលមានបច្ចុប្បន្ន ដើម្បីបំពេញតម្រូវការគណនីជញ្ជីងទូទាត់ដែលទាក់ទងនឹងពាណិជ្ជកម្មជាបណ្តោះអាសន្ន ។

ពេលដែលកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោកស្តីពីវាយនភណ្ឌ និងសំលៀកបំពាក់ត្រូវបានផុតកំណត់ នៅចុងឆ្នាំ ២០០៤ ជាឧទាហរណ៍ ដូចជាសាធារណៈរដ្ឋដូមីនិកបានទទួលនូវការគាំទ្រក្រោមយន្តការ TIM ដែលធ្វើឱ្យប្រទេសនេះ ក្លាយទៅជាប្រទេសទី២ បានទទួលជំនួយនេះបន្ទាប់ពីបង់ក្លាដែសនៅក្នុងឆ្នាំ ២០០៤ ។ កិច្ចពិភាក្សាជាមួយបណ្តាប្រទេស ជាសមាជិកដទៃទៀតក៏កំពុងតែដំណើរការ ។ លទ្ធភាពទទួលជំនួយក្រោមយន្តការ TIM បានជួយសំរាលការព្រួយបារម្ភណ៍ របស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ចំពោះសម្ពាធនៃកំណែតំរូវដ៏ធ្ងន់ធ្ងរដែលកិច្ចព្រមព្រៀងដូហាសង្កត់មកលើប្រទេសទាំងនេះ ។

ដើម្បីជួយធានាឱ្យបានថា បណ្តាប្រទេសជាសមាជិកអាចទាញយកប្រយោជន៍ពីកាលានុវត្តភាពសេរីភាវូបនីយកម្ម ពាណិជ្ជកម្មពហុភាគីនេះ មូលនិធិរូបិយវត្ថុអន្តរជាតិ បានប្រកាន់យកនូវវិធានការដូចខាងក្រោមៈ

- ផ្តល់ជំនួយបច្ចេកទេសនៅក្នុងវិស័យនានា ដូចជាកំណែទំរង់គយ កំណែទំរង់ ពន្ធដារ និង ពន្ធនាំចូល និង ការបង្កើន គុណភាពទិន្នន័យផ្សេងៗ ។
- ចូលរួមវិភាគទានដល់ការសិក្សាស្រាវជ្រាវអំពីឧបសគ្គទាំងឡាយ ដែលរារាំងដល់សមាហរណកម្មពាណិជ្ជកម្ម នៅក្នុងបណ្តាប្រទេសមានការអភិវឌ្ឍន៍ទាប ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងអន្តរស្ថាប័ន ដែលដឹកនាំដោយធនាគារពិភពលោក ។
- កំណត់វាស់សក្តានុពលហានិភ័យ និង ជួយបណ្តាប្រទេសទាំងនេះអោយយល់ពីអត្ថប្រយោជន៍នៃសមាហរណកម្ម អន្តរជាតិ ។
- វាយតម្លៃអំពីផលប៉ះពាល់ដោយសារកំណែទំរង់ពាណិជ្ជកម្ម ដូចជា ផលវិបាកនៃឧបត្ថម្ភធនផ្នែកកសិកម្មដែលថយចុះ និង ការបាត់បង់បន្តិចម្តងៗនូវលក្ខខណ្ឌអនុគ្រោះការបញ្ចប់ប្រព័ន្ធកូតាវាយនភ័ណ្ឌ ។ ■

## ការិយាល័យវាយតំលៃឯករាជ្យ (IEO)

# ដើម្បីបង្កើនតម្លាភាព និង គណនេយ្យភាព របស់មូលនិធិរូបិយវត្ថុអន្តរជាតិ

ដើម្បីទទួលបានពតិមានដោយឯករាជ្យ ចំគោលដៅ និង ដោយក្រាសក្រៃលអំពីការអនុវត្តន៏របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ក្រុមប្រឹក្សាប្រតិបត្តិ បានបង្កើតឡើងនូវការិយាល័យវាយតំលៃឯករាជ្យមួយ (Independent Evaluation Office-IEO) កាលពីខែ កក្កដា ឆ្នាំ ២00១ ។ ចាប់តាំងពីពេលនោះមក ការិយាល័យវាយតំលៃឯករាជ្យ បានផ្តល់របាយការណ៏លំអិតជាបន្តបន្ទាប់លើគ្រប់ទិដ្ឋភាពនៃការងាររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ។ របាយការណ៏ទាំងនោះ ជួយបង្ហាញអំពីការកែប្រែដែលចង់បាននៅក្នុងគោលនយោបាយ និង កិច្ចប្រតិបត្តិការ។ ការិយាល័យវាយតំលៃឯករាជ្យ អនុវត្តការងាររបស់ខ្លួនដោយឯករាជ្យពីគណៈគ្រប់គ្រង និង បុគ្គលិករបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ហើយក៏មិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាប្រតិបត្តិដែរ។ ការិយាល័យវាយតំលៃ ឯករាជ្យមានលោក ថូម៉ាស អេ ប៊ឺនស៏ (Thomas A. Bernes) ជានាយក និង មានបុគ្គលិក ១២ នាក់ផ្សេងទៀត ដែលភាគច្រើនត្រូវបានជ្រើសរើស ពីក្រៅមូលនិធិរូបិយវត្ថុអន្តរជាតិ និង ខ្លះជាទីប្រឹក្សា ។

គេហទំព័ររបស់ការិយាល័យវាយតំលៃឯករាជ្យ (www.imf.org/ieo) ផ្តល់ជូននូវពតិមានលំអិតអំពីលក្ខន្តិកៈ ការងាររបស់ខ្លួន ការងារមកទល់បច្ចុប្បន្ន ស្ថានភាពគំរោងកំពុងអនុវត្ត របាយការណ៏វាយតំលៃ និង អំពីសិក្ខាសាលា និងសកម្មភាពទំនាក់ទំនងការងារខាងក្រៅផ្សេងទៀត ។ គេហទំព័រនេះ ក៏បានផ្តល់ឪកាសដល់អ្នកពាក់ព័ន្ធដែលមានចំណាប់អារម្មណ៏ (អាជ្ញាធរប្រទេសជាសមាជិក អ្នកសិក្សាស្រាវជ្រាវនានា អង្គការក្រៅរដ្ឋាភិបាល និង សមាជិកសង្គមស៊ីវិលដ៏ទៃទៀត) ចូលរួមប្រាស្រ័យទាក់ទងជាមួយការិយាល័យវាយតំលៃឯករាជ្យនៅក្នុងការកំណត់កម្មវិធីការងាររបស់ខ្លួន ការកំណត់ លក្ខន្តិកៈការងារសំរាប់ការសិក្សានិមួយៗ និង ការផ្តល់នូវវិភាគទានប្រកបដោយខ្លឹមសារចំពោះការសិក្សាទាំងនោះ។

ការិយាល័យវាយតំលៃឯករាជ្យរៀបចំកម្មវិធីការងាររបស់ខ្លួន ដោយឈរលើមូលដ្ឋាននៃការពិភាក្សាផ្ទៃក្នុង និង ការពិគ្រោះយោបល់ខាងក្រៅដោយទូលំទូលាយ ។ សេចក្តីព្រាងឯកសារអំពីបញ្ហាទាំងឡាយសំរាប់ការវាយតំលៃ ត្រូវបានផ្សព្វផ្សាយនៅក្នុងគេហទំព័រ សំរាប់ការទទួលមតិយោបល់ពីសាធារណជនសំរាប់ទាំងការសិក្សាដែលខ្លះបានបញ្ចប់ និង ខ្លះទៀតកំពុងដំណើរការ ។

ក្នុងការរៀបចំកម្មវិធីការងារសំរាប់ពេលអនាគត ការិយាល័យវាយតំលៃឯករាជ្យបានកំណត់ប្រធានបទច្រើន សំរាប់ការវាយតំលៃក្នុងរយៈពេលមធ្យម ដោយឆ្លុះបញ្ចាំងពីសំណើរជាច្រើនទទួលបានពីភាគីពាក់ព័ន្ធខាងក្រៅ ព្រមទាំងពីនាយកប្រតិបត្តិនានា គណៈគ្រប់គ្រង និង បុគ្គលិករបស់មូលនិធិរូបិយវត្ថុអន្តជាតិ ។

### ការវាយតំលៃដែលបានធ្វើចប់សព្វគ្រប់

- ការប្រើប្រាស់អូសបន្លាយនូវធនធានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។
- តួនាទីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ នៅក្នុងវិបត្តិគណនីមូលធនកាលពីពេលថ្មីៗនេះនៅប្រទេសកូរ៉េ ឥណ្ឌូណេស៊ី និង ប្រេស៊ីល ។
- កំណែតំរូវសារពើពន្ធនៅក្នុងកម្មវិធីដែលទ្រទ្រង់ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ ។
- តួនាទីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ នៅអាហ្សង់ទីន ក្នុងកំឡុងឆ្នាំ ១៩៩១-២00១ ។
- ប្រសិទ្ធិភាពនៃដំណើរការរៀបចំឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និង កម្មវិធីឥណទាន ដើម្បីការកាត់បន្ថយភាពក្រីក្រ និង កំណើន ។
- ជំនួយបច្ចេកទេសរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។
- វិធីសាស្ត្ររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ចំពោះការធ្វើសេរីភាវូបនីយកម្មគណនីមូលធន ។
- កម្មវិធីវាយតំលៃវិស័យហិរញ្ញវត្ថុ ។
- ជំនួយរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ចំពោះប្រទេសហ្សកដង់ ។
- យន្តការសង្កេតការណ៏ពហុភាគី របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។

### ការវាយតំលៃដែលកំពុងធ្វើ

- លក្ខខណ្ឌរចនាសម្ព័ន្ធ របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។
- តួនាទីរបស់ មូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុងការកំណត់កញ្ចប់ធនធានជំនួយក្រៅប្រទេសនៅតាមបណ្តាប្រទេស ក្នុងឧបទ្វីបអាហ្វ្រិក-សាហារ៉ា ។
- ការផ្តល់យោបល់របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ចំពោះគោលនយោបាយអត្រាប្តូរប្រាក់ ។

ក្នុងឆ្នាំ ២00៦ ការិយាល័យវាយតំលៃឯករាជ្យខ្លួនឯង ត្រូវបានវាយតំលៃដោយគណៈកម្មការឯករាជ្យពីខាងក្រៅមួយ ។ ផ្អែកលើរបាយការណ៏របស់គណៈកម្មការនេះ ក្រុមប្រឹក្សាប្រតិបត្តិអនុម័តយល់ព្រមថា ការិយាល័យវាយតំលៃឯករាជ្យ បានបំរើមូលនិធិរូបិយវត្ថុអន្តរជាតិបានយ៉ាងល្អប្រសើរ ហើយទទួលបានការគាំទ្រយ៉ាងទូលំទូលាយ ពីសំណាក់ភាគីពាក់ព័ន្ធជាច្រើន ។ គណៈកម្មការឯករាជ្យក៏បានកត់សំគាល់ចំណុចមួយចំនួនសំរាប់ពង្រឹងការិយាល័យវាយតំលៃដោយឯករាជ្យ ដែលចំណុចទាំងនេះកំពុងត្រូវបានតាមដានបន្ត ។ ក្រុមប្រឹក្សាប្រតិបត្តិក៏បានអនុម័តយល់ព្រមផងដែរថា មូលនិធិរូបិយវត្ថុអន្តរជាតិនៅបន្តត្រូវការការិយាល័យវាយតំលៃឯករាជ្យ ដើម្បីរួមចំណែកដល់វប្បធម៌រៀនសូត្ររបស់ស្ថាប័ននេះ និង ដើម្បីជួយសំរួលដល់ការគ្រប់គ្រង និង អភិបាលកិច្ចរបស់គណៈកម្មាធិការប្រតិបត្តិ ។ ■

### ការពង្រឹងយន្តការសង្កេតការណ៏: មេរៀនទទួលបានពីការវាយតំលៃថ្មីៗរបស់ការិយាល័យវាយតំលៃឯករាជ្យ

ថ្មីៗនេះ ការិយាល័យវាយតំលៃឯករាជ្យ បានបញ្ចប់នូវការវាយតំលៃចំនួនពីរ ពាក់ព័ន្ធនឹងយន្តការសង្កេតការណ៏ ដែលជាសកម្មភាពស្នូលសំខាន់របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។ វិស័យជាក់លាក់សំខាន់ៗ ដែលជាកម្មវត្ថុនៃការវាយតំលៃនេះ គឺកម្មវិធីវាយតំលៃ វិស័យហិរញ្ញវត្ថុ (Financial sector Assessment Program-FSAP) និង ការសង្កេតការណ៏ពហុភាគី (Multilateral Surveillance)។ របាយការណ៏ បានរកឃើញកត្តាវិជ្ជមានជាច្រើនក្នុងនោះរួមមានគុណភាពនៃការវិភាគនៅក្នុងរបាយការណ៏សង្កេតការណ៏ពហុភាគី និង ការរីកចំរើនលេចធ្លោចំពោះសមត្ថភាពរបស់ មូលនិធិរូបិយវត្ថុអន្តរជាតិ នៅក្នុងការសង្កេតការណ៏ផ្នែកហិរញ្ញវត្ថុដែលជាលទ្ធផលនៃកម្មវិធី FSAP ។ ជាមួយគ្នានេះដែរ ការិយាល័យវាយតំលៃឯករាជ្យបានបង្ហាញនូវវិស័យសំខាន់ៗជាច្រើនត្រូវការលើកកំពស់ នៃការសង្កេតការណ៏ជារួម ។

សំរាប់គំរោង FSAPs ភាពប្រឈមសំខាន់ៗមាន:

- ធានាអោយបាននូវវិសាលភាពគ្របដណ្តប់ក្នុងពេលអនាគត លើប្រទេសសំខាន់ៗជាប្រព័ន្ធ ។
- ដោះស្រាយបញ្ហាឆ្លងដែន (ដែលភាគច្រើនមិនត្រូវបានគេយកចិត្តទុកដាក់រហូតមកទល់បច្ចុប្បន្ន) ។ និង
- ចាត់វិធានការ ដើម្បីបង្កើនសមាហរណកម្មជាមួយនឹងការតាមដានទ្វេរភាគីជាទូទៅ ។ សមាហរណកម្មនេះនៅមានបញ្ហានៅឡើយ ។

ពាក់ព័ន្ធនឹងការតាមដានពហុភាគី ការវាយតំលៃបានសន្និដ្ឋានថា ការងាររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ គឺទាបជាង សក្តានុពលរបស់ខ្លួន ។ ការវាយតំលៃនេះបានផ្តល់នូវអនុសាសន៏សំរាប់ការផ្លាស់ប្តូរ ដូចខាងក្រោម :

- ត្រូវធ្វើអោយមានសមាហរណកម្មប្រសើរឡើង រវាងផ្នែកហិរញ្ញវត្ថុ និង ម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងការវិភាគទ្វេរភាគី និង ពហុភាគី និង ការផ្តល់អនុសាសន៏គោលនយោបាយ ។
- ត្រូវធ្វើយ៉ាងណាអោយលទ្ធផលការងាររបស់មូលនិធិរូបិយវត្ថុអន្តរជាតិមានលក្ខណៈ "ផ្តោតលើអតិថិជនជាសំខាន់" តាមរយៈផលិតផលដែលមានភាពរលូនផ្តោតច្បាស់ជាងមុនផ្តល់សារខ្លីៗ និង ច្បាស់លាស់ព្រមទាំងការពង្រឹងយុទ្ធសាស្ត្រទំនាក់ទំនង ។ និង
- បង្កើនជំរុញឥទ្ធិពលនៃក្រុមប្រឹក្សាប្រតិបត្តិ និង គណៈកម្មការរូបិយវត្ថុអន្តរជាតិ និង ហិរញ្ញវត្ថុ នៅក្នុងការត្រួតពិនិត្យ តាមដានពហុភាគី គួបផ្សំនឹងការប្រើប្រាស់អោយបានប្រសើរយន្តការនៃការប្រមូលផ្តុំជាក្រុមតូចៗរបស់បណ្តាប្រទេស ដែលមូលនិធិរូបិយវត្ថុអន្តរជាតិចូលរួម។

# ទិដ្ឋភាពរួម

## សូចនាករសំខាន់ៗ របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (គិតត្រឹមថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៦ ប្រសិនបើគ្មានការបញ្ជាក់ផ្សេងទៀត) [១]

| | |
|---|---|
| សមាជិកភាព | ១៨៤ ប្រទេស |
| ទីស្នាក់ការកណ្តាល | ទីក្រុងវ៉ាស៊ីនតោនឌីស៊ី |
| គណៈកម្មការប្រតិបត្តិ | ២៤ សមាជិក |
| បុគ្គលិកសរុប | ប្រហែល ២៧០០ នាក់ |
| កូតាសរុប | ៣១០ពាន់លានដុល្លា (២១៣,៥ពាន់លាន SDR) |

**កូតា**

| | |
|---|---|
| ប្រទេសដែលមានកូតាច្រើនជាងគេបំផុត | សហរដ្ឋអាមេរិក (១៧,៤ភាគរយ នៃកូតាសរុប) |
| ប្រទេសដែលមានកូតាតិចជាងគេបំផុត | ប៉ាឡូ (០,០០១ភាគរយ នៃកូតាសរុប) |

**ធនធាន ឬ ទុនប្រាក់ឱ្យខ្ចី**

| | |
|---|---|
| ធនធានប្រាក់ឱ្យខ្ចីនៅទំនេរ ដែលអាចប្រើប្រាស់បាន[២] | ២១៦,៦ពាន់លានដុល្លា (១៤៧,២ពាន់លាន SDR) |
| សមត្ថភាពធានាការឱ្យខ្ចីសំរាប់រយៈពេល១ឆ្នាំទៅមុខ[៣] | ១៧៦,៦ពាន់លានដុល្លា (១២០,១ពាន់លាន SDR) |

**ប្រភពឥណទាន[៤]**

| | |
|---|---|
| ឥណទានអាចប្រើប្រាស់បានក្រោមយន្តការកម្ចីនានា | ៥០,០ពាន់លានដុល្លា (៣៤,០ពាន់លាន SDR) |

**ទុនបំរុង**

| | |
|---|---|
| តុល្យការគណនីបង្ការ[៥] | ១១,២ពាន់លានដុល្លា (៧,៦ពាន់លាន SDR) |

**ទ្រព្យសកម្មផ្សេងទៀត**

| | |
|---|---|
| ទ្រព្យសកម្មរក្សាទុកជាមាស | ១០៣,៤លាន អោនស៍ |
| តំលៃចុះបញ្ជី IMF | ៨,៦ពាន់លានដុល្លា (៥,៨៥ពាន់លាន SDR) |
| តំលៃទីផ្សារ | ៦៦,៦ពាន់លានដុល្លា (ក្នុងតំលៃ ដុល្លា៦៤៤,០/oz) |

**ឥណទានជំពាក់**

| | |
|---|---|
| ឥណទានសរុប | ៣៤,១ពាន់លានដុល្លា (២៣,១ពាន់លាន SDR) |
| ឥណទានផ្តល់ជូនប្រទេសមានកំរិតចំណូលទាប នៅក្នុងលក្ខខណ្ឌសម្បទាន | ៥,៨ពាន់លានដុល្លា (៣,៩ពាន់លាន SDR) |
| ឥណទានផ្តល់ជូនប្រទេសសមាជិកផ្សេងទៀត | ២៨,៣ពាន់លានដុល្លា (១៩,២ពាន់លាន SDR) |

**កម្មវិធីផ្តល់ប្រាក់កម្ចី នាពេលបច្ចុប្បន្ន**

| | |
|---|---|
| កម្មវិធីឥណទានបំរុង | ១០ |
| ឥណទានមូលនិធិរយៈពេលវែង | ១ |
| ឥណទានសំរាប់ការអភិវឌ្ឍន៍ និងកាត់បន្ថយភាពក្រីក្រ និង ឥណទានក្នុងគ្រាមានវិបត្តិពីខាងក្រៅ(PRGF-ESP) | ២៧ |

**ប្រទេសដែលខ្ចីប្រាក់ច្រើនជាងគេបំផុត**

| | |
|---|---|
| ប្រទេសទួរគី | ១៣,១ពាន់លានដុល្លា (៨,៩ពាន់លាន SDR) |
| ប្រទេសឥណ្ឌូណេស៊ី | ៧,៦ពាន់លានដុល្លា (៥,២ពាន់លាន SDR) |
| ប្រទេសអ៊ុយរ៉ាហ្គាយ | ១,៩ពាន់លានដុល្លា (១,៣ពាន់លាន SDR) |
| ប្រទេសអ៊ុយក្រែន | ១,១ពាន់លានដុល្លា (៧៣៤លាន SDR) |
| ប្រទេសស៊ើប និង ម៉ុងតេណាក្រូ | ៩៦៥លានដុល្លា (៦៥៦លាន SDR) |

**ជំនួយលប់បំណុល សំរាប់ប្រទេសក្រីក្រដែលជាប់បំណុលធ្ងន់ធ្ងរ** (HIPCs) គិតត្រឹមចុងខែ មេសា ឆ្នាំ ២០០៦

| | |
|---|---|
| បានបំពេញគ្រប់លក្ខណៈវិនិច្ឆ័យ និង ឈានដល់ចំណុចបញ្ចប់ | ១៩ ប្រទេស |
| បានឈានដល់ចំណុចធ្វើការសម្រេចចិត្ត តែមិនទាន់បានបំពេញ តាមលក្ខណៈវិនិច្ឆ័យបន្ថែមដើម្បីឈានដល់ចំណុចបញ្ចប់ | ១០ ប្រទេស |
| បានបំពេញលក្ខណៈវិនិច្ឆ័យនៃភាពជាប់បំណុល និង កំរិតប្រាក់ចំណូល នៅចុងឆ្នាំ ២០០៤ ហើយអាចត្រូវបានពិចារណាផ្តល់ជំនួយលប់បំណុលសំរាប់ប្រទេសក្រីក្រជាប់បំណុលធ្ងន់ធ្ងរ | ១១ ប្រទេស |
| ការចំណាយសរុបសំរាប់ជំនួយដោះបំណុល HIPC សំរាប់ប្រទេសក្រីក្រជាប់បំណុលចំនួន ២៩ ដែលឈានដល់ដំណាក់កាលធ្វើការសម្រេចចិត្ត | ៤១,៣ពាន់លានដុល្លា (លក្ខខណ្ឌ NPV គិតត្រឹមចុងឆ្នាំ ២០០៥) |
| ការចំណាយរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ សំរាប់ប្រទេសក្រីក្រជាប់បំណុលទាំង ២៩ ដែលឈានដល់ចំណុចធ្វើការសម្រេចចិត្ត | ៣,១ ពាន់លានដុល្លា (លក្ខខណ្ឌ NPV គិតត្រឹមចុងឆ្នាំ ២០០៥) |

**ស្ថានភាពនៃការផ្តល់ជំនួយក្រោមគំនិតផ្តួចផ្តើមពហុភាគីសំរាប់ការលប់បំណុល** (MDRI)

| | |
|---|---|
| ប្រទេសទទួលជំនួយ MDRI | ២០ ប្រទេស |
| ជំនួយសំរាប់សងគណនីឥណទានធនធានទូទៅ | ១៣៦,២ លានដុល្លា (៨៩,៨លាន SDR) |
| ជំនួយសំរាប់សងឥណទាន PRGF-ESF | ៣,៧ពាន់លានដុល្លា (២,៤ពាន់លាន SDR) |
| សរុប | ៣,៨ពាន់លានដុល្លា (២,៥ពាន់លាន SDR) |

សំគាល់ :

[១] តំលៃដុល្លាសហរដ្ឋអាមេរិកគិតតាមអត្រា ១ SDR = ១,៤៧១០៦ (ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៦) និង គិតត្រឹមលេខមូល ។

[២] ស្មើនឹងផលដកនៃធនធានអាចឱ្យខ្ចីដែលអាចប្រើប្រាស់បាន និង បរិមាណសរុបនៃតុល្យការឥណទាន មិន ទាន់ដកយកទៅប្រើប្រាស់ក្រោមឥណទានកំពុងអនុវត្ត ។

[៣] គឺជារង្វាស់នៃធនធានមានសំរាប់ការធានាហិរញ្ញវត្ថុឱ្យខ្ចីថ្មីក្នុងឆ្នាំបន្ទាប់ ដែលមានចំនួនស្មើនឹងធនធាន អាចប្រើប្រាស់បានមិនទាន់ចុះកិច្ចសន្យាបូក ការទិញចូលសំរាប់រយៈពេល ១ ឆ្នាំ ដក តុល្យការបង្ការ (ដែលកំណត់ក្នុងចំនួន ៥០,៣ពាន់លាន ដុល្លា (៣៤,២កោដ SDR) នៅចុងឆ្នាំសារពើពន្ធ ២០០៦) ។

[៤] មូលនិធិរូបិយវត្ថុអន្តជាតិ មានប្រភពឥណទានពីរដែលអាចប្រើប្រាស់បាន ប្រសិនបើត្រូវការសាច់ប្រាក់បន្ថែម: ទី១, យន្តការទូទៅសំរាប់ការខ្ចីប្រាក់ (GAB) និង ទី២, យន្តការថ្មីសំរាប់ការខ្ចីប្រាក់ (NAB) ។ ការប្រើប្រាស់ប្រភពឥណទានទាំងនេះ ចុងក្រោយបំផុត គឺនៅឆ្នាំ ១៩៩៨ ។

[៥] មូលនិធិរូបិយវត្ថុអន្តរជាតិ សន្សំតុល្យការបង្ការវិបត្តិ ដែលក្នុងនោះមានគណនីធនធានបំរុង និង គណនីពិសេស សំរាប់គ្រាអាសន្ន គឺដើម្បីការពារខ្លួន និងការពារប្រទេសឥណទាយក ជាសមាជិក ពីការខាតបង់ក្នុងករណីមានការមិនសង ប្រាក់កម្ចី ។

ទិន្នន័យ : នាយកដ្ឋានហិរញ្ញវត្ថុ របស់មូលនិធិរូបិយវត្ថុអន្តរជាតិ

# មូលនិធិរូបិយវត្ថុអន្តរជាតិត្រូវបានរៀបចំយ៉ាងដូចម្តេច




[១] ពីមុនហៅថាគណៈកម្មការក្រសួងរួមនៃក្រុមប្រឹក្សាភិបាលរបស់ធនាគារពិភពលោក និងមូលរូបិយវត្ថុអន្តរជាតិ សំរាប់ការផ្ទេរធនធានពិតអោយទៅប្រទេសកំពុងអភិវឌ្ឍនានា ។

[២] សកម្មភាពទាំងឡាយរបស់នាយកដ្ឋានទាំងនេះកំពុងតែត្រូវច្របាច់បញ្ចូលគ្នា ។

[៣] ភ្ជាប់ជាមួយការិយាល័យរបស់នាយកគ្រប់គ្រង ។

IMFPUBLICATIONS

# The Macroeconomic Management of Foreign Aid: Opportunities and Pitfalls




***Editors: Peter Isard, Leslie Lipschitz, Alex Mourmouras, and Boriana Yontcheva***

This new volume emphasizes that a substantial increase in foreign aid will be necessary but not sufficient to meet the Millennium Development Goals. Sound macroeconomic management by recipients of foreign aid, and supportive efforts by donors, will also be crucial. Issues addressed in the papers and overview chapter include the relationship between aid, growth, and poverty reduction; the potential for sizable increases in aid to adversely affect competitiveness, and how to avoid this; and the effect of aid on institutions and the political economy in recipient countries.

$28.00  2006 Paperback.
ISBN: 1-58906-520-4
**Stock# MMFAEA**



## World Economic Outlook

The *World Economic Outlook* is the product of a unique international exercise in information gathering and analysis performed by IMF staff to guide key initiatives and to serve IMF member countries. Published at least twice a year in English, French, Spanish, and Arabic, the *World Economic Outlook* offers a comprehensive picture of the international economic situation and prospects for the future. With its analyses backed by the expertise and resources of over 1,100 IMF economists, the *World Economic Outlook* is the authoritative reference in its field.

$54.00  2006 Paperback.
ISBN: 1-58906-549-2
**Stock# WEOEA2006001**




## Public-Private Partnerships, Government Guarantees, and Fiscal Risk

*IMF Staff Team Led by Richard Hemming*

Public-private partnerships (PPPs) refer to arrangements under which the private sector supplies infrastructure assets and infrastructure-based services that traditionally have been provided by the government. This Special Issue paper provides an overview of some of the issues raised by these PPPs, with a particular focus on their fiscal consequences. It also looks at government guarantees, which are used fairly widely to shield the private sector from risk and are a common feature of PPPs. The paper concludes with a list of measures that can maximize the benefits and minimize the fiscal risks associated with the use of PPPs.

$25.00  2006 Paperback.
ISBN: 1-58906-493-3
**Stock# ISIEA2005009**




## Global Financial Stability Report April 2006

This semi-annual publication from the IMF provides comprehensive coverage of mature and emerging financial markets and seeks to identify potential fault lines in the global financial system that could lead to crises. It is designed to deepen understanding of global capital flows, which play a critical role as an engine of world economic growth.

$49.00  2006 Paperback.
ISBN: 1-58906-504-2
**Stock# GFSREA2006001**

---

**International Monetary Fund**
Publication Services
Room HQ1-CN-235
700 19th Street, N.W.
Washington, D.C. 20431 U.S.A.

Telephone: (202) 623-7430
Telefax: (202) 623-7201
E-mail: *publications@imf.org*

Prepaid orders may be mailed, phoned, faxed, or e-mailed. Please include AMEX, Visa, or MasterCard number, expiration date, and signature on all orders.

CODE: P0608GNO-IF